ការសង្ខេបប្រវត្តិរបស់អ៊ំស្រី ញាន ទូច

អ៊ំស្រីញាន

ទូចគាត់ជាកូនអ្នកស្រែចំការហើយគាត់មានបងប្អូនជាច្រើននាក់ប៉ុន្តែគាត់អត់បានស្គាល់មុខទាំងអស់ទេ

ព្រោះបងគាត់ខ្លះត្រូវបានស្លាប់នៅពេលគាត់មិនទាន់បានកើត។ជីវិតរបស់អ៊ំស្រីបានកើតទាន់ពេលជំនាន់សង្គ្រាមហើយគាត់បានធ្វើការនៅក្នុងកងកុមារផងនឹងកងយុវនារីផង

។អ៊ំបានប្រាប់ថាគាត់បានដើរជាន់សាកសពដែលគេកប់ពុំបានជិតហើយហើម

គាត់ក៏បានឃើញពួកប៉ុល

ពតយកមនុស្សទៅសម្លាប់ដែរតែគាត់ពុំហ៊ានមាត់ឡើយព្រោះខ្លាចគេយកទៅសម្លាប់ដែរ។នៅថ្ងៃបែកសង្គ្រាមពួកប៉ុល

ពតបានអោយឈប់ធ្វើការហើយអោយត្រលប់ទៅផ្ទះហើយគាត់ក៏ត្រលប់ដោយមានភាពភ័យខ្លាចមិនដឹងថានឹងមានរឿងអ្វីកើតឡើងបន្ទាប់ទៀត

រួចបន្ទាប់មកក៏មានទាហានវៀតណាមចូលមកជាច្រើន។បន្ទាប់បែកសង្គ្រាមហើយម្តាយអ៊ំបានស្លាប់រួចបានប៉ុន្មានឆ្នាំមកអ៊ំស្រីក៏រៀបអាពាហ៍ពិពាហ៍ហើយបានប៉ុន្មានឆ្នាំក្រោយមកទៀតស្វាមីក៏បានស្លាប់ចោលទៀតបន្សល់កូនប្រុសមួយនាក់ ហើយគាត់ក៏រៀបប្តីថ្មី

ហើយហើយមានកូនស្រីៗមកទៀត

ហើយសព្វថ្ងៃគាត់រស់នៅជាមួយស្វាមីនឹងកូនហើយចៅដោយសុខសាន្តនៅក្នុងទីលំនៅបច្ចុប្បន្នរបស់គាត់គឺស្ថិតនៅក្នុងភូមិទន្លេបាទី ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។

ការសម្ភាសន៍របស់អ៊ំស្រីញានទូច

អ្នកដែលសម្ភាសន៍ឈ្មោះញ៉ែមសុគន្ធា អ្នកដែលត្រូវគេសម្ភាសន៍ញាន ទូច

ក:

ជាដំបូងនេះខ្ញុំសូមថ្លែងអំណរគុណដល់អ៊ំស្រីដែលអោយខ្ញុំសម្ភាសន៍ពីជីវប្រវត្តិរបស់អ៊ំស្រីហើយ
នាងខ្ញុំឈ្មោះញ៉ែមសុគន្ធា
ជាអ្នកសម្ភាសអំពីជីវប្រវត្តិរបស់អ៊ុំស្រីនៅក្នុងថ្ងៃនេះហើយខ្ញុំត្រូវជាកូយបង្កើតរបស់អ៊ំស្រីផងដែរ។
ហើយពួកយើងសម្ភាសន៍គឺនៅក្នុងភូមិទន្លេបាទីឃុំក្រាំងធ្នង់ស្រុកបាទីខេត្តតាកែវប្រទេសកម្ពុជា
។ពួកយើងសម្ភាសន៍ថ្ងៃទី 10 ខែសីហាឆ្នាំ 2018
ហើយនាងខ្ញុំសូមចាប់ផ្តើមសម្ភាសន៍អំពីជីវប្រវត្តិរបស់អ៊ំដែលមានដូចតទៅ!អញ្ចឹងអ៊ុំប្រាប់ឈ្មោះរ
បស់អ៊ំឈ្មោះពេញឈ្មោះអីគេ?

ខ:ឈ្មោះញានទូចនិងតែម្តង ។

ក: ថ៎ អ៊ំ មានឈ្មោះហៅខាងក្រៅអីដែរឬក៏អត់?

ខ:អត់!

ក:តែមួយទេអញ្ចឹងហេ?

ខ:តែមួយហ្នឹង!

ក:អត់មានអ្នកណាគេដាក់ងារអ្វីអោយផ្សេងពីហ្នឹងទេហេ?

ខ:ចា៎!អត់ទេ!

ក:អ៊ុំឆ្នាំខ្មែរកើតឆ្នាំអីគេទៅវិញ?

ខ:ឆ្នាំខ្មែរឆ្នាំអីគេមើលនៅក្នុងសៀវភៅគ្រួសារទៅមីអូន!

ក:ឆ្នាំខ្មែរអាជូតឆ្លូវខាលថោះនោះហ្ន៎??

ខ:ឆ្នាំខាល!

ក:ហ្ន៎!

ខ:ឆ្នាំខាល!

ក:ឆ្នាំខាលដូចជាតាបុិចដែរ?

ខ:ចា៎!

ក:ប៉ុន្តែកាច់ជាងតាបុិចហ៎?

ខ:កាចដែលធម្មតាតែតែធ្វើអីមិនស្រួលវែ
ដែរហ្នឹងណាស់ខូច!

ក:អ៊ីថ្ងៃអាយុប៉ុន្មានឆ្នាំហើយ?

ស្វាមី:37ហិ?

ខ:ហេ៥៦។

ស្វាមី:57!

ខ:56!

ក:ហ៉ាអញ្ចឹងអាយុប្អូនម៉ែទេអញ្ចុះ???
ខ:អូនតើ!អ៊ុំស្រែករក្រោយទេតើបើនៅកងកុ
មារនិងយើងបើនៅបែកអាពតបានប្រហែ
លមួយឆ្នាំបានខ្ញុំការការហៅ
អីហើយហ្នឹងមានប្តីនិងប្តីគេស្លាប់ចោលទៅ
បានឪវានឹងគេទៅសួរនាំអីអញ្ចឹងទៅថាបើ
មីងឯងនេះមីងឯងទទួលខ្ញុំដែរ
ឬទេ?ខ្ញុំមានស្ទឹគ្រាន់តែថាចាំមើលអោយតែ
កុំឲ្យតែកាន់ជើងកូនពេកខ្ញុំនិយាយត្រង់ត្រ
ង់ៗចឹងតែម្តងមនុស្សតែមានប្តី

មានប្រពន្ធមានកូនយើងត្រូវតែកាន់ជើងកូនអញ្ចឹងខ្ញុំថាអ្វីបន្តិចបន្តួចកុំកាន់ជើងកូននិយាយតែត្រឹមត្រូវទេអត់មាននិយាយរឿងវេ!

ក:អញ្ចឹងបានសុខគ្នា!

ខ:ចា៎!

ក:ធម្មតាតែចាស់ចាស់ត្រូវតែស្តីអោយក្មេងក្មេងហើយតែធ្វើអ្វីខុសមិនត្រូវស្តីឲ្យ!

ខ:តែធ្វើខុសស្តីអោយហើយ!

ក:ហ្នឹងហើយ!

ខ:បើធម្មតា!ប៉ុន្តែមីសយរាកាន់ជើង!មីសុ!

ក:អ៊ំនិយាយថាអ៊ុំកើតខែខ្មែរគេហៅថាអ្វីដូចជាភទ្របទ ចេស អាសាធ អាហ្នឹងអ៊ំចាំដែរឬទេ?

ខ:អត់ចាំទេ!

ក:អត់ចាំទេ!

ខ:ចាំតែឆ្នាំខាលនឹងមួយ!

ក:អញ្ចឹងនៅក្នុងសៀវភៅកំណើតរបស់អ៊ុំ ខ្ញុំបានមើលគឺអ៊ុំ
ក្នុងសៀវភៅគ្រួសាររអ៊ំកើតក្នុងសៀវភៅគ្រួសាររបស់អ៊ុំអ៊ុំ
កើតថ្ងៃទី 8 ខែ 9 1964 ហ្អ៎អញ្ចឹងអ៊ំប្អូនរបស់មីងសយទៀត? ហ៎ៅបងបងពីឆ្នាំ។

ខ:បងមីសយ!ដំណាលមីស៊ីម!

ក:ចា៎!ហ្នឹងហើយអណ្តែតនៅក្នុងភូមិខ្វាន់មាសឃុំពត់សរស្រុកបាទីខេត្តតាកែវ។

ខ:ស្រុកបាទីខេត្តតាកែវ។

ក:អញ្ចឹងអ៊ុំស្រុកកំណើត នៅពត់សរនេះទេអញ្ចឹង?

ខ: នៅពត់សរតើ!

ក:នៅជិតផ្ទះពូសឿនដែរឬក៏អត់?

ខ:អត់ទេ សឿននៅភូមិខ្ញុំ ខ្ញុំនៅខ្វាន់មាស ហួសប្តែតបន្តិចទៅដល់ហើយ!

ក:ចា៎!តែត្រូវផ្លូវបត់ចូលទៅក្នុងដែរឬក៏អត់អ៊ំ?

ខ:អត់ចូលទេទៅត្រង់តែម្តង ពីប្តែតហ្នឹងទៅត្រង់តែម្តង។

ក:អញ្ចឹង នៅលើថ្នល់ជាតិទេអញ្ចឹងហេ?

ខ:នៅលើថ្នល់ជាតិទេដូចថាផ្លូវលំអញ្ចឹងដូចអញ្ចឹង!ក:ហ្អ៎!ខ:ចូលមកជ្រៅអញ្ចឹងអាហ្នឹង!

ក:ចូលតាមផ្លូវវត្តអីគេ?

ខ:វត្តបិទមាស!

ក:ហ្នឹងហើយ!

ខ:តែខ្ញុំអត់ទៅដល់ហ្នឹងទេនៅឯណោះទេ!នៅនឹងអាយហួសតែប្តែតហ្នឹងទៅដល់ហើយ
ខ្វាន់មាស មានស្រះមួយ
នៅខាងកើតនិងខុសតែបន្តិចទៅដល់ផ្ទះខ្ញុំហើយប្រហែលថា 200 ម៉ែត្រចុះ!

ក:ហ៊ឺ!ហើយឥឡូវហ្នឹងផ្ទះនិងអ្នកណាគេជាអ្នកនៅ?

ខ:បង ប៉ុន្តែឥឡូវបងស្លាប់ហើយមានតែបងមួយនឹងខ្ញុំមានបង 2

ប៉ុន្តែបងបង្អស់នឹងគាត់ស្លាប់ហើយនៅតែក្ងួយក្ងួយ

នៅណែនផ្ទះនោះ!អត់មានអ្នកណាគេថាអត់មានអ្នកណាគេអីទេ។ឪពុកស្លាប់ទៅប៉ែលិនគេចាប់

ផ្តើមពេលនោះ

យកទៅប៉ែលិននោះអោយតែទៅប៉ែលិនគាត់មកវិញគាត់ចាញ់ហើយគាត់ស្លាប់ទៅ។

ក:ច្រើនណាស់អ៊ុំប្រជាជនខ្មែរពេលហ្នឹងស្លាប់ដោយសារទៅទីហ្នឹង!

ខ: ដោយសារយកទៅប៉ែលិននិងដោយសារយកទៅប៉ែលិនហ្នឹង

ហ៊ីតាសួនមកវិញថាតែមិនរស់ផងទេចាញ់ចាញ់

ឡើងស្គមឡើងស្គែកគាំងមកហើយបងរបស់ខ្ញុំគាត់ហ៊ាន

គាត់ហ៊ានហូបសាច់គោហើយនឹងជ្រក់ណាស់ជ្រក់ល្អុង

ណាស់! ហូបទៅទៅបណ្តោយ។

ក:ហ្អ៊ុំ អ៊ុំយើងត្រូវតែឲ្យស្រួលបួលមែនទែនបើមិនអញ្ចឹងហូបអីមិនស្រួល!

ខ:អត់បានទេ!ចា៎!យើងមកពីនោះម្ចាស់ទឹកម្ចាស់ដីគេគេដូចថាគេចាញ់ណាស់ ហើយដោយ

យើងឯណេះទឹកដី

អត់ចាញ់វាចាញ់ពីនោះមកហើយ។

ក: វាស្រាប់មកពីនោះហើយហ្នឹង!

ខ:ស្រាប់មកពីនោះ!សាច់ឡើងស្អេកហើយណាស់!ឡើងសុទ្ធតែបារតណាស់ឡើង
ខៀវណាស់!

ក:ដោយសារតែផឹកទឹករបស់គេនៅឯណោះអ៊ំហ៎?

ខ:ហ្នឹងហើយ អញ្ចឹងបើយើងទៅឯនឹងហើយមិនហូបទឹកហ្នឹង!

ក:ថាអ្នកខ្លះគេ!

ខ:ឥឡូវបងមួយនៅខ្វាន់មាស អ៉ាំនេះនៅថ្ងៃល់ដាច់នេះ
មកប៉ោចរពាក់មកហៅរាល់យប់ហ្នឹង!អោយតែមកបោច
រពាក់ អើរទូចហ៎!ទូចហ៎ មកបោចរពាក់។

ក:រាល់ថ្ងៃហ្នឹង?

ខ:ច៎!

ក:អ៊ំនៅឯណោះមានព្រៃរពាក់ដែរហេ?

ខ:ហ៊ីខ្ញុះអីព្រៃលើស្សរអ៊ុំ!ខ្ញុះអីរពាក់។

ក:រថយន្តមកធ្វើកន្ត្រកអីមែន?

ខ:កន្ត្រកអីធ្វើបង្គី!

ក:បង្គីហេ?

ខ:ថ៎!

ក:ហ្ន៎ ហើយអ៊ំចេះធ្វើបង្គីទេ?

ខ:ចេះតើ!

ក:ចេះដែរ។

ខ:ខ្ញុំនៅថ្នល់ដាច់ ចាំមើលឪវាគាត់យកនិងខ្ញុំនៅត្រពាំងឬស្សីខ្ញុំចេះធ្វើបង្គីចេះធ្វើអីមួយចប់។

ក:តែឥឡូវអត់ប្រកបមុខរបរនិងទេ?

ខ:អត់!

ក:ចៅច្រើនពេកអ៊ុំណោះ?

ខ:ចៅច្រើនពេក ហើយអញ្ចេះផងបើឪវាចេះតែបោចមកខ្ញុំចេះតែធ្វើទៅណាស់
ប៉ុន្តែដល់តែអ៊ំរបស់ឯងធ្វើអត់កើត
ទៅអត់ធ្វើទៅ!ខ្ញុំធ្វើដែរទេតែកាលពីចំបក់ឪវាបើកមកខ្ញុំចេះតែធ្វើទៅលក់បានមួយ5000
ពីរ10000 អញ្ចឹ
ងទៅ!

ក:ចា៎ហើយអ៊ំបង្គីពេលនឹងប៉ុន្មានបើសិនជាមានវល្លិរពាក់ហ្នឹងយកមកធ្វើមួយថ្ងៃបានប៉ុន្មានទៅអ៊ុំ?

ខ:បើយើងធ្វើដូចថាបោចក្នុងមួយថ្ងៃមួយថ្ងៃបានពីរសម្រាប់ បួនបង្គី! បើគេអ្នកប៉ុនបាន6
បើយើងបោចយើងអត់
សូវប្រសប់អញ្ចឹងបានតែ 4 ឥ៉ាន់ទេ!ជួនកាលបានតែបីផង។

ក:ប៉ុន្តែមានអីបើសិនជាមានគេមកទិញរហូតមានអីធូរដែរអ៊ំ។

ខ:ទិញរហូតហ្នឹងណាស់អោយតែ ! ហ៊ឺពួកហ្នឹងគេបោចតែរហូតរពាក់ដែងៗ
ធ្វើតែមួយក្រវិលតែប៉ុននេះនឹង បាន
មួយហើយអោយទៅដែងៗមួយ ក្រវិលមួយក្រវិលហើយអាហ្នឹងមួយហើយ។

ក:ហេងហើយអញ្ចឹងបើសិនជាអញ្ចឹង!ប៉ុន្តែប្រសិនបើជាអ្នកណាទៅកាប់ទៀត!

ខ:កាលពេលអ៊ុំទៅនេះ ផ្ទះបងខ្ញុំនេះម្តុំថ្ពល់ដាច់នេះណាស់អ៊ុំនៅទីហ្នឹងទេការពេលហ្នឹង
បានឪវ៉ាទៅនេះហ្នឹង បោច
មកធ្វើទៅឯខ្ញុំឯណោះអត់ចេះចាក់ដៃ
អត់ចេះចាក់ដៃទេអោយគេជួលគេចាក់ដៃឱ្យអញ្ចឹងទៅហើយយកទៅលក់នៅឯ
នេះឯណោះឯតាខ្មៅណាស់!ក:ចា៎!ខ:អ៊ំជិះកង់ទៅហើយដាក់លក់ 10អាក្រោម 10
ដាក់ជិះកង់ទៅលក់ទៅ

លក់កាលពេលនឹងគេអោយតែប៉ុន្មានកាក់តើ!10តែប៉ុន្មានបានតែប៉ុន្មានរៀលទេ។

ក:ប៉ុន្តែពេលនិងលុយថ្លៃហេ?

ខ:ស្រាប់តែអង្គុយយំ អង្គុយយំនៅឯណោះគេអោយ 7កាក់8
កាក់អត់លក់ណាស់ទៅលក់ដល់ហ្នឹងពាក្យអោយ 5

កាក់ថាអង្គុយយំតែម្តងដាក់គូទអង្គុយយំតែម្តងស្រាប់តែគេថាថីបានជាយំ?ដឹកទៅវិញវាធ្ងន់
ហើយបញ្ចាស់ខ្យល់
យើងលក់ទៅវា ស្តាយគេអោយនៅឯណេះ 7កាក់អត់លក់ អត់លក់ទៅលក់ឯណោះបានតែ 6
កាក់ហ៎ាបានតែ 5
កាក់និង!អង្គុយយំតែម្តង!

ក:ហត់ពេកអ៊ំហេ?

ខ:ហត់ពេកនឹកឃើញថាដឹកមកវិញស្តាយ
បង្គីណាស់ខំបោចចង់ងាប់ហើយយកទៅលក់ឲ្យគេបានតែ 5 កាក់។គេ
មកម៉ៅយក 10 បាន 7រៀល8រៀលដែរហើយយើងអត់សុខចិត្តលក់ណាស់
សុខចិត្តទៅលក់ដល់ណោះហើយលក់
គិតថាបានថ្លៃ។

ក:តែអត់!

ខ:អត់គេអោយតែប្រាំកាក់ទៅកន្លែងណាក៏គេអោយតែប្រាំកាក់ដាក់គូទអង្គុយយំតែម្តងកំសត់ពេក
យំយំហើយជិះតែ
ម្នាក់ឯងទេណាស់ទៅចេញទៅតាំងតែពីម៉ោង 5
ជិះទៅកាលហ្នឹងចំបក់អត់សូវមានឡានទោះណាស់!ក:ថ៎!

ខ:ចេះតែជិះទៅ។

ក:ហើយដល់ពេលដល់ឯណោះអញ្ចឹងទៀត!

ខ:ថោកទៀតណាស់ខឹងអើយខឹងមិនដឹងធ្វើយ៉ាងម៉េច ដូចជាណែនដើមទ្រូងយំតែម្តង។

ក:ហួសចិត្តខ្លួនឯង!

ខ:កំសត់ពេកដូចតូចចិត្តខ្លួនឯងគេអោយ៧កាក់
ទាំងអស់លក់ទៅលក់ឯនោះបានតែ5កាក់ខឹងតែម្តងហាត់ ហាត់
ហើយនឹកឃើញថាជិះមកវិញជិះមកវិញអត់លក់ទេគេមកវិញ
ហ៊ីអញ្ចឹបើជិះមកវិញបែបជិះមិនរួចទេ
បញ្ហាសខ្យល់លក់តែម្តងទៅ!ទៅដល់ឯណោះបងថ្លៃសួរថាឯងលក់បានប៉ុន្មានទូច?លក់បានតែ
ប្រាំកាក់ ហ៊ឹច្រឡះអញ្ចឹងទៅង៉ែង
អញ្ចអោយគេអោយឯណោះ៧កាក់ង៉ែងអត់លក់ហ្នឹងហើយ
ហ៊ឹក្តៅក្រហាយរឹតតែលើសហ្នឹងទៅទៀត!លែងបោច
រពាក់ជាប់កន្តុះខែ ខឹងពេកលែងអស់កម្លាំងពេកលែងទៅ។

ក:អស់កំលាំងចិត្តអ៊ំ!

ខ:លែងទៅ!យាយធុចថាចុះង៉ែងអត់ទៅនឹងគេទេហ៎?ម្តាយក្មេកនឹងណាស់!ក:ថ៎!ខ:យាយ
ភាពនិងថាចុះ

មីនាងអីអត់ទៅទេហេ?អត់ទៅទេអស់កំលាំងណាស់លេងទៅលក់បានតែប៉ុណ្ណឹងអីវ៉ាន់!អញ្ចឹង
ហើយទុកចិត្តដឹក

យកទៅលក់ខ្លួនឯងក្រែងលោបានថ្លៃលើសហ្នឹងណាស់!នឹកឃើញស្រាប់តែគេអោយតែប្រាំកាក់
កន្លែងណាក៏

ដោយអោយតែ៥កាក់ កន្លែងផ្សារចាស់ពេលមុននោះណាស់!ក:ថ៎!ខ:
កន្លែងផ្សារចាស់ជិតមាត់ទន្លេនោះ

ហ្ន៎!

ក:ហ្នឹងហើយ!

ខ:ថាមីអូនអើយខ្ញុំខឹងនោះខឹងមិនដឹងដូចជាស្អីទេ។

ក:ថ៎!អ៊ំរបៀបធ្វើបង្គីគេធ្វើយ៉ាងម៉េចដែរ អ៊ំប្រាប់ពីរបៀបបង្ហាញធ្វើបង្គីទេណាស់!

ខ:គេចាក់វា

អ៊ំប្រាប់មុនដំបូងគេចាក់គេចាក់គូថវាហើយអញ្ចឹងរហូតចាក់អញ្ចឹងឲ្យគ្រប់ពីពីអញ្ចឹងអោយគ្រប់6

6

សងខាងអញ្ចឹងទៅណាស់!ក:ចា៎!ខ:ហើយបានគេនេះត្បាញវាទៅ!

ក:ត្បាញវត្តចុះវត្តឡើងអញ្ចឹងទេ?

ខ:ចា៎!

ក:ហើយដល់ពេលដៃគេមូលគេអីយ៉ាងម៉ិចទៅអ៊ំ?

ខ:ដៃគេមូលគេមូល ហើយបានគេចាក់ ចាក់អញ្ចឹងមូលខាងនេះមកចាក់រុំទៀត ។

ក:ម៉ែរបស់ខ្ញុំចេះតែធ្វើអំបោសអំបោសស្អីគេ!ត្មោតទួកៗអ៊ំហ្ន៎!

ខ:អាហ្នឹង!

ក:អាហ្នឹងម៉ែចេះប៉ុន្តែបើបង្គីវីញខ្ញុំអត់ដឹងប្រហែលម៉ែអត់ចេះទេ ។

ខ:អត់ចេះទេ!

ក:អ៊ំដល់ពេលបងប្អូនវិញអ៊ុំមានបងប្អូនប្រុសស្រីប៉ុន្មាននាក់វិញដែរ?

ខ:និយាយពីបងប្អូនអ៊ុំវិញគាត់ស្លាប់ស្លាប់តាំងតែពី!ម៉ែម៉ែ 12 កូន!

ក:ច្រើនម្ល៉េះ??

ខ:ប៉ុន្តែស្លាប់អស់រលីងសល់តែបីទេនៅតែបងស្រីនឹងមួយហើយបងស្រីនៅថ្នល់ដាច់នឹងមួយហើយឥឡូវស្លាប់បង

ស្រីហ្នឹងបាត់ទៅនៅតែបងស្រីមួយនៅថ្នល់ដាច់ហ្នឹង!

ក:ចា៎ អញ្ចឹងនៅតែ 2នាក់បងប្អូនទេរាល់ថ្ងៃ?ខ:នៅតែពីរនាក់បងប្អូន។

ក:មើលអ៊ំប្រាប់ឈ្មោះបងប្អូនទាំងពីរ 12នាក់អ៊ំណោះ?

ខ:ចា៎!

ក:ប្រាប់ឈ្មោះទាំងអស់ទៅមើលទាំងត្រកូល!

ខ:ខ្ញុំអត់ស្គាល់បើខ្ញុំពៅគេពៅគេបំផុតតែម្តង!ក:អញ្ចឹងចាំប៉ុន្មានអ្នកប្រាប់មកអញ្ចឹង។

ខ:ចាំតែប៉ុនណឹងចាំតែ 3នាក់និង!

ក:មើលឈ្មោះអីគេខ្លះ?

ខ:ឈ្មោះមឿមនោះ1 ឈ្មោះសុសនោះមួយ។ បងមឿនហ្នឹងបងគេ បានមកសុស
សុសហើយបានខ្ញុំ ហើយអ្នក
ទាំងប៉ុន្មានទាំង 7 នាក់នោះស្លាប់អស់រលីង។

ក:អ៊ុំអត់ឃើញមុខគាត់តែម្តងឬក៏អី?

ខ:អត់!បើអត់តែម្តង!

ក:ហើយម្តាយកដែលប្រាប់ឈ្មោះទៀត?

ខ:អត់។

ក:គាត់ឈឺរហូតម៉ែរបស់ខ្ញុំឈឺរហូតគាត់ឈឺគាត់មានធ្វើអីកើតតែឱទេគាត់ចេះតែដួចថាគាត់លក់ដូ
រជួញគោជួញអីអ

ញ៊ឹងទៅណាស់ជូនពរជួនអីអញ៊ឹងទៅបានលុយបានកាក់អញ៊ឹងទៅអោយម៉ែធ្វើស្រែធ្វើភ្លឺអីអញ៊ឹងទៅគាត់ឈឺរហូត!

ក:ពេលនឹងជំងឺអីគេទៅអ៊ុំ?

ខ:គាត់ក្រឡាភ្លើង។

ក:ព្រាយក្រឡាភ្លើងនិងហី?

ខ:ហ្នឹង!

ក:អ៊ំអាព្រាយក្រឡាភ្លើងនិងដោយសារយើងកូនខ្ចីឬក៏យ៉ាងម៉េច?ខ:យើងកូនខ្ចីកូនខ្ចីម៉ែឪនិងគាត់ជាអ្នកជួញគោអញ៊ឹងទៅណាស់គាត់ដើរចោលអ៊ីចឹងទៅដូចថាយើង!ចុះយើងទាល់ដៃទាល់ជើងកូននរាទៅតូចតូចយើងមិននេះមិនដើរអកស៊ីត្រូវដើរអកស៊ីចិញ្ចឹមកូនចិញ្ចឹមប្រពន្ធអញ៊ឹងគាត់ចេះតែដើរជួញគោអញ៊ឹងឆ្ងាយឆ្ងាយទៅណាស់!លក់អញ៊ឹងទៅបានចំណេញអញ៊ឹងទៅគាត់បានយប់មុខអោយប្រពន្ធទៅណាស់!ដល់អីចឹងទៅគាត់ចេះតែដើរចោលអញ៊ឹងទៅគាត់នឹងនៅតែម្នាក់ឯងអញ៊ឹងទៅ!ចុះកូនកូនតែក្មេងក្មេងវាចេះតែដើរលេងបាត់បាត់វាមិនមែនទៅនៅជាមួយយើងឯណាវាអត់នៅជាមួយយើងទេ។

ក:ហើយអញ៊ឹងចេះតែឈឺអញ៊ឹងទៅ?

ខ:គាត់ឈឺរហូតយកទៅពេទ្យព្រែកត្នោតហ្នឹងអញ្ចឹងទៅបានមួយខែពីខែអ៊ីចឹងទៅគាត់ជាទៅយប់មកវិញមក។

ក:អ៊ំអាព្រាយក្រឡាភ្លើងនិងឈឺតែម្តងហេ?

ខ:ឈឺអត់ដូចគ្នាអត់ដឹងអីតែម្តងណាស់ដល់ពេលណាគាត់វក់ៗអញ្ចឹងតែម្តងនេះ។

ក:អាហ្នឹងមកពីត្រូវត្រូវតែអាំងភ្លើងអាំងអីឬក៏យ៉ាងម៉េច?

ខ:មិនមែនទេមិនមែនមកពីៗចឹងទេប៉ុន្តែបើគេបើពេទ្យវិញឮគេថាយើងដូចថាអាហ្នឹងយើងមកពីអាំងភ្លើងអាំងអីអញ្ចឹ

ងទៅណាស់តែបើខ្មែរវិញអត់ទេមកពីយើងហ្នឹងកូនខ្ចី នោះមួយនោះកូនធំលង្ហតដែរនោះ!

ក:អង្គុយនៅខាងមុខផ្ទះរាល់ថ្ងៃ?

ខ:ហ្នឹងៗអង្គុយនៅមុខផ្ទះរហូតវាមានកូនខ្ចីវាមានអ្នកណាគេនឹងមើលហើយប្តីមិនដឹងនៅឯណាអីឯណាអត់មានប្តី

អត់មានសីផងបានកូនមួយហើយអត់បងចេះតែយកបាយមកឲ្យស៊ីទៅហើយនៅតែម្នាក់ឯងឆ្លតមានដឹងអីនៅតែ

លើកផ្ទះហ្នឹង។

ក:ហ្នឹងហើយឃើញដើរប៉ុន្មានថ្ងៃហ្នឹងឃើញដើរមកឃើញអង្គុយខាងមុខផ្ទះរហូត!

ខ:អង្គុយតែនៅទីហ្នឹងនិងកាំជណ្តើរកាំជណ្តើរទើបតែគេធ្វើឲ្យទៀតទើបតែការធ្វើឲ្យមុនបោះឆ្នោត
ហើយខ្ញុំចេះតែ
ប្រាប់គេដូចបងថុលគេសមាគមៗចឹងណាស់គាត់មកនិយាយលេងជាមួយឪវាហៅខ្ញុំថាឥឡូវបងអើ
យបងបងឯង
អាណិតវាគ្នាអត់ម៉ែអត់ឪហើយរំពឹងតែបង
បងហ្នឹងឥឡូវចេះតែយកបាយមកអោយស៊ីអញ្ចឹងទៅហើយឥឡូវមានកាំ
ជណ្តើរឯណាឡើងអត់កាំជណ្តើរឡើងទេដាក់បាវស៊ីម៉ង់ត៍ឡើងឡើងលើផ្ទះណាស់!ហ៊ីអញ្ចឹងគេធ្វើ
អោយបាន
ប៉ុណ្ណឹងទេ។

ក:បានអង្គុយ!

ខ:បានអង្គុយនៅតាមជណ្តើរនិងទៅ!

ក:ហ៊ីអាណិតគាត់ណាស់អ៊ំ។

ខ:ឥឡូវមានស្អីគេគេយកមកឱ្យស៊ីទៅ!ចាំតែស៊ីទេតើ!

ក:ផ្ទះនៅផ្ទះរបស់គាត់ដែរទេ?

ខ:ផ្ទះរបស់វាផ្ទះរបស់វាផ្ទះដីវា!

ក:ចាំអញ្ចឹងអ៊ំដល់ពេលបងប្អូនរបស់អ៊ំឥឡូវនៅសល់តែ 2 នាក់ទេ?

ខ:នៅសល់តែ 2 នាក់ទេ!

ក:អញ្ចឹងអ្នកដែលអ៊ំស្គាល់ត្រកូលដូចអ៊ំទាំងអស់?

ខ:ចាំ!

ក:ទាំងអស់គ្នា?

ខ:ចាំទាំងអស់គ្នា។

ក:ហើយដល់ពេលអ៊ំមែនស្លាប់ទៅគាត់ធ្វើការអីវាទៅវិញមុនពេលគាត់ស្លាប់ទៅ?

ខ:បងរបស់ខ្ញុំធ្វើប្រែធ្វើភ្ជីអត់មានធ្វើអីទេកូនកូនចេះតែចិញ្ចឹមទៅណាស់
កូនកូនវាដាំដំណាំដាំអីអញ្ចឹងធ្វើស្រូវធ្វើអី

លក់ស្រូវចាយនៅម្តុំហ្នឹងគេលក់តែស្រូវចាយទេ

កន្លែងធ្វើអីឲ្យធំដុំទេហើយដំណាំកែ្បមាត់ស្ទឹងហ្នឹងណាស់អញ្ចឹងដាំ

ដំណាំដាំអីអញ្ចឹងទៅបានទៅយកទៅលក់អោយចឹងទៅ!ក:ចា៎!ខ:ធ្វើអីទេវានោះ!

ក:ហើយដល់ពេលបងស្រីនៅទីនេះ?

ខ:បោចរពាក់។

ក:បោចរពាក់ធ្វើបង្គី?

ខ:បោចរពាក់ធ្វើបង្គី។

ក:ប៉ុន្មានឆ្នាំហើយអ៊ំចូលធ្វើបង្គីហ្នឹង?

ខ:គាត់ធ្វើយូរហើយតាំងពីមកនៅមកមកពីស្រុកទន្លេមកមានប្តីនៅស្រុកទន្លេណាស់នៅឬស្សីស្រុក

ដែលវាមកទិញដី

នៅបើនៅនឹងថ្ម៎ល់ដាច់នឹង!ឥឡូវបានធ្វើផ្ទះធំរបស់វាហើយអស់ហើយចាក់ខាងក្រោមដាក់ក្រោមដា

ក់អីអញ្ចឹង!ធ្វើ

អោយអស់ហើយឥឡូវវាធ្វើបង្គីហ្នឹង

កូននោះឲ្យធ្វើទេថាម៉ែឯងទៅធ្វើអីទៅបោចយធ្វើអីម៉ែឯងមិនបាច់ទេ!ម៉ែឯង

មើលតែផ្ទះនៅតែផ្ទះដើម្បីអីដាំបាយហូបទៅបានហើយ!អញ្ចឹខ្ជិលនៅណាស់!វាអត់ចៅនោះ!ក:ចា៎

!ខ:ដល់អញ្ចឹ

ងវាចេះតែបោចៗទៅជាមួយគេ។

ក:តាមពិតមែនហ្នឹងអ៊ំដល់ពេលបើសិនជាអត់មានអីធ្វើនៅផ្ទះ!

ខ:អញ្ចឹមនឹងលុយពួកង៉ែងទេពិបាកណាស់ថាអញ្ចឹពិបាកចាយណាស់អញ្ចឹចាយលើខ្លួនអញ្ចឹវិញ! ថាចឹងហិ!

ក:ហេមួយថ្ងៃមួយថ្ងៃជំនាញរបស់គាត់ចេះឃ្យរហើយមួយថ្ងៃមួយថ្ងៃបានតែ៦អ៊ំហ៎?

ខ: ច្រើនណាស់លក់ម្តងម្តងសុទ្ធតែ10ម៉ឺន 20ម៉ឺនឯណោះ!លក់ម្តងម្តង 20ម៉ឺនដប់ម៉ឺន 15ម៉ឺន!

ក:គេមកយកដល់ផ្ទះអ៊ំ?

ខ:មកយកដល់ដល់ផ្ទះអត់បាច់យើងទៅលក់ឯណា។

ក:ស្រួលហើយអញ្ចឹងនោះ!មានមុខរបរមួយហើយរពាក់មានអីទៅពិបាកអីអ៊ំហ៎គ្រាន់តែបន្តាហី?

ខ:គ្រាន់តែបន្តា មីអូនឯង
បើខ្ញុំវិញណាស់បោចមុតទាំងអស់តែលុបមុខអញ្ចេះលោកមិនចង់កើតផង!មាននៅក្នុង អាចុងបន្តិចបន្តិចនោះហើយយើងបោចទៅចេះតែបោចទៅ!

ក:អ៊ំទៅដល់មុនដំបូងដាក់កាំបិតហើយបានទាញវាមកលេះៗអញ្ចឹងទៅ?

ខ:ចា៎!យើងកាត់ចុងវាអញ្ចឹងទៅមកកាន់កាន់ហើយបានលះ

លះវាឲ្យស្អាតហើយទាញមកបានយើងកាប់វានឹង

ប្រវែងមែនអីប្រវែងប៉ុន្មានយើងទៅកាត់គល់វាមកបានយើងលះវាទៀតទៅ។

ក:ចា៎ហើយបើសិនជាកាប់វាអញ្ចឹងរាល់ថ្ងៃវាយ៉ាងម៉េចវាលូតអោយទាន់ទៅ?

ខ:ហឺ ឲ្យតែពូកែរកវាលត្បូងអត់ចេះខ្វះទេមីអូនទៅមើលម្ដុំស្រែអ៊ុំឥវ៉ាន់នោះ រពាក់ឡើងសត្រុប

ឡើងចង់នេះហើយ

ឡើងចង់ដល់ស្រែហើយ អ៊ំហ្អែងថាកាប់ៗ

ថាស្ការចេញអត់អត់នៅហ្នឹង!ខ្វះអីនៅខាងត្បូងឯណោះណែង។ ទាំងនេះ

គឺធ្វើដែរនោះវាទៅឃ្វាលគោអញ្ចឹងវាទៅបោចមកធ្វើបានមួយអញ្ចឹងទៅ។

ក:គ្រប់គ្រាន់សម្រាប់ទិញអីហូបអញ្ចឹងទៅអ៊ំណោះ?

ខ:ចា៎!

ក:អញ្ចឹងអ៊ំដល់ពេលនៅក្មេងក្មេងឡើយពេលអ៊ំរស់នៅតូចតូចនឹងណាស់លេងអីគេខ្លះជាមួយបងប្អូ

នដែលអ៊ំស្គាល់

នឹងមក?

ខ:លេងជាមួយគ្នានេះដែរបាយឡុកបាយឡឡេងល្បែងអីស្អីក្រៅពីនេះអញ្ចឹងទៅជួនកាលទៅជ

ញ្ជាត់អញ្ចឹងទៅពីរ

នាក់បងប្អូនទៅជញ្ជាត់

មីមួយនៅនេះនឹងនៅថ្ងល់ដាច់នឹងទៅជញ្ជាត់ពីរនាក់បងប្អូននៅមាត់ស្ទឹងហ្នឹងបេះដៃត្រគៀត

បេះអីអញ្ចឹងមកបានខ្យងបានខ្ចៅអញ្ចឹងមកយកមកស្ងហុបអញ្ចឹងទៅ។

ក: ឆ្ងាញ់ណាស់!

ខ:ចា៎ អត់មានថាដែលលេងហើយដល់តែទៅជញ្ជាត់អញ្ចឹងទៅបេះកំប្លោកនឹងយកមកលេង

បេះកំប្លោកនិងយកមក

ធ្វើលេងអញ្ចឹងទៅមកលេងតែពីរនាក់បងប្អូនទៅ ។

ក:អើរហើយទឹកអត់ជ្រៅអត់អីទេដែលតើអ៊ំហ៎?

ខ:ទឹកត្រឹមករ អាកណ្តាលលិចក្បាលទៅ។

ក:ប៉ុន្តែអត់ហ៊ានទៅដល់ជ្រៅទេ?

ខ:អត់ទេ!ជញ្ជាត់តែខាងខាង ក្បែរខាងខាងទេ!

ក្បែរក្បែរខាងយើងមានស្មៅយើងមានអីអញ្ចឹងទៅមានត្រគៀតអីអ

ញ្ចឹងទៅណាស់ ជញ្ជាត់ទៅ។

ក:បានត្រីកំពឹសណាយគ្នា!

ខ:បានលាយគ្នា!អញ្ចឹងយើងជ្រងរនាមទៅបានត្រីកំភ្លាញ

កន្ត្រៃបអីអញ្ចឹងទៅតែពីរនាក់បងប្អូនខ្ញុំហ្នឹង។

ក:ចាំសម័យមុន!

ខ:ហាត់ហើយមានឈ្លោះគ្នាអត់ដែលមានប្រកែកគ្នាអត់រលីង តែខ្ញុំទេខូចជាងគេ

ខ្លាចបងបងរបស់ខ្ញុំខ្លាចខ្ញុំបាច់។

ក:ទៅអញ្ចឹងវិញទៅហ៎?

ខ:ចាំខ្លាចខ្ញុំខ្លាចអញ្ចេះអោយតែដើខ្ញុំខ្ញុំទូពិតប្រាប់ម៉ែឪនោះ

អញ្ចឹងម៉ែហើយឪគាត់ស្រលាញ់គាត់ហ៊ានេះទេ!កុំដើ

កូនពៅអញ្ចឹយ!ហៅតែពៅពៅទេឈ្មោះអត់ដែលហៅចំឈ្មោះទេ

តែបងខ្ញុំបង្កើតមីមួយនៅខ្វាន់មាសនិងណាស់

មិនដែលហៅខ្ញុំទូចមួយម៉ាត់ទេ មួយនេះហើយខ្ញុំទូច 1

បងគេបង្អស់និងតែពៅពៅទេហៅខ្ញុំតែពៅពៅទេ។

ក:

ដោយសារទៅគេ!ខ:ចាំ!ក:ដោយសារពេលហ្នឹងអ៊ុំជញ្ជាត់ត្រីឥ៉ាន់ពេលឥឡូវក៏អត់សូវមានដែរអ៊ុំ

ហ៎?

ខ:ហ្ម៎ បើគេទៅជញ្ជាត់បានមីអូន

តែឥឡូវបច្ចុប្បន្នឥលូវនេះអូនឯងដឹងស្រាប់ហើយស៊ីតែស្រាប់ស្រាប់លុយមាន

លុយធ្វើការហ្នឹងហើយមកហើយគេមិនទៅជញ្ជាត់អីកាលពេលមុនអ៊ុំទៅ ជញ្ជាត់ដែរទេតើ

អ៊ំនៅទីហ្នឹងហិ សួរអ៊ំ

មើលទៅកន្លះៗឆ្នាំងហិ!ទន្លេបាទី។

ក: ទៅជញ្ជាត់និងទន្លេហ្នឹង?

ខ:នៅទន្លេនិងកន្លះកន្លះឆ្នាំងសួរអ៊ុំមើល!

ក:មានត្រី មាន កំពឹសមានខ្យងមានក្តាមអញ្ចឹងទៅអ៊ំហ៎?

ខ:ហ្នឹងហើយមួយចប់!ខ្យងក៏យកក្តាមក៏យកស្ទឹកក៏យើងដែរ។

ក:អាហ្នឹងស្តរឆ្ងាញ់ណាស់អ៊ំអើយ!

ខ:ចា៎ស្តរឆ្ងាញ់ណាស់បេះដៃត្រកៀតមក ដកក្រអៅឈូកមកស្តរមួយឆ្នាំៗកូនហូបទៅហើយឥឡូវ

ម៉ែយ៉ាងម៉េចមិន

ទៅជញ្ជាត់

មីវណ្ណ៉ា!វាថាយ៉ាងម៉េចម៉ែមិនទៅជញ្ជាត់ទៀត?ទៅអោយឈ្លើងតោង!ឈ្លើងឡើងណែនទន្លេហើ

យ។

ក:ហ្នឹងហើយឥឡូវល្បីថាសុទ្ធតរឿង!

ខ:ហ៊ឺ!សុទ្ធតែឈ្លើងមីអូនអត់បានទេ!

ក:មុជអត់បានទេ?

ខ:ហេមុជធម្មតាអត់អីទេកុំអោយតែយើងនៅឃ្យរ។

ក:មកតែម្តង?

ខ:ឈ្លើងមកតែម្តងតែម្តុំនេះឪវាទៅត្រាំថាមកតែម្តងវ៉ាបៗៗរកមក លឿនណាស់មីអូនណាស់!

ក:អ៊ំខ្ញុំមិនដែលឃើញនៅក្រៅទេណាស់!

ខ:ចា៎!បងប្អូនរបស់ខ្ញុំអត់ចេះឈ្លោះគ្នាទេស្រលាញ់អ្នកស្រលាញ់ប្អូនណាស់សូម្បីតែជំនាន់ប៉ុលពត
ខ្ញុំឈឺណាស់ក
ដៃប៉ុនៗដងដែក ឈឺទៅចុះយើងនៅកងកុមារនោះដឹងខ្យល់អីនៅតូចតូចមកផ្ទះនឹងនិយាយពី
ផ្គត់ផ្គង់ម្ហូបអាហារអោ
យស៊ី ហើយបាយកាលពេលហ្នឹងគេអោយមួយចឹបៗហ្នឹង
គេឲ្យមួយចឹបៗហើយនិងឪហើយម៉ែគាត់ចាស់ចាស់

ហើយហ្នឹង

គេអោយមកមួយកូនឆ្នាំងប៉ុណ្ណឹងមកហូបខ្លះទៅទុកឲ្យយើងខ្លះទៅគេអត់អោយស៊ីទេណាស់យើង

មក

យើងមកកងកុមារគេឲ្យស៊ីទេមីអូនណាស់ គេអត់ឲ្យស៊ីទេ ស៊ី

ជាមួយម្តាយឪពុកហ្នឹងទៅបងខ្ញុំធ្វើអង្ករធ្វើអីអញ្ចឹងទៅ

វាដាក់អង្ករនៅក្នុងហៅប៉ោអីអញ្ចឹងមកដាំបាយនៅក្នុងកុំសៀវណាក់ទៅណាស់អត់ហ៊ានដាំអោយ

ឃើញទេ គេឃើញ

គេចាប់យកទៅវ៉ៃចោលងាប់ណាស់មីអូនណាស់

អត់បានទេថាខ្ញុំប្រាប់ថាកំសត់គឺកំសត់ហើយខ្ញុំប្រាប់ទៅ!នៅនេះ

ន៊ឹង!

ក: ជំនាន់សង្គ្រាម។

ខ:ប៉ុន្តែបងប្អូនទាំងអស់អត់ចេះ

ខឹងគ្នាអត់ចេះឈ្លោះគ្នាអីទេបងប្អូនរបស់ខ្ញុំស្រីស្រីហ្នឹង!ស្រួលណាស់។

ក:ហើយអ៊ំស្រីដល់ពេលម្តាយអ៊ំស្រីគាត់ឈ្លោះអីគេទៅវិញ?

ខ:ឈ្លោះយាយមុត។

ក:អីគេមុតទៅវិញ?

ខ:ទេមិនដឹងទេជីតាមិនដឹងឈ្មោះអីទេនេះ!គាត់នេះឪក៏អត់ស្គាល់ជីតាដែរ!

ក:គាត់អត់ប្រាប់!ប៉ុន្តែដល់ពេលក្នុងសំបុត្រកំណើតគឺវ៉ាន់មានទេ?

ខ:អត់!

ក:អត់អត់ដឹងតែឈ្មោះយាយមុតតែមួយទេ?

ខ:ចា៎!យាយមុតហើយនិងតាញានហ្នឹង!

ក:ចា៎ឪពុកឈ្មោះញាន។

ខ:ខ្ញុំដាក់ខ្ញុំដាក់ត្រកូលឪពុកទេតើបើខ្ញុំអត់ស្គាល់ជីតា!

ក:ចុះត្រកូលនិយាយទៅទាំងខាងឪទាំងខាងម៉ែក៏អត់ស្គាល់ទាំងពីរ?

ខ:អត់!ឃើញខ្ញុំដាក់ត្រកូលឪទេ!

ក:ហើយម៉ែហើយនឹងឪក៏អត់ដែលប្រាប់ទៀត?

ខ:អត់!គាត់ឈឺលែងចង់ទៅដូចថាយើងកាលពេលកងកុមារដូចមានបាននៅផ្ទះឯណាបើគេឲ្យយើងធ្វើរហូតហ្នឹង

ដែកដីដំបូករហូតហ្នឹង!ដែកដីដំបូករកជីអត់អោយនៅផ្ទះទេមីអូនណាស់!យីបើបាននៅផ្ទះអញ្ចេះងាប់ហើយ ។

ក:ហើយអ៊ំដល់ពេលយាយទូចឥឡូវគាត់នៅរស់រឺក៏អីអត់?

ខ:យាយទូចណា?

ក:ម៉ែរបស់អ៊ំ!ហ៎ាយាយមុត។

ខ:ម៉ែរបស់ខ្ញុំគាត់ស្លាប់តាំងពីយើងបែកប៉ុលពតមីអូនណាស់
បែកអាពតធ្វើស្រូវបានមួយឆ្នាំបានមួយឆ្នាំចឹងទៅគាត់ក៏
រាគណាស់ គេ
ហៅថាអាសន្នរោគណាស់ហើយកាលពេលនោះមិនទាន់មានពេទ្យមានអីឯណាទៅគាត់សម្រាន្ត
សម្រាន្តទៅខ្ញុំក៏គាត់ក្រោកងើបក្រោកងើបខ្ញុំថាម៉ែម៉ែឯងថី? រាគ
ហើយអញ្ចឹងរត់រកពេទ្យទៅរកឯណារកឯណាមាន
អញ្ចឹងទៅក៏មួយភ្លែតរាគៗៗៗហើយដៃអស់រលីងដូចនៅកន្លែងនេះអញ្ចឹងណាស់ឡើងស្លេកគាំង
ទៅណាស់រត់រក
ពេទ្យឯណាក៏គេអត់នេះដែរ។មិនដឹងមានពេលឯណាបើអត់!ស្លាប់មួយភ្លែតហ្នឹង!

ក:ចា៎!អាសន្នរោគ!

ខ:ហ្នឹង!

ក:បែក មកបានមួយឆ្នាំ?

ខ:ម៉ោងប្រហែលម៉ោង៥។

ក:អញ្ចឹងគាត់ស្លាប់ 1980 គត់អ៊ំហេ?

ខ:ចា៎!យើងបែក។

ក: ហើយអាយុយាយប៉ុន្មានដែរពេលហ្នឹង?

ខ:អាយុម៉ែរបស់ខ្ញុំ 56 57។

ក:ស្លាប់ហ្នឹង?

ខ:ចា៎!

ក:ហើយស្រុកកំណើតយាយនៅឯណាទៅវិញ?

ខ:នៅទាំងឬស្សី។

ក:នៅឯណាទៅវិញឯហ្នឹង?

ខ:ទាំងឬស្សីហួសថ្ម ល់ដាច់បន្តិចមកទាំងឬស្សីហ៎!

ក:នៅតាកែវយើងដែរ?

ខ:ហ្នឹង។

ក:នៅស្រុកបាទីយើងដែរ?

ខ:នៅស្រុកបាទីខេត្តតាកែវដូចតែគ្នាហ្នឹងណាស់។

ក:ហ្ន៎!ហើយពេលហ្នឹងយាយគាត់ឆ្នាំអីគេទៅវិញឆ្នាំខ្លែរណាស់ ជូតឆ្លងខាលថោះអី?

ខ:មិនដឹងឆ្នាំអីទេម៉ែបើបងខ្ញុំក៏ចាំតែខ្ញុំអត់ចាំ!តែម៉ែខ្ញុំប្អូនអោយខ្ញុំប៉ុន្មានពីឆ្នាំ!ប្អូនរបស់ឪ 2 ឆ្នាំ!

ក:ម៉ែប្អូនឪពីឆ្នាំ?

ខ:ច៎ា។

ក:មើលអ៊ំប្រាប់ពីជីវិតរបស់ម្តាយបន្តិចមើលតើគាត់ជាមនុស្សយ៉ាងម៉េចដែរ?តាំងតែពីអ៊ំដឹងក្តីរស់នៅជាមួយគាត់

ណាស់?

ខ:បើម៉ែវិញគាត់កំសត់ណាស់តាំងតែពីតូចមក

គាត់រ៉ាប់រងប្អូនប្អូននៅតូចតូចនោះណាស់បងប្អូនគាត់ណាស់បងប្អូន

គាត់តូចតូចនឹងគាត់កំសត់តាំងតែពីដើមមក!គាត់មិនសូវរាងដូចថាមិនក្រមិនមានមធ្យមមិនក្រមិន

មានមិនអត់អី

ហូប គាត់ម៉ាចិញ្ចឹមប្អូនអត់មានខ្វះខាតអីទេចំពោះគាត់។

ក:ហ្នឹងយាយហ៎?

ខ:ហ្នឹងយាយ។

ក:ត្រូវជាម្តាយរបស់អ៊ំ យាយមុត។

ខ:ចា៎យាយមុតបើតាញានហ្នឹងគាត់តែម្នាក់ឯងគត់!ម្តាយគាត់មានតែមួយមានតែគាត់មួយហ្នឹងតែ

ម្តង គាត់ហ្នឹងក៏

កំសត់ដែលគាត់មានប្រពន្ធមុនគាត់បានកូនពីរ

ដល់ហើយគាត់បានមកស្តីម៉ែរបស់ខ្ញុំនឹងទៅស្តីម៉ែខ្ញុំបានកូនច្រើន។

ក:12!

ខ:12កូន!តែគ្រាន់តែអត់នៅ!នៅសល់តែបីនាក់ហ្នឹង!

ក:អុញ!អាំមើលសួរបកក្រោយបន្តិចទៅមើលបងប្អូនអាំ6

នាក់ទៀតដែលគាត់ស្លាប់ថីបានស្លាប់អស់រលីងចឹង?

ខ:តាំងតែពីតូចតូចឯណោះ!កើតហើយដូចខាងកើតបាន 10 ថ្ងៃដូចថាបានមួយខួប 2

ខួបៗចឹងទៅណាស់ វា

ឈឺទៅថាយើងកាលពេលហ្នឹងថ្នាំសង្កូវមានដូចថាស្លឹកឈើស្រុកព្រៃឱ្យបុកអោយហូបអោយអីអញ្ចឹ

ងទៅណាស់!

ឈឺស្លាប់ឈឺស្លាប់អញ្ចឹងទៅណាស់!

ក:ហើយចុះដល់ពេល 9 នាក់ស្លាប់សុទ្ធតែអញ្ចឹងទាំងអស់អ៊ុំហេ?

ខ:ចា៎!

ក:ហើយមិនមែនមកសង្គ្រាមមកអីឯណាហេ?

ខ:អត់ទេអត់ទេអត់មានអីទេ!

ក:ពេលហ្នឹងស្រុកនៅស្រួលបួលនៅឡើយទេ!

ខ:នៅស្រួលបួលនៅឡើយទេ អត់អីទេ។

ក:ស្តាប់មកបន្តរហូត ។

ខ:គាត់ដូចថាគាត់អត់គង់ណាស់ គង់ដែលត្រឹមបងរបស់ខ្ញុំ 1

ស្តាប់នៅខ្វាន់មាសហ្នឹងហិ!មកគង់តែត្រឹម

ហ្នឹង!

ក:ងាប់អីក៏ម៉ែះម្ល៉ះ!ចិញ្ចឹមកូនដោយរបៀបថាគាត់អត់កបជាមួយកូនឡើង 9នាក់!

ខ:ច្រើនមិនដឹងប្រុសប៉ុន្មានស្រីប៉ុន្មានតែគាត់ថា 9នាក់!

ក:ហើយពេលហ្នឹងយាយទូចចក៏ទុកធ្វើស្រូវធ្វើអីដែរ?

ខ:យាយមុត។

ក:យាយមុតយាយមុត ហ្នឹងហើយ។

ខ:គាត់ធ្វើប្រែធ្វើអីអញ្ចឹងទៅដាំដំណាំដាំអីអញ្ចឹងទៅគ្រាន់ចិញ្ចឹមជីវភាពអញ្ចឹងទៅណាមីអូនណាស់នឹងហើយ!

ស្រួវនិងយើងធ្វើបានច្រើនអញ្ចឹងទៅលក់ដូរអីគ្រាន់ទិញម្ហូបទិញម្ហាហូបអញ្ចឹងទៅវាបើថារឿងមានដូចថាដូចគេអីអត់

មានទេ!មធ្យម។

ក:ចា!ហ្នឹងហើយហើយអញ្ចឹងអ៊ំដល់ពេលប៉ុន្តែគាត់អត់កាចឯណាហីហី?

ខ:ម៉ែខ្ញុំស្លូតណាស់ឪខ្ញុំគាត់ស្លូតដែរអត់ដឹកូនដឹអីយ៉ាងម៉េចទេអត់!ស្លូតណាស់។

ក:ហើយគាត់គឺជាមនុស្សយ៉ាងម៉េចដែរដឹងថាគាត់ស្លូតហើយប៉ុន្តែគាត់រកស៊ីអីគេខ្លះអញ្ចឹងទៅណាស់?

ខ: គាត់ជួយគោជួយធ្វើប្រែធ្វើអីចឹងទៅ គោរបស់គាត់ដូចថាគាត់លក់ចេញអញ្ចឹងទៅ
ដល់ពេលគាត់ទៅទិញវិញអ
ញ្ចឹងទៅចំណេញខ្លះអញ្ចឹងទៅយកមកម៉ែអញ្ចឹងទៅម៉ែធ្វើ
ស្រែធ្វើអីអញ្ចឹងទៅគាត់ភ្ជួរអីអញ្ចឹងទៅណាសមីអូនណា
ស់។

ក:ហ្ន៎ជួញគោ!

ខ:តែតាមខ្ញុំដឹងខ្ញុំដឹងតិចតិចទេព្រោះថាយើងនៅតូចៗ!

គ្រាន់តែបែកចូលប៉ុលពលពតភ្លាមយើងចូលកងកុមារភ្លែត !គេឲ្យនៅកងកុមារ
គេអត់អោយនៅផ្ទះទេ។

ក:ហើយដល់ពេលឪ គាត់ស្លាប់ដោយសារអីគេ?

ខ:ឪរបស់ខ្ញុំចាស់តែម្តង ចាស់ជរាគាត់ចាស់ជរា។

ក:តែពេលហ្នឹងក្នុងឆ្នាំណាទៅ?ហើយប៉ុលពតឬក៏មុនប៉ុលពតអ៊ុំ?

ខ:បែក!

ក:បែកហើយ?

ខ:បែកហើយតែនៅទន្លេងណោះ មានស្លាប់នៅស្រុកនេះឯណា!

ក:អញ្ចឹងសង្គ្រាមចប់ហើយបានជាគាត់ស្លាប់?

ខ:ចាំ!

ក:ទាំងម្តាយទាំងឪស្លាប់?

ខ:ចាំ!ឪរបស់ខ្ញុំស្លាប់មុនបានម្តាយរបស់ខ្ញុំនៅមកឯស្រែបានស្លាប់នៅឯស្រែឯណោះ។

ក:អញ្ចឹងមានន័យថាស្លាប់បែកប៉ុលពតភ្លាមបានគាត់ស្លាប់ភ្លាមឬក៏យ៉ាងម៉េច?

ខ:ថ៎!

ក:អញ្ចឹងឆ្នាំ 1979 ឪស្លាប់?

ខ:ថ៎!

ក:គាត់អាយុប៉ុន្មានពេលនឹងអ៊ំចាំដែរឬទេ?

ខ:ឪ 60!

ក:60ហើយហេ!

ខ:ម៉ែ 52!

ក:ហ្នឹងហើយ!ដល់ពេលអញ្ចឹងទៅក៏!តែអម្បាញ់មិញអ៊ំប្រាប់បងប្អូនគ្នា 2 ឆ្នាំតែគម្លាត!ហ្ន៎!ត្រូវហើយ។

ខ:ត្រូវហើយ!គាត់បង បងម៉ែ។

ក:ចាំ គម្លាតគ្នាអញ្ចឹងទៅ ។

ខ:គាត់ឈឺគាត់គ្មានដើរទៅឯណារួចដល់ពេលគាត់ឈឺទុរន់ទុរា គាត់មានដើរទៅណារួច
កាលពេលបែកហ្នឹងពិបាក
ផទនាកាលពេលនិងវៀតណាមចូលនោះយើងបែកប៉ុលពតវៀតណាមចូលស្រាប់តែនៅលើគ្រែ
សោះស្រាប់តែគ្រាន់
តែភ័យគាត់ដើរព្រឹល ដើរលឿនខ្លើត ទៅមុនកូនកូនបាត់ហើយបងរបស់ខ្ញុំលីទៅផ្ទះនៅទាំងឬស្សី
លីគាត់ទៅគាត់
តូចតែមួយហ្នឹង កតូចហើយទាប។

ក:ចាំ ឪហ្នឹង?

ខ:បើម៉ែខ្ពស់ធំមាឌធំ ។

ក:ទៅអញ្ចឹងវិញទៅ?

ខ:ហ្នឹង បើឪតូចតែម្តងមាឌតូចតែម្តងណាស់តូចជាងតាទៅទៀត!មាឌល្អិត!

ក:លឺថាពេលភ័យទៅហើយអ៊ំហៅ?

ខ:ភ័យទៅហើយដើរទៅបាត់រកឪរកអត់ឃើញ

ស្រាប់តែដើរទៅបាត់ដើរទៅបាត់នាំគ្នាមានបានយកស្អីៗ ស្អីៗក៏អត់

ដែរអីក៏អត់ដែលខ្ញុំវិច តែឆ្នាំងចានក៏អត់បានដែរបានតែបងស្រីហ្នឹងទេ

ទូលឆ្នាំងទូលរចានហើយពោះធំផង ខ្ញុំឯណោះ

ដឹកដៃក្មួយក្មួយហ្នឹង បងខ្ញុំជួយដឹកខ្លះទៅ ខ្ញុំជួយដឹកខ្លះទៅមានបានយកស្អីស្អី

ស្អីក៏អត់ដែរនៅក្នុងរទេះទាំងអស់គេ

ចាប់បងថ្លៃទៅបាត់ទៅនោះ គេចាប់បងថ្លៃកាលហ្នឹងវៀតណាមចាប់ណាស់

គេថាយើងអាពតណាស់គេចាប់យកទៅ

រៀនសូត្រនៅរោងចក្រកែវហ្នឹង ។

ក:ថ៎!ឲ្យកែប្រែចរិកអីវ៉ាន់ទៅអ៊ំហេ?

ខ:ថ៎! ហ្នឹងហើយអោយយកទៅកែប្រែរាងនេះទៅ!

ក:ប៉ុន្តែតាមពិតអត់ទេ?

ខ:អត់ទេ នៅរៀនទីហ្នឹងតែម្តង នៅរៀននៅឯរោងចក្រកែវហ្នឹងតែម្តង។

ក:ហ្នឹងហើយប៉ុន្តែគាត់មិនមែនខាងអាពតទេអ៊ំហេ?

ខ: អាពតស្អី!

ក:ប្រជាជនធម្មតាធ្វើការ!

ខ:ធម្មតាដាំដំណាំដាំអី ចិញ្ចឹមមាន់ចិញ្ចឹមទាហូបអីហ្នឹង គាត់អត់មានធ្វើអីទេ។

ក:អញ្ចឹងអ៊ំដល់ពេលឪពុកអ៊ំ គាត់ជាអ្នកជួញគោហើយស្រុកឪនៅឯណាទៅវិញ?

ខ:ស្រុកឪរបស់ខ្ញុំនៅហ៊ីថាជិតជិតគ្នាដែរហ្នឹង នៅស្អីគេហៅភូមិអីគេទេភូមិតាប៉ុក
ភូមិតាប៉ុកហ្នឹងហួសពីខ្ញុំមកណាស់
ហួសពីខ្វាន់មាសមកគេហៅភូមិតាប៉ុក ។

ក:ប៉ុន្តែភូមិខ្វាន់មាសហើយនឹងភូមិហ្នឹងនៅក្នុងខេត្តកណ្តាលឬក៏ខេត្តតាកែវ?

ខ:ខេត្តតាកែវ!

ក:ខេត្តតាកែវហេ!

ខ:ខេត្តតាកែវតែទាំងអស់ហ្នឹង!ម៉ាស្រុកបាទីខេត្តតាកែវទាំងអស់។

ក:ចា៎ៗ ស្រុកបាទីនិងដែរ!

ខ:ចា៎!

ក:អ៊ំមានចាំកន្លែងជាមួយឪជាមួយម៉ែជាងគេទៀតឬអត់?

ខ:អត់!

ក:អត់សូវចាំចំនុចកន្លែងណាពិសេសអីទេហេ?

ខ: អត់អត់ពីព្រោះខ្ញុំ ពេលគេអត់បានអត់បានចាំទេមីអូនណាស់!

ក:ចុះអ៊ំដល់ពេលចំណុចដូចជាជំនាន់ដើមមកម៉ែឪប្រដៅអ៊ំអីវ៉ាន់ប្រដៅបងប្អូនយ៉ាងម៉េចដែរពេលគាត់នៅតូចតូចអ

ញ្ចឹងទៅណាស់ដោយសារម៉ែឪត្រូវតែអញ្ចឹង?

ខ:គាត់ប្រដៅកុំអោយយើងដើរលេងទៅឯណាឆ្ងាយខ្លាចលង់ទឹកខ្លាចអីអញ្ចឹងទៅយើងចេះតែប្រដេរប្រដៅទៅរៀន

ទៅសូត្រទៅណាស់!តែខ្ញុំរៀនបានតិចណាស់រៀនឯណាដល់អញ្ចឹងទៅស្រុកបែកនេះអញ្ចឹងទៅសង្គ្រាមអញ្ចឹងទៅ

មានបានរៀនទេ មានបានរៀនសូត្រទៀតអីនឹងគេ។

ក:មួយៗគិតតែពីគេច។

ខ:គិតតែពីរត់តែម្តងបងរបស់ខ្ញុំបានរៀនខ្លះបើខ្ញុំអត់បានតែម្តង
រៀនបានតែពីរបីថ្ងៃអញ្ចឹងទៅស្រុកចឹងទៅលេងបាន
រៀនរហូតរត់ទៅទន្លេទៅទន្លេទៅរៀនបានតែ 3 ថ្ងៃ 4 ថ្ងៃឈប់ទៀតទៅ ។

ក:ហ្ន៎!អញ្ចឹងពេលដែលវ័យអ៊ុំចូលរៀនហ្នឹង!

ខ:ចេះតែរកនេះរកនោះជួយបងអញ្ចឹងទៅណាស់
ដើរអើសខ្យងអើសខ្ចៅអញ្ចឹងទៅនៅស្រុកទន្លេយើងស្រួលណាស់
កាច់ពោតទឹកអីអោយគេអញ្ចឹងទៅបានលុយបានអីអញ្ចឹងទៅណាស់!

ក:ទន្លេនិងនៅឯណាទៅវិញអ៊ំ?

ខ:ឬស្សីស្រុក។

ក:ភូមិឬស្សីស្រុកហ្នឹងទៅ?

ខ:ហ្នឹងហើយចា៎!

ក:នៅខេត្តកណ្តាលយើងដោយសារ

ខ:ខេត្តកណ្តាលអាហ្នឹង!

ក:ហ្នឹងហើយ!

ខ:យើងហួសផ្សារតាខ្មៅបន្តិចទៅឯកើតទៅ!

ក:ហ្នឹងហើយស្គាល់ហើយ!ទៅខាងកៀនស្វាយទៅអីឯណោះអ៊ំហេ?

ខ: អត់ដល់ទេ។

ក:អត់ដល់ទេ។

ខ:នៅឬស្សីស្រុកនេះទេ។

ក:ចា៎ អញ្ចឹងអ៊ុំគាត់ ចេះតែទូន្មានប្រៀនប្រដៅអ៊ំអោយល្អរៀងខ្លួនៗចឹងទៅអ៊ំណោះ?

ខ:ចា៎ៗ!

ក:ហ្នឹងហើយ!

ខ:អត់មានថាហ្ន៎កូនដើរទៅឯណាមានគិតមានគួរគាត់ប្រដៅប្រដៅថាកុំអោយយើងដើរលេងឆ្ងាយ
អីអញ្ចឹងទៅណា
ស់។

ក:ចា៎!ហើយអ៊ំ អ៊ំដល់ពេលរៀនអត់បានរៀនហើយរៀនបានតែពីរបីថ្ងៃឈប់រៀន
រៀនបានពីរបីថ្ងៃឈប់រៀនអញ្ចឹ
ងទៅ?

ខ:ចា៎។

ក: អញ្ចឹងពេលរៀនគេអោយចូលរៀននៅសាលាណាវិញអ៊ំ?

ខ:សាលាយើងនៅនេះនេះវត្តបិតមាសយើងហ្នឹង!វត្តចំបក់។

ក:វត្តចំបក់!

ខ:ចា៎!

ក:ចា៎នៅហ្នឹង!

ខ: រៀនបានតែ 4 ទៅ 5ថ្ងៃស្រុកយើងអញ្ចឹងទៅលែងបានរៀនទៅ។

ក:យ៉ាងម៉េចសាលាបិទខ្មែចខ្ទីតែម្តង?

ខ:បិទខ្មែចខ្ទីតែម្តង!

ក:មួយៗសុទ្ធតែរត់យករួចខ្លួនណាស់។ហើយដល់ពេលចូលរៀនអ៊ំមានតែពីក្មេងមកទោះតែមិនបានរៀនឬក៏បាន

រៀនតិចតួចអីរ៉ាន់ចឹងមែន តែអក្សរខ្មែរអានបានទាំងអស់ទេឥឡូវ?

ខ:អត់!

ក:អត់ចេះតែម្តងហេ?

ខ:អត់!

ក:ហើយចុះកូនអ៊ីវ៉ាន់ហើយប្តីបង្រៀនឬក៏អត់អញ្ចឹង?

ខ:អត់!

ក:អត់ចាប់អារម្មណ៍?

ខ:

អត់ចាប់អារម្មណ៍!ដូចថាយើងខំប្រឹងរកស៊ីទៅណាស់អូនណាស់ខំរកស៊ីអញ្ចឹងទៅយើងធ្វើយ៉ាងម៉េចយើងវា

អត់ចេះទៅហើយតែម៉ាអក្សរអត់ចេះតែអ្នកចេះចាញ់ខ្ញុំទេ!

ក:យ៉ាងម៉េចទៅអ៊ំ?

ខ:ខ្ញុំចេះគិតគូរមិនធម្មតាដែរហ្នឹងមិនដូចគេឯណានេះទេ គិតគូរខ្លាំងដែរហ្នឹងណាស់

បើយើងអត់ចេះអក្សរយើងចេះ

ដូចថាចេះតម្រិះយើងដូចថាយើងចាត់ទុកចេះដាក់អញ្ចឹងទៅណាស់។

ក:ហ្នឹងហើយ!

ខ:ហ្នឹងហើយ!

ក:ធម្មជាតិមកឆ្ងាតដែរប៉ុន្តែប្រសិនបើយើងបានរឿងទៀតក៏ល្អ!

ខ:បានរៀនទៀតក៏ល្អតែម្តងប៉ុន្តែវាអត់
វាអត់សោះតែម្តងនេះអូនណាស់បើស្រុកយើងបែកចឹងមកអ៊ំមានបានរៀនអី
បែកនេះមករហូតអញ្ចឹងរត់រហូតមានដែលបានមានពេលណាថាអត់រត់ទេ។

ក:អ៊ំដល់ពេលចឹងមានដែលមានក្តីស្រមៃថាធំឡើងចង់ធ្វើអីមួយឬក៏ជាធ្វើជំនួញអ្វីមួយនៅពេលក្មេង?

ខ:ពេលក្មេងវានឹកឃើញចឹងដែរប៉ុន្តែមីអូនអើយដូចថាយើងអត់ចេះៗចឹងយើងមិនអាចទៅរួច។ខ្ញុំនឹកឃើញតែក្នុង
ចិត្តទេណាស់ ថាអាចមិនអាចទៅរួចព្រោះយើងអត់ចេះចឹងយើងមិនដឹងគិតគូរថាយ៉ាងម៉េចណាស់
យើងអត់អាចទ
រួចបើថាដូចយើងចេះទៅយើងចេះតែនឹកឃើញចង់ណាស់
ចង់ធ្វើអីមួយចង់លក់ដូរអីអញ្ចឹងយើងចេះតំរិះដល់យើងអត់ចេះពិបាកចិត្តណាស់។

ក:ចា៎!

អត់ត្រូវបើកអីបើកអីកើតអ៊ំណេះ!ខ:ចា៎!ក:ហើយទោះបើសិនជាចង់ធ្វើគ្រូបង្រៀនគ្រូពេទ្យឥវ៉ាន់

ពិបាកទៀត!

ខ:ពិបាកយើងធ្វើយ៉ាងម៉េចទៅកើត!

ក:អញ្ចឹងដោយសារអង្ពែក វ័យកំពុងតែពេញរៀនគឺវ័យកំពុងតែពេញសង្គ្រាម !

ខ:វ័យកំពុងពេញសង្គ្រាម!

ក:ហ្នឹងហើយដោយសារអង្ពែក អ៊ំកើត 1964 ដល់ពេលចូលមកត្រឹម 6ឆ្នាំ
7ឆ្នាំត្រូវដល់វ័យចូលរៀនហើយ !

ខ:ចា៎!ក:ចូលមកដល់លន់ណុលចប់បណ្តោយ!

ខ:ចប់បណ្តោយ!

ក:រៀនក៏ !អ្នកខ្លះក៏បាន អ្នកខ្លះក៏សង្គ្រាមទៅដល់ពេលចូលប៉ុលពតទៀតស៊ប់ពេញតែម្តង !

ខ:ចា៎!

ក:អាអំឡុងពេលសង្គ្រាមគឺ 10 ឆ្នាំពី70 ដល់79(1970

1979)ចង់10ឆ្នាំហើយអ៊ំណោះ!

ខ:ថ៎!

ក:ហើយដល់ពេលបែកមកវិញក៏មិនអាចទៀត!

ខ:ក៏មិនអាចទៀតវាទៅលែងរួចទៅហើយ វាយើងធំហួសទៅហើយណាស់!

ក:ហ្នឹងហើយ!

ខ:វា!

អើរអាហ្នឹងជំទង់ពេញជំទង់ពេញក្រមុំទៅហើយហ្នឹង!វាពេញសាច់ពេញឈាមហើយយើងទៅរៀន

ឯណា

អាណា រៀនចូល។

ក:ហ្នឹងហើយ!

ខ:ដល់តែគេអោយរៀនអក្ខរកម្មនេះទៀត

នោះចេះតែដេញអោយទៅរៀន(ស្វាមីរបស់គាត់)ហ៊ីណែអើយខ្ញុំទៅមិន

រួចទេបានថាយើងគិតណាស់គិតវែងគិតឆ្ងាយអញ្ចឹងទៅទៅលែងរួចហើយបើយើងនៅវ័យក្មេងយើងអាចទៅរួចដល់

យើងវ័យចាស់មិនអាចទៅរួចទេ ខ្ញុំគិតខ្លួនខ្ញុំអញ្ចឹង។

ក:អញ្ចឹងនៅមើលកូនមើលចៅទៅអ៊ំ!

ខ:ខ្ញុំទៅមើលកូនមើលចៅទៅធ្វើយ៉ាងម៉េចបើអត់ចេះទៅហើយ ។

ក:ហើយអ៊ំដល់ពេលនេះវិញតាយាយអត់ទាន់បានសួរតាយាយទេ ខាងយាយទូច!

ខ:ខាងយាយញាន!

ក:យាយមុត!

ខ:យាយយមុត!

ក:ច្រឡំយាយទូចរហូត ដល់ពេលខាងយាយមុតយាយរបស់អំឈ្នោះអីគេទៅវិញ?

ខ:វាអត់ស្គាល់!

ក:អត់ដែរ?

ខ:អត់ស្គាល់តែម្តង!

ក:តា?

ខ:តាក៏អត់ស្គាល់ដែរ។

ក:យាយអត់ដែលស្គាល់អត់ដែរប្រាប់មានតែម្តង!

ខ:បើយើងនៅតូចជាងគេអញ្ចឹងវាស្មើរណាស់ដូចថាអូនឯងវ័យរត់ទៅអញ្ចឹងចេះតែរត់អញ្ចឹងក៏អត់ចាប់អារម្មណ៍
ប្រាប់អញ្ចឹងទៅណាស់ដល់អញ្ចឹងអត់ស្គាល់តែម្តង។

ក:ហ៊ឺ!ប៉ុន្តែបើសិនជាបងប្អូនប្រហែលជាស្គាល់?

ខ:ស្គាល់បងបងស្គាល់ បងរបស់ខ្ញុំនេះក៏អត់សូវស្គាល់ដែរបើបងស្លាប់ទៅនោះស្គាល់តែម្តង
ហ្នឹងបងបង្អស់

ណាស់!

ក:ចា៎ ហើយចុះដល់ពេលខាងឪវិញយាយតាខាងឪ?

ខ:អត់ស្គាល់នឹងណាស់ប្រាប់ថាអត់ស្គាល់!

ក:ទាំងពីរ!ទាំងសងខាងតែម្តង?

ខ:ចា៎ទាំងសងខាងតែម្តង។

ក:ហើយអ៊ំមីងមាអីវ៉ាន់នៅរស់ទល់ឥឡូវទេមីងមាខាងម៉ែខាងឪអីវ៉ាន់ណាស់?

ខ:នៅតើ!

ក:នៅដែរហេ?

ខ:នៅខ្លះស្លាប់ខ្លះ។

ក:ឥឡូវនៅឯណាវិញ?

ខ:នៅថ្នល់ដាច់ហ្នឹង ។

ក:នៅជិតផ្ទះបងហ្នឹងហេ?

ខ:ចា៎!នៅតែបងម៉ៅបងស៊ឹមបងណាតស្លាប់ហើយអ្នកខៀបស្លាប់ហើយហើយអ្នកបងអីអ្នកលុច
សុទ្ធតែជីដូនមួយ
ហើយហ្នឹង!

ក:សុទ្ធតែជីដូនមួយ?

ខ:ចា៎ជីដូនមួយខាងម៉ែហើយហ្នឹង!

ក:តែដល់ពេល ប្អូនរបស់ម៉ែ!

ខ:ហើយមកអញ្ចឹងបងធន
បងសឿមក៏ស្លាប់ដែរនៅតែបងធនហើយនឹងបងសឹមសុទ្ធតែជីដូនមួយម៉ែហើយហ្នឹង។
សុទ្ធតែក្មួយម៉ែ។

ក:សុទ្ធតែតែក្លួយ

។ប៉ុន្តែដល់ពេលមីងដូចរបៀបថាមីងរបស់ម៉ែគ៉ាន់អញ្ចឹងឬក៏យ៉ាងម៉េចអត់មានសាច់ឈាម?

ខ:អត់មាន! ស្លាប់អស់ហើយ។

ក:ចុះបងប្អូនម៉ែអីគ៉ាន់ហ្អ?

ខ:ស្លាប់អស់ហើយ។

ក:ស្លាប់អស់រលីងដែរ?

ខ:ចាំស្លាប់អស់ហើយអស់រលីងតែម្តងខាងម៉ែអស់រលីងខាងឪអត់មានទេគាត់មានម្នាក់ឯង។

ក:ហ្នឹងហើយគាត់ទោល។

ខ:គាត់ទោលគាត់អត់មាន!គាត់អត់ស្គាល់ម៉ែគាត់អត់ស្គាល់ឪគាត់ផងបើគាត់ទោលតែម្នាក់ឯងទៅ។

ក:ហើយអ៊ំដល់ពេលចូលមកដោយសារនេះសួរពីដូនតាពីអីអស់ហើយដោយសារអ៊ុំចាំខ្លះអត់ចាំខ្លះអញ្ចឹងទៅអ៊ុំ

ពេលចូលជំនាន់លន់ណុលអន់ទៅរស់នៅឯណាវិញ

ពេលទម្លាក់គ្រាប់បែកឥវ៉ាន់នោះ?ពេលទម្លាក់សម្តេចហើយ

មកនោះ?

ខ:អ៊ំនៅតូចដែលមិនសូវចាំ អត់សូវចាំទេ!បានថាអត់សូវចាំអ៊ុំនៅតូចតែម្តងណាស់ ។

ក:ដែរទោះថានៅតូចមានដែលចាប់អារម្មណ៍ថាមានឃើញគ្រាប់បែកគេបាញ់គ្នាអីគេទេអ៊ំ?

ខ:មាន

ឃើញតែគ្រាន់ថារត់ចូលត្រង់សេរត់ចូលក្រោមជង្រុករត់ចូលក្រោមអីតែគ្រាន់តែអ៊ុំអត់ចាំចាំតែប៉ុណ្ណឹង

ងចូល

ចូលនឹងគេម៉ែអោយចូលចូលនឹងគេទៅ។

ក:ហើយមានឮដុងដាំងអីអត់អ៊ំ?

ខ:ឮក្តុងក្តាំងហ្នឹងគេបាញ់អាពួកអស់ហ្នឹងគេចូលឮក្តុងក្តាំងៗរត់ចូលក្នុងជង្រុកដោយតែពេលចេញ

ពីក្នុងជង្រុកវិញ

ចេញអត់កើតចេញរួចអភ័យចូលទៅរួច។

ក:ដូចយាយនោះគាត់ប្រាប់អញ្ចឹងគាត់ប្រាប់ថាគាត់ភ័យក៏រត់ចូលព្រៃឫស្សីរួចដល់ពេលចេញមកវិញគាត់មិនរួច។

ខ:ហ្នឹងចេញមកវិញមិនដឹងចេញតាមណា។

ក:យ៉ាងម៉េចបានចេះតែអញ្ចឹងអ៊ំណោះ?ខ្ញុំឆ្ងល់ដល់ហើយអាចិត្តមនុស្ស!

ខ:ចិត្តមនុស្ស!ធ្វើយ៉ាងម៉េចអូនភ័យណាស់មាអាអំណាចភ័យចេះតែទៅហើយដល់តែចេញមកវិញតិចរួចនាំគ្នាលូន
ផងក្រាបផងបានចេញរួច ហើយបើអាភ័យចូលផ្តុកលឿនតែម្តង។

ក:ហើយអ៊ំពេលនឹងជំនាន់លន់ណុលមានជំលៀសទៅភ្នំពេញទៅអីឯណាឬក៏អត់រឺក៏នៅតែទីហ្នឹង
?

ខ: នៅតែខ្វាន់មាសហ្នឹង អត់ទៅណាផង។

ក:នៅខ្វាន់មាស?

ខ:ចាំអត់មានទៅទីណាទេ។

ក:ហើយនៅផ្ទះនិងមានជីកត្រង់សេជីកអីស្រាប់ដែរឬក៏អត់អ៊ំ?

ខ:ជីតើ!ជីកត្រង់សេមុខផ្ទះជួនកាលបងរបស់ខ្ញុំជីកនៅខាងក្នុងផ្ទះតែម្តង!ជីកនៅក្នុងផ្ទះហើយគាត់ដាក់ ចុះ

អាសរសរយើងអាខ្លីមខ្លីមអាពីដើមហ្ន៎!ក:ថ៎!ខ:ហ៊ីដាក់ធំៗណាស់ប៉ុនៗនេះ
នៅក្នុងហ្នឹងតែម្តងស៊ីបាយនៅ
ក្នុងហ្នឹងទៀត ភ័យ អត់ហ៊ានចេញមីអូនណាស់ ខ្លាចអំណាចខ្លាច
ដាំបាយឆ្អិនអីហើយនាំគ្នាដាំបាយអីហើយនាំកូន
ចៅចូលត្រង់សេ ហូបនៅក្នុងត្រង់សេហ្នឹងទៅ មើលតែស្ងាត់បានហ៊ានចេញ ។

ក:មានអ្នកចេញមួយទៅមើលទៅអ៊ំណោះ?

ខ:ថ៎មើលតែស្ងាត់គ្រាប់ក្តុងក្តាំងៗផ្លោងមកក្តុងៗៗហើយស្ងាត់ចេញមកប៉ុន្តែបើអត់ស្ងាត់ទេយើងនៅក្នុងហ្នឹងទៅ!

ក:វាយ៉ាងម៉េចពួកទាហានដើរពេញហ្នឹងមែន? ម៉េចបានអញ្ចឹងអ៊ំណោះ?

ខ:ហ៊ីដើរឡើងពេញទឹកពេញដីហ្នឹងមីអូនអើយកាលពីជំនាន់ហ្នឹងនិយាយពីភយ័
ខ្ញុំនិយាយពីកំសត់ណាស់ព្រោះ
យើងនៅតូចជាងគេយើងកម្សត់តែម្តង។

ក:ដឹងក្តីមកលឺតែកាំភ្លើងគ្រាប់បែក!

ខ:លឺតែអញ្ចឹងមកតែម្តង ភ័យខ្លាចរហូត។

ក:អ៊ំខ្ញុំឆ្ងល់អញ្ចេីកដល់ពេលជីកត្រង់សេនៅក្នុងផ្ទះអញ្ចឹងបើសិនជាគ្រាប់បែកមកចំផ្ទះហ្នឹងមិនអស់ហើយ !

ខ:ចុះធ្វើយ៉ាងម៉េចបើសិនជាងាប់ងាប់ទាំងអស់គ្នាទៅនៅក្នុងហ្នឹងទៅ។

ក:កុំអោយគេដើរមកឆែកឃើញមែនអ៊ំឬក៏យ៉ាងម៉េច?

ខ:ហ្នឹងហើយកុំអោយគេឃើញ!មិនមែនអញ្ចឹងទេ ជីក
មុនដំបូងជីកនៅខាងក្រៅទេនៅខាងក្រៅវាចេញទឹកដល់
ពេលអញ្ចឹងមកជីកនៅក្នុងផ្ទះទៅក្នុងផ្ទះក្រដាក់សរសរដាក់អីទៅធំណាស់ជីក!ធំមែនទែនតែម្តង
ហើយណាស់ធំហើយឡើងទូលាយ

ក:ហើយអ្នកណាគេជាអ្នកជីកត្រង់សេ?

ខ:បងថ្លៃ បងថ្លៃបងថ្លៃបងខ្ញុំបង្កើតនូវខ្វាន់មាសស្លាប់ហ្នឹង!

ក:ហ្ន៎!ឥឡូវបងថ្លៃហ្នឹងនៅរស់ដែលទេអ៊ំ?

ខ:ស្លាប់ការពេលទៅនេះនឹងកាលពេលទៅប៉ែលិន។

ក:ហ្ន៎បងថ្លៃហ្នឹងដែរ!

ខ:ថ៎!ហើយបងខ្ញុំទើបតែស្លាប់បានប៉ុន្មានថា 10 ឆ្នាំហើយបងម្បឿនមិនទាន់ដល់
1oទេបែបប្រហែល 7ឆ្នាំអី
ហ្នឹង។ស្លាប់មុនតាយូរដែរហ្នឹងប្រហែល 2 ឆ្នាំបីឆ្នាំហើយ។

ក:ថ៎!

ខ:ឥឡូវតាប៉ុន្មានហើយខ្ទង់ 6 ហើយ!

ក:៨ឆ្នាំហើយតាតាស្លាប់។

ខ:បងម្បឿនចូលដល់10ឆ្នាំជាងហើយ!

ក:ហើយអ៊ំដល់ពេលបានស្រាកស្រាន្តហើយមកផុតគ្រាប់បែកគ្រាប់អីមកអ៊ំណោះ?

ខ:ថ៎!

ក:ហើយស្ងាត់បានប៉ុន្មានខែបានចូលអាពតមកវិញទៀតហ្ន៎?

ខ:ចូលមកអាពតខ្ញុំវាមិនសូវចាំទេ!តែគ្រាន់ថាវាចូលអាពតហ្នឹងអ៊ំនៅតូចអាយុនឹង៧ឆ្នាំប្រាំបីឆ្នាំ
ចុះ ៧ឆ្នាំបផឆ្នាំថា

10 ឆ្នាំចុះ!

ក:ថ៎!ដប់ឆ្នាំដប់មួយហើយ!

ខ:ថា 10ឆ្នាំជាងចុះខ្ញុំវានៅតូចដែរគេអោយចូលកងកុមារហ្នឹង កងកុមារថាវេទនាហ្នឹង
នៅឯមាត់បឹងណាស់គេអោ
យទៅនៅបឹងណាស់គេអោយចាប់ពីកណ្តុរ ដេញកណ្តុរវាស៊ីស្រូវហ្នឹងហ្ន៎ ហ៊ីចាប់កណ្តុរ
ដេញកណ្តុរអញ្ចឹងជីករន្ធក
ណ្តុររន្ធអីអញ្ចឹងទៅ ដល់សុំគេ
គេអត់ឲ្យមកអញ្ចឹងយំដេកយំនឹកម៉ែណាស់យើងមិនដែលដេកបែកម្តាយនោះ
ណាស់!អញ្ចឹងដេកយំនឹកតែម៉ែហ្នឹង គេថាង៉ែងយំថី
គ្នាឯងហ្នឹងណាស់!ពួកម៉ាកគ្នាឯងសួរថាយំថី?អញនឹកម៉ែ
អញនឹកឪអញ

ចុះប៉ែងសំុគេទៅផ្ទះទៅគេអត់អោយទៅ!ដល់តែភ្លឺឡើងៗចឹងទៅនាំគ្នាដេញកណ្តុលដេញអី

ទៀតអញ្ចឹងទៅភ្លេចម៉ែទៅដល់តែពេលយប់ឡើងនឹកម៉ែនឹកឃើញម៉ែទៀតហើយ

ដឹងថាយើងអត់ដែលបែកចេញចឹង

ណាស់បែកពីម្តាយយើនឹកតែម្តាយ។

ក:អញ្ចឹងអោយរដេញកណ្តុរ អ៊ំដល់ពេលដើរជីករូងកណ្តុរមានដែរចំរូងពស់ដែរឬក៏អត់អ៊ំ?

ខ:អត់ទេ!

ក:មានតែរន្ធកណ្តុរ?

ខ:មានតែរន្ធកណ្តុលតែម្តង!

ក:តែពស់!

ខ:ប៉ុនៗនេះ!កណ្តុរបឹងធំធំណាស់!

ក:ហើយដើមកមិនមែនយកធ្វើអីអីឯណាហី?

ខ:ដើមកពីអ្នកនៅនេះគេនៅពត់សរគេនៅខ្ពាក្ងនយកមកស៊ីណាស់!ខ្ញុំអត់ហ៊ានហូបទេពួកហ្នឹងគេ

ធ្វើទៅគេប្រឡាក់

អញ្ចឹងទៅគេហាល ហាលថ្ងៃឲ្យស្ងួតអញ្ចឹងទៅគេអាំងហូបទៅ។

ក:តែពួកប៉ុលពតអត់ថាអីទេពេលហូបកណ្តុរ?

ខ:អត់ថាអីទេអត់អីទេ!

ក:ដោយសារបើសិនជាហូបមាន់ហូបអីប្រហែលជាត្រូវរបស់វាវិញ!

ខ:ត្រូវរបស់វាហើយ!តែបើចិញ្ចឹមមាន់អី
ដាំដំណាំយើងគាស់ស៊ីយើងអត់ប្រាប់វាវាថាយើងគួនយើងអត់ដាក់
សម្ងួហភាព។

ក:វាចង់អោយធ្វើអីរួមទាំងអស់!

ខ:ចា!ចង់អោយធ្វើអីរួមទាំងអស់អត់អោយយើងស៊ីដាច់ដោយឡែកយើងគាស់យើងដាំនៅឯផ្ទះ
យើងគាស់ យក
ទៅដាក់សម្ងួហភាព អោយគេស៊ីផង។

ក:តែយើងក៏បានហូបដែរឬក៏អត់ពេលហ្នឹង?

ខ:ហ៊ីចុះអាសម្ងូហភាពវាមិនមានមនុស្សតិចឯណាមីអូន!រាប់រយរាប់ម៉ឺនមនុស្សមួយម៉ាត់មួយក៏មួយនាក់ហ្នឹង!វា

ច្រើនពេកផងបាយមួយចាន

មួយក្រវិលមួយតក្រវិលចានស៊ីទៅធឹកតែទឹកទៅមួយថ្ងៃមួយថ្ងៃបានអីហូប!ជួនកាលឃ្លានពេកមីអូនណាស់បេះស្ពឺកអំពិលមកផ្ទាប់អាក្តាមតូចតូចហ្នឹង

ហូបទៅអត់អំបិលអត់អីផ្ទាប់តែក្តាមហ្នឹងហូបទៅ

ហើយហូបហើយហូបទឹកទៅធ្វើការវិញទៀតទៅ!

ជួនកាលចឹងចង់ដាច់ខ្យល់ងាប់ពោះនៅដណ្តប់ឆ្អឹងខ្នងណោះ។

ក:ងាប់ហើយអ៊ំ!

ខ:ផទនាណាស់ណាស់មីអូនណាស់ថាផទនាណាស់ផទនាមែនទែន!

ក:ហើយអ៊ំពេលធ្វើការហ្នឹងក្រោកក្រោកហើយហេ?

ខ:ហ៊ីពោះកូនរហូតហើយយើងធ្លាប់នៅពីក្មេងមីអូន

អញ្ចឹងហិបាយឆ្នាំងម្តាយដាំពេញៗឆ្នាំងហ្ន៎មកពីលេងដើរលេង

ជាមួយពួកម៉ាក់អញ្ចឹងតូចដូចគ្នាគ្នាដើរលេងបាយឡុកបាយឡអញ្ចឹងទៅណាស់

រត់តាំងតាំងមកបើកឆ្នាំស៊ីទៅស៊ី!

ហើយចុះយើងជំនាន់ប៉ុលពតមានអីហូបអូនឯងគិតមើលមានអីហូបវាគ្មានអីហូបពីផទនាណាស់!

ក:អ៊ំក្រៅតែពីពេលគេអោយដើរមើលកណ្តុរហើយការពារស្រូវកុំឲ្យវាស៊ីអញ្ចឹងចុះប៉ះលោរកណ្តុរ
ហ្នឹងពេលខ្លាចអត់
បានមើលគ្រប់ជ្រុងជ្រោយទៅវាស៊ីស្រូវវាយ៉ាងម៉េចទៅ?

ខ:គ្រប់កន្លែងដើរដេញគ្រប់កន្លែង!ហើយដេកនឹងណាស់ធ្វើដូចយើងធ្វើនេះអញ្ចឹងដេកតាមបន្តិច
បន្តិចដេកតែម្នាក់
ម្នាក់ឯង ជួនកាលមានពីរនាក់យើងពួកម៉ាក់យើងដេកជាមួយគ្នា 2
នាក់អញ្ចឹងទៅ។ប្រក់ស្លឹកពីសងខាងទៅដេកទៅ
កំសត់ណាស់។

ក:ហើយទៅយកស្លឹកពីឯណាទៅវិញ?

ខ:ស្លឹកយើងកាប់ទៅដេរខ្លួនយើងទៅ!ហើយយើងធ្វើថែប
អាហ្នឹងគេហៅថែបដេកទៅជួនកាលខ្លាចពស់ខ្លាចអី
មកអញ្ចឹងទៅមីអូនណាស់ប្តីខ្ញុំចង់ទៅជួនកាលដេកលក់អញ្ចឹងទៅ!ជួនកាលដេកអត់សូវលក់អីអ
ញ្ចឹងទៅចេះតែ
ក្រោកមើលទៅណាស់ខ្លាចលោរពស់លោរអី !ចុះបឹងមីអូនឯងដឹងស្រាប់ហើយ។

ក:ហ្អ៊ុំទៅបឹងទេអញ្ចឹង?

ខ:នៅបឹងនឹងណាស់នៅបឹងតែម្តងគេអត់ឲ្យយើងមកផ្ទះទេ។

ក:អ៊ំតែនៅបឹងពួកវាមាននៅយាមយើងអីទៀតដែរឬក៏អត់?

ខ:អត់មានទេប៉ុន្តែគ្រាន់តែថាវាវាឈ្លបមានអីអញ្ចឹងដើរមើលអញ្ចឹងទៅណាដើរមើល
ខ្លាចយើងដើរទៅឯណាទៅឯណីទៅណាស់!វាអោយឈ្លបមើលហើយវាដើរទៅវិញទៅ!វាមើល
ហើយហើយឃើញយើងដេកលាន់ចឹងទៅមាតាទៅវិញទៅ។

ក:ហើយមានបានទៅរកអីហូបទេពេលចឹង?

ខ:ពេលចឹងយើងដើរហួតឯណាទៅកើត!វាវាអត់ឲ្យយើងដើរកហូប។យើងដល់យើងលួចលាក់
។ដូចថាស្ងាត់អ
ញ្ចឹងទៅមើលល្ហែមលើមៗមើលតែស្ងាត់ៗចឹងទៅយើងបង្កាត់ភ្លើងទៅអាំងអីទៅ!ដូចថាចាប់ត្រីចា
ប់អីបានអញ្ចឹង
ទៅណាស់!យើងអាំងហូបទៅ បើអញ្ចឹងទេអត់ទេ!

ក:ហើយចុះប៉ះវាឃើញផ្សែងអញ្ចឹងទៅទៀតចប់ទៅហើយអ៊ំ?

ខ:អត់អីទេ ឃើញផ្សែងអត់អីទេ បើដូចថា

ឃើញយើងដើកណ្តុរដើអីអញ្ចឹងយើងនាំគ្នាហូបអញ្ចឹងអត់អីទេកុំអោយតែ

យើងយកទៅដាក់ឯណាយើងស៊ីជាមួយគ្នាទាំងអស់គ្នាហ្នឹង!កងកុមារមួយហ្វូងយើងស៊ីទាំងអស់

គ្នាហ្នឹង! អត់

អីទេ។

ក:តែសំបូរត្រីណាស់ពេលហ្នឹងអ៊ំហ៎?

ខ:ហ៊ីខ្ញុះអីត្រីពេលហ្នឹងសំបូរណាស់មីអូន!អូនអើយសំបូរណាស់ត្រីបឹងមិនដឹងយកទៅណាអស់

ទេត្រី។

ក:តែពេលហ្នឹងអ៊ុំចាប់យ៉ាងម៉េចនឹងបានទៅដាក់សន្ទូចឬក៏ដាក់អី?

ខ:យើងដាក់មិនបាច់សន្ទូចទេយើងទៅរាវទៅយើងទៅចាប់នៅនឹងស្មៅទៅ ត្រីកំភ្លាញត្រីក្រក

ប៉ុនៗហ្នឹង

ណាស់!

ក:អីគ្រាន់តែរាវចឹងសោះចាប់បានដែរ?

ខ:ចាំ!ចាប់បានរៀបនឹងកក់ និងកក់ កក់អាគេធ្វើនេះហ្នឹង គេធ្វើកន្ទេលនេះមីអូន
កន្ទេលក្រហមកន្ទេលអីនេះ
ហ្នឹង!

ក: ចេះតែចាប់បានស្រួលម្ល៉ឹងៗដែរ?

ខ:ហ៊ីយើងនិយាយពីត្រីកាលពេលស្របក់ហ្នឹងអត់ខ្វះទេមីអូន ។

ក:តែវាមិនអោយ។

ខ:គេវាមិនអោយយកទៅស៊ីដូចថាយើងស៊ីតែម្នាក់យើងអត់កើតទេ!យើងដាក់សម្ងួហភាពទាំងអ
ស់គ្នាអញ្ចឹងទៅ
ណាស់អាហ្នឹងបានគេឱ្យហូប យើងរកបានទាំងអស់គ្នាអញ្ចឹងនាំគ្នាធ្វើស៊ីទៅ។

ក:អាហ្នឹងអត់អីទៅវិញ!

ខ:អាហ្នឹងអត់អីទៅវិញទេ។

ក:តែដោយកន្លែងខ្លះកន្លែងខ្លះក៏អត់បានដែរអ៊ំហៅ?

ខ:ចាក់ន្លែងខ្ពះបានទេ។

ក:តែពេលខ្ពះអ្នកខ្ពះក៏ចិត្តធម៌!

ខ:តែអញ្ចេះកងកុមារទេដូចថាគេមិនសូវយកចិត្តទុកដាក់ដូចកងនារីកងយុវជនធំធំអញ្ចឹងទៅណា
កងកុមារគេចេះ

អនុគ្រោះអញ្ចឹងទៅណាស់!

ក:ហ្នឹងហើយដោយសារគិតថាហ្ន៎ក្មេងវាមិនដឹងអី។

ខ:វាមិនសូវដឹងអី ហ្នឹងហើយ។

ក:បើសិនជាយុវជនយុវនារី!

ខ:ហ្ន៎ថាកំសត់ណាស់មីអូនអើយជំនាន់ប៉ុលពតកំសត់មែនទែនតែម្តងហ្នឹង!

ក:អ៊ំបឹងដែលអំណោយនៅឯណាទៅវិញ?

ខ:បឹងនៅឯកើតវត្តត្របែក!ខាងកើតវត្តត្របែកហ្នឹងតែម្តង!

ក:ចា៎!ចូលទៅក្នុងឯណោះ?

ខ:ចូលទៅក្នុងជ្រៅ!

ក:ទៅឯណាឯណីវិញឯណោះ!

ខ:វត្តត្របែកឯណោះជាប់មាត់បឹងហ្នឹងតែម្តង។

ក:អ៊ុំពេលនៅក្នុងជំនាន់ប៉ុលលពតណាស់ក្រៅពីកន្លែងមួយហ្នឹងគេមានជម្លៀសអ៊ុំទៅនៅកន្លែងឯណាឯណីអត់?

ខ:ហ្ន៎ដើរគ្រប់កន្លែង
ដល់តែចេញពីអាហ្នឹងមកមកនៅក្នុងភូមិកងកុមារហ្នឹងណាស់មកនៅក្នុងភូមិគេនៅ ចេញពីវត្តត្របែកហ្នឹងមកមកនូវស្អីគេហៅស្អីពត់សរខ្ចាកូន !

ក:ពត់សរ សខ្ចាកូន ព្រៃស្វា!

ខ:ត្រពាំងត្រាវនៅត្រពាំងត្រាវ!ក:ចា៎!ខ:ត្រពាំងត្រាវ!

ក:នៅតែជិតជិតគ្នា!

ខ:នៅតែក្នុងភូមិហ្នឹង ចេញមកមិនមកនៅក្នុងភូមិគេ។

ក:ចា៎អឹំ ប្រជាជនចាស់ឬក៏ថ្មី?

ខ:ខ្ញុំវាមិនចាស់វាមិនថ្មី កណ្តាល
។ខ្ញុំចេញពីទន្លេមកបានមកនៅទីហ្នឹងណាស់មកនៅក្នុងភូមិខ្ញុំហ្នឹងណាស់បាន
កាលពេលហ្នឹងគេហៅអ្នកថ្មីដែរប៉ុន្តែដូចថាវាមិនចាស់ប៉ុន្មានទេអាហ្នឹងវាជំនុំជំនុំដែរ
គេហៅថាអញ្ចេះចុះ!

ក:អឹំដល់ពេលអ៊ុំចូលមកពីជំនាន់ប៉ុលពតនឹងណាស់ដល់អឹំនៅទន្លេហើយបានបងមករឿងមែនឬក៏
យ៉ាងម៉េច?

ខ:ចា៎!ហ្នឹងហើយ!

ក:មានប៉ុលពតនៅទីហ្នឹង!

ខ:ចា៎មកពីទន្លេមកបានមានប៉ុលពត។

ក:អញ្ចឹងចេញពីខ្វាន់មាសហើយ?

ខ:ចេញពី ខ្វាន់មាសនេះទៅទន្លេ!

ក:ទៅទន្លេហើយបានបងមកវិញ?

ខ:ចាំ!បានរត់រត់ពីហ្នឹងទៅទៅនៅទន្លេចេញពីទន្លេនឹងមកវិញបាននាំត្រឡប់មកបានប៉ុលពតបាន ប៉ុលពត!

ក:ចាំ ហើយនៅទីហ្នឹងជាមួយ!ហើយម៉ែនៅចម្ងាយប៉ុន្មានពីគ្នាទៅ?

ខ:ម៉ែខ្ញុំមែន?ក:ចាំ!ខ:ម៉ែនៅជាមួយខ្ញុំហ្នឹង!

ក:ជាមួយដែរ!

ខ:នៅជាមួយគ្នា។

ក:ប៉ុន្តែដល់ពេលដល់ពេលដេញកណ្តុរបានបែកពីគ្នា?

ខ:ហ្ន៎ម៉ែគាត់នៅនឹងផ្ទះទេក៏អត់ទៅណាទេព្រោះគាត់ចាស់អញ្ចឹងគេអោយនៅផ្ទះណាស់ហើយបងខ្ញុំគាត់មើលកូន

អោយបងខ្ញុំ!មើលអោយមីបងមួយស្លាប់ទៅនឹងណាស់ គេឲ្យមើលថៅ 2

នាក់តាមើលថៅទៅ!ហើយបងខ្ញុំទៅ

ធ្វើការចឹងទៅបងផ្ទៃរបស់ខ្ញុំទៅរកត្រីនៅបឹងនិងដែរ!ហើយខ្ញុំនៅបឹងហ្នឹង

ហើយខ្ញុំបងស្រីខ្ញុំធ្វើអង្ករគេអោយធ្វើអង្ករ

ណាស់គេអោយកិនស្រូវហ្នឹងហើយជាន់ជាអង្ករ។

ក:ហ្នឹងហើយជាអញ្ចឹង ហើយយាយពេលហ្នឹងអាយុចាស់ខ្លាំងហើយហ៎?

ខ:ម៉ែខ្ញុំវាចាស់ហ្នឹងណាស់!

ក:តែអ៊ំថាស្លាប់ 52ហេ?

ខ:52 ! ហេមិនមែន52 ទេម៉ែ!បែបចូល 70 អី ហើយម៉ែ ម៉ែចូល

60ឆ្នាំជាងប្រហែលព្រោះឱពេលគាត់ស្លាប់ហ្នឹងវាចូល 66 ឆ្នាំ

67ឆ្នាំហើយណាស់គាត់ស្លាប់ណាស់!

ក:ប៉ុន្តែម៉ែ60 ឆ្នាំជាង?

ខ:ចា៎!

ក:ហើយអ៊ំដល់ពេលវាឲ្យទៅមើលកណ្តុរហ្នឹងហើយបានចេញពីអាបឹងហ្នឹងហើយមកនៅផ្ទះធ្វើអី
គេទៀត?

ខ:មកនៅត្រពាំងត្រាវហ្នឹងគេអោយធ្វើជីដែកដីដំបូកដែកដី!

ក:មានពាក្យកាប់អោយស្រាប់ហៅ?

ខ:គេកងយើងកុមារហ្នឹងកាប់ទៅ កាប់ទៅយើងអ្នកសែងទៅ
សែងទៅយកទៅលាយដីលាយអាចមន៍គោលាយ
អាចមន៍លាយអីហ្នឹង លាយអោយគេទៅយើងកាប់ជ្រុំៗៗ
ដៃអោយតែបែកបែកទៅយកទៅលាយអោយចាស់ចាស់
គាត់យកទៅដាក់ស្រែ!

ក:ដាក់ស្រែ!អ៊ំភាគច្រើនដីដំបូកគេថាមានពស់មានអីនៅយ៉ាងម៉េចទៅអ៊ំ?

ខ:ជួនកាលមានមែនហ្នឹង
អត់អត់ទេនៅក្នុងដីដំបូកមានប៉ុន្តែយើងកាត់យើងស្គារអញ្ចឹងទៅអត់មានទេដីដំបូកប៉ុន
ណាណីអញ្ចឹងទេអត់មានទេ ជួនកាលវាមាន!បើកកន្លែងណាព្រៃចឹងមានណាស់មីអូន
ធ្វើរុនធ្វើអីហ្នឹងអញ្ចឹងទៅ
ណានាំគ្នាពទ្ធដៃអីអញ្ចឹងទៅ ។

ក:ក្មេងក្មេងហ្នឹងហ៊ានម្លេះ?

ខ:ក្មេងក្មេង! ហេក្មេងក្មេងប្រុសប្រុសណាស់កងកុមារប្រុសប្រុសណាស់។

ក:ហ្ន៎ក្លាហានដែរហ្នឹងណាស់។

ខ:ថ៎!

ក:ពស់ស្រួលមិនស្រួលចឹកងាប់។

ខ:វាដើរចឹងទៅនាំគ្នាធ្វើស៊ីទៅនាំអាំងស៊ីទៅជាមួយគ្នាវាប្រុសប្រុសហ្នឹង!កងកុមារ។ស្រីស្រីនៅដោយខ្លួន ទៅ
ណាស់!ក្មេងស្រីស្រីនៅកងដោយខ្លួនក្មេងប្រុសប្រុសវាឲ្យនៅដោយខ្លួន។

ក:អញ្ចឹងវាអោយនៅឡូកឡំជាមួយគ្នា?

ខ:អត់អោយនៅឡូកកឡំគ្នាទេកងកុមារប្រុសប្រុសនៅដោយខ្លួន កុមារស្រីស្រីនៅដោយខ្លួន!

ក:ឆ្ងាយពីគ្នាទេអ៊ំ?

ខ:ចា៎ ដូចថាពីព្រឹមណឹងទៅទៅដល់មាត់ ដល់កន្លែងស្ពានដែលខាងកើតមីអូនឯង ហ្នឹង!

ក:ស្គាល់ហើយ។

ខ:ហើយកងកុមារនារីនៅទីនេះក៏បានស្រីស្រីកងកុមារក្មេងប្រុសប្រុសនៅម្តុំអស់ហ្នឹងអញ្ចឹងទៅណាឆ្ងាយពីគ្នា

ណាស់!

ក:ចា៎!

ខ:ប៉ុន្តែដល់ពេលមកធ្វើការធ្វើជាជិតគ្នា កាប់ដីដំបូកកាប់ដីអីកាប់ជិតគ្នាអញ្ចឹងទៅណាស់!

ក:តែដល់ពេលបងប្អូនអ៊ុំទៅឯណាវិញទៅ?គាត់ពីរនាក់នោះនៅជាមួយដែរឬក៏អត់?

ខ:បងស្រីស្រីរបស់ខ្ញុំហ្នឹងហេ?បងរបស់ខ្ញុំនៅថ្ងល់ដាច់នេះនៅនារីដែរអញ្ចឹងកេកងនារីធំធំគេចេះទៅឯណាឆ្ងាយ

ឆ្ងាយទៅឯងស្អីៗឯណាភ្នំជីសូភ្នំអីអញ្ចឹងទៅឆ្ងាយឆ្ងាយណាស់!គេឱ្យដើរឆ្ងាយឆ្ងាយណាស់ហើយដល់ពីជំនាន់បែក

ហ្នឹងគេឲ្យទៅរហូតឯណាឯណឹងណោះដើរមកគេមកដល់ផ្ទះអស់នៅតែបងរបស់ខ្ញុំមួយអត់ទាន់មកដល់ផ្ទះគិតតែពី

ភ័យម៉ែឥវ៉ាន់ភ័យ!ចុះកូនអញ្ចក្រមកម្ល៉េះ!កូនអញ្ចក្រមកម្ល៉េះ ភ័យណាស់!

ក:ថ៎ាដោយសារគេអោយកូនទៅធ្វើការនៅឆ្ងាយឆ្ងាយ!

ខ:កូនធ្វើការនៅឆ្ងាយរហូតឯផ្លូវជាតិលេខ 3 ឯណោះណាស់ផ្លូវជាតិលេខ 3 លេខ 4 ឯណោះណាស់!

ក:ភ្នំស្រង៉ភ្នំអីឯណោះហេ??

ខ:ហួសនឹងទៅទៀត!

ក:ឆ្ងាយខ្លាំងណាស់អ៊ុំ!

ខ:ថ៎ា!

ក:សូម្បីតែយើងជិះឡានជិះម៉ូតូនៅឆ្ងាយហើយហ្នឹង!

ខ:ហើយដើរហូតគិតមើលដែរហូត!គ្រាន់តែរៀតណាមចូលមកហើយដើរផងអីផងដើរមកផ្ទះរ
ហូតទំរាំមកដល់
ផ្ទះ!

ក:ហើយពេលហ្នឹងយ៉ាងម៉េចប៉ុន្មានថ្ងៃបានមកដល់ផ្ទះបែក?

ខ:គេមកដល់ប្រហែល ម៉ោង8 ឃប់ម៉ោង 9
ឃប់បងរបស់ខ្ញុំទល់ភ្លឺបានមកដល់បានលែងភ័យបានបងមកដល់បង
របស់ខ្ញុំបងស្រីនៅខ្វាន់មាសនិងភ័យមកដល់គ្រប់គ្នាហើយអត់តែបងប្អូនឯងណាស់ហើយខ្ញុំនៅ
នេះទេតើនៅខាង
ក្រៅវត្តកកោះទេតើ!

ក:ចា!ហ្ន៎អ៊ុំប្រសិនបើនៅខាងក្រោយវត្តកកោះឃើញមនុស្សស្លាប់ច្រើនណាស់អ៊ុំហេ?

ខ:ហ៊ឺ!គេអោយទៅកាប់ជីមីអូនអើយកាប់ៗៗៗៗអាធាងខេត្តហ្នឹង
កាប់ៗៗជាន់ព្រួកលើកជើងមករត់ !

ក:អីគេទៅអ៊ុំជាន់សាកសព?

ខ:ជាន់សាកសពចុះវាកប់គ្នា 4 នាក់ 10 នាក់អញ្ចឹងកប់មួយនេះហ្នឹង

ដល់ពេលហើមទៅវាមិននេះ!

ក:អើយញ្ញេីតណាស់អ៊ុំ!

ខ:ភ័យភ័យរត់ហ្អែងស្ទឹងចឹង 2 នាក់ពួកម៉ាកខ្ញុំនៅខ្វាន់មាសហ្នឹង

ឈ្មោះថ្លែលៗហ្នឹង!រត់ហ្អែងពីរនាក់ហ្នឹង អត់

ហ៊ានរត់មកវិញ

មកកងធាងខេត្តខ្ពាចអត់បានធាងខេត្តអោយគេណាស់!អត់បានធាងខេត្តឲ្យគេគេរ៉ឹងចោល

ទៀតឯណោះ

ដោយសារមួយសន្ទុះស្រាប់តែពួកពួកអាកងទ័ពនិងណាស់វាដើរស្ពាយអាកាំភ្លើងមក កាំភ្លើងមក

ស្រាប់តែឃើញខ្ញុំរត់

ហើយពីរនាក់ខ្ញុំនឹងពួកម៉ាក់ខ្ញុំនិងចេះតែថាធ្វើអោយស្រួលប្រួលទៅតិចពិបាកគេរ៉ឹចោល!

ខ្ញីបខ្ញីបគ្នាអញ្ចឹងណាស់ធ្វើត្នោតធ្វើរឿងអីអញ្ចឹងទៅណាហើយទើបតែរ៉ឹកាប់កប់ថ្មីៗ

ហើមឡើងកំពុង ជាន់ព្រួក!

ក:អើយអ៊ុំ!មិនដឹងជាន់ចំឯណាទេពោះអីវ៉ាន់ហ្នឹងហ៎!

ខ:ហ៊ឺ!ខ្ពាចនោះខ្ពាចមហាសែនខ្ពាច

អោយឡើងកាប់នៅលើភ្នំតាម៉ៅភ្នំអីហ្នឹងណាស់ធាងខេត្តមីអូនណាស់!

ក:ឆ្ងាយម្ល៉េះ?

ខ:ហ៊ឺ!ឡើងកាប់លើភ្នំតាម៉ៅភ្នំអីឯណោះ

អោយតែមួយថ្ងៃបានពីរបាច់មួយគ្នាធ្វើយ៉ាងម៉េចអោយបានពីបាច់បានរួចខ្លួន។

ក:ទៅរកឯណាទៅរកទៅ?

ខ:រកឯណារកទៅ!រកអោយតែបានហើយកាលពេលហ្នឹងសម្បុរមែនសម្បុរមែនទែនតែម្តងនេះ

ខ្វះអីធាងខេត្រ

យកទៅណាអស់។

ក:ថ៎!អត់ទេពេលហ្នឹងសង្គ្រាមទាន់ជំនាន់អាសម្បុសប្បាយសម្បុរទាំងត្រីសម្បុរទាំងបន្លែទាំងអ

ស់ណាស់អ៊ំ

ណាស់!

ខ:ថ៎!សម្បុរទាំងអស់!

ក:ប៉ុន្តែឥឡូវសាកទៅរកមើលបើមាន!មិនងាយទេហេ?

ខ:ថានិយាយពីខ្ញុំដើរខ្ទេចដើរខ្ទីអស់ហើយគ្រប់កន្លែងទាំងអស់ដកកងនារី 77

ហើយចេញពីហ្នឹងទៅនៅភ្នំស្រង់

ទៀត អោយទៅនៅភ្នំស្រង់វិញអោយតែនៅភ្នំស្រង់!

ក:ហ្ពីក៏បានច្រើនកន្លែងម្លេះអ៊ំ!

ខ:ចា៉!នៅភ្នំស្រង់និងបានមួយខែគេដកកងទៀតហើយទៅព្រៃងាត។

ក:ស្អីព្រៃងៀត?

ខ:ស្គាល់ព្រៃងៀតទេ?

ក:អត់ផងអ៊ំ!

ខ:ខាងខាងលិចភ្នំស្រង់ខាងលិចហ្នឹងឆ្ងាយណាស់មិនមែនជិតទេណាស់!ហើយដើររហូតមីអូន

ណាស់ដើរ

រហូត!

ក:ចា៉!អ៊ំពេលនៅភ្នំស្រង់ក៏នៅមានសត្វដែរ!ខ:ចា៉!

ក:មានខ្លាមានអីដែរ!

ខ:មានអីទាំងអស់!

ក:អញ្ចឹងអ៊ំដល់ពេលអ៊ំជាន់សាកសពជាន់អីអញ្ចឹងហើយដល់ពេលអញ្ចឹងនៅវត្តកកោះហ្នឹង!មិញ
ឈប់ផ្អាកអាកន្លែង
ទៅភ្នំស្រង់សិនមុខបកក្រោយអាកន្លែងជាន់សាកសពហើយដល់ពេលអញ្ចឹងអ៊ុំ
ដោយសារនៅក្នុងវត្តកកោះហ្នឹងគឺ
កន្លែងដាំមនុស្សងាប់ច្រើនតែម្តង!ខ:ថ៎!ក:ហើយដល់ពេលអញ្ចឹងអ៊ំ
អ៊ំមានដែលមានផ្ទាល់ភ្នែកទៅឃើញថាគេ
យកមនុស្សទៅឬក៏អត់?

ខ:ឃើញតើ!ឃើញអញ្ចឹងប៉ុន្តែយើងអត់ហ៊ានទេណាស់
យើងឃើញបណ្តើរទៅចូលក្នុងព្រៃទៅហើយយើងអត់
ហ៊ានទេគ្រាន់តែលបមើលគេទេព្រោះកុំអោយគេឃើញណាស់!តែគេឃើញគេយកយើងដាំចោល
ដែរហើយព្រោះ
យើងថាយើងហ្នឹងខ្ចាំងលបមើលគេអញ្ចឹងយើងអត់ហ៊ានទេមីអូន
ខ្ញុំមើលឃើញច្បាស់នឹងភ្នែកបានខ្ញុំហ៊ានថា ឃើញ
ឃើញអញ្ចឹងនាំគ្នាទាញដៃមកវិញហើយអត់ហ៊ាននៅមើលនៅឈរមើលគេទាញយើងយកទៅដាំ
ចោលឥឡូវហ្នឹង

ណាស់

សុខចិត្តគេចខ្លួនមកខ្លាចណាស់មីអូនណាស់កាលពេលហ្នឹងយើងនៅស្ទើរដែរមាននៅក្នុងកងនារី 77 វារាង

ស្ទើរដែរណាស់ ចាំលបមើលគេមើលគេគេយកបណ្តើរយកទៅអញ្ចឹងទៅបណ្តើរទៅ

ប្រែនអើយប្រែនមិនដឹងគេមិន

ដឹងយើង !មិត្តអើយពួកម៉ាក់អើយមិនដឹងយ៉ាងម៉េចទេហា

មិនដឹងយើងមិនដឹងទេទេអាណិតណាស់លោកអើយមិន

ដឹងអាណាគេមិនដឹងបង មិនដឹងប្អូនយើងទេ ។

ក:មើលអត់ស្គាល់ទេអ៊ំហេ?

ខ:ស្គាល់យើងស្គាល់ដូចថាខ្ញុំស្គាល់ស្រពិចស្រពិលអញ្ចឹងណាស់!យើងម៉េចនឹងស្គាល់ឃប់ពីណាពីណីមកប៉ុន្តែ

គ្រាន់តែឃើញគ្នាអញ្ចឹងវាអាណិត។

ក:ជួយក៏អត់បាន ក៏អត់អី?

ខ:ចុះជួយឯណា ទៅជួយអោយគេវ៉ៃងាប់គេវ៉ៃដោយយើងដែរ។

ក:ហើយពេលហ្នឹងប៉ុន្មានបណ្តើរទៅនឹងឈ្លបហ្នឹងអ៊ំអើយ ?

ខ:ឈ្លបហ្នឹងតូចតូចអាយុ 16ឆ្នាំ 17 ឆ្នាំអីហ្នឹងណាស់!វាយកតែអ្នកអត់ចេះទេ 16ឆ្នាំ
17ឆ្នាំស្តាយកាំភ្លើងណោះ
ហៀរដីហ្នឹងណាស់ 16ឆ្នាំ 17ឆ្នាំណាស់។

ក:ហើយអ៊ំដល់ពេលហ្នឹង ឥឡូវកុំនិយាយមករំលងហួសបន្តិចដល់ពេលបែក
ប៉ុលពតពេលចប់សង្គ្រាមគេយកពួក
អាដែលសំលាប់គេទៅឯណាវិញទៅអ៊ំហេ?

ខ:វារត់ខ្ទេច វាដឹងវារត់អស់រលីង
បើជំនាន់ពេលខ្ញុំបែកខ្ញុំបែកហ្នឹងណាស់មីអូនណាស់នៅខ្ញុំនៅវត្តកកោះហ្នឹងវា
គ្រាន់តែថាផ្ទះឯងរបស់អ្នកណាទៅគ្រប់គ្នាទៅវារត់បាត់វារត់ទៅអស់រលីងអត់មានលុយទេមីអូនវា
ដឹងខ្លួនវាវារត់
ចោលអស់រលីងហើយ ។

ក:ចុះមានអ្នកណាគេដែលអ៊ំស្គាល់ដែរឬក៏អត់?

ខ:អត់!

ក:វារត់ទៅឆ្ងាយចឹងទៅអ៊ំហេ?

ខ:ចា៎!វាគ្រាន់តែប្រាប់ខ្ញុំថាផ្ទះអ្នកណាម្នាក់ឯងទៅផ្ទះអ្នកនឹងគ្រប់គ្នាទៅ

ផ្ទះនៅឯណាកន្លែងណាទៅទីណាទៅទៅ

ផ្ទះគ្រប់គ្នាទៅ

គ្រាន់តែប្រាប់ប៉ុណ្ណឹងវាទៅបាត់អស់ហើយវាអត់កុហកយើងមិនឃើញវាទៀតផង!អត់មានឃើញវា

ទៀតទេ!នាំគ្នាប្រមូលឆ្នុក ប្រមូលឆ្នុងដាក់ខោអាវមកផ្ទះដើរតាមផ្លូវរហូតស្ងាត់ឈឹងមីអូន ខ្ញុំប្រាប់

ស្ងាត់ថា ចុះ

ចាស់ចាស់ថាមានផ្ទះអត់មនុស្សនៅ ដើរម៉្លេតស្ងាត់ឈឹងដើរតាមផ្លូវហ្នឹងមករហូត

ហត់ឈប់ហត់ឈប់។

ក:ប៉ុន្មាននាក់ពួកម៉ាកទៅអ៊ំ?

ខ:តែពីរនាក់ពួកម៉ាកហ្នឹង ហើយជិតស្និទ្ធ។

ក:ឈ្មោះអីគេទៅ?

ខ:ប្រែន ។

ក:ហើយចុះមួយទៀត តែពីរនាក់អ៊ំតើហី?

ខ:តែពីរនាក់តែពីរនាក់ខ្ញុំហ្នឹង។

ក:ហើយម៉ែឪគាត់មីងប្រែនទៅណាអស់ទៅ?

ខ:ស្លាប់អស់ហើយ!

ក:ឥឡូវមីងប្រែននៅរស់អត់?

ខ:នៅរស់តើ!

ក:ហ្ន៎បាន 2 នាក់ហ្នឹង ឥឡូវគាត់នៅប៉ែត?

ខ:នៅជិតផ្ទះខ្ញុំផ្ទះខ្ញុំជិតបងខ្ញុំហ្នឹង នៅខាងលិចផ្ទះរបស់ខ្ញុំ។

ក:ចេះបានពីរនាក់ហ្នឹងទៅកងកុមារជាមួយគ្នាអញ្ចឹងទេ?

ខ: ហ្នឹងនៅកងកុមារជាមួយគ្នា នៅកងនារី 77 ក៏ជាមួយគ្នាតែពីរនាក់ជិតស្និទ្ធជាងគេ។

ក:អញ្ចឹងអ៊ំនៅក្នុងពេលជំនាន់ប៉ុលពតហ្នឹងបានតែកងនារីផងបានទាំងកងកុមារផងធំទៅអ៊ំណោះ
?

ខ:ចា៎!

ក:គេបំបែកឲ្យទៅកងនារី!

ខ:គេបំបែកឲ្យទៅកងនារីធ្វើកងនារី 77។

ក:បានអ៊ំបែកធ្លាយទៅដល់ភ្នំស្រង់ហួសទៅដល់ភ្នំស្រង់ទៀតហេ?

ខ:ចា៎ហួសភ្នំស្រង់ទៀត។

ក:អ៊ំពេលនៅភ្នំស្រង់អ៊ំធ្វើអីខ្លះ?ខ:គេអោយស្ទូងគេឲ្យដកស្ទូងដកស្ទូងហ្នឹងងមីអូនអើយឈ្លើង
ដករត់ដករត់ធ្វើ
យ៉ាងម៉េចអោយបាន មួយផ្លូន អោយតែក្នុងមួយព្រឹកហ្នឹងអោយតែបាន 1ផ្លូនក្នុងមួយថ្ងៃ
ស្ទូងមួយថ្ងៃ។

ក:ហ៊ឹៗ!ងាប់ហើយ។

ខ:ដករត់ដករត់ ខ្ញុំឯងរឿងឈ្លើងងាយអី!

ក:ហើយមានដែលទាម?

ខ:ខ្ញុំអត់ដែលទាមទេ ទឹមតែទាមមួយដងខ្ញុំរត់រត់ចង់បាក់ករ រត់ទៅត្រដុសគេតែម្តងទាល់តែជ្រុះត្រដុសទាល់តែជ្រុះ

អោបឡើងខ្ញិត ត្រដុសទាល់តែជ្រុះ ទាល់តែជ្រុះឈ្លើង!

ក:ហើយអាឈ្លើងអ៊ំយកទៅកប់ចោលឬក៏យកធ្វើអីគេ?

ខ:ហ៊ឹកប់រិតតែរស់ បើយើងដាក់បន្ទាក្រសាំងអញ្ចឹងដោតវាអញ្ចឹងទៅវានេះទៅ ងាប់។

ក: អោយវាត្រូវថ្ងៃ?

ខ:អោយវាត្រូវថ្ងៃងាប់ហើយ ហើយបើថាយកទៅកប់ដូចអោយវារស់វិញអញ្ចឹងអត់បានទេ ។

ក:ទោះប៉ុន្មានកង់ក៏ដោយអ៊ំហេ?

ខ:ទោះជាប៉ុន្មានកង់ក៏ដោយ។

ក:ក៏វារស់វិញ?

ខ:ក៏វារត់រកជួបគ្នាវិញដែរ!

ក:ហ៊ឺ!

ខ:ឈ្លើងអត់បានទេ!

ក:ចំអាសត្វហ្នឹងសាហាវម្ល៉េះអ៊ំ?

ខ:ថ៎!ដល់តែនៅវត្តកកោះហ្នឹងមួយខែជាង
បានបែកជំនាន់បែកនិងគេថាផ្ទះអ្នកណាទៅផ្ទះអ្នកហ្នឹងទៅ គេថា
អ្នកឯងទៅផ្ទះទៅផ្ទះនាក់ឯងនៅកន្លែងណាទៅកន្លែងនឹងវិញទេ
ដើរមកកំសត់ពីរនាក់អាប្រែនហ្នឹងដើរមកដើមមកស្ពាយ!
ប្រែនថាមកគោះហ្អែងយកឆ្នាំងយកចានហី?ខ្ញុំថាខ្ញុំអត់យកទេហ្អែងយកមិញយកទៅ
អញអត់យកទេអញស្ពាយអត់រួចដើរតាមថ្នល់មកអញហត់ណាស់ អញទៅមិនរួចទេ
មីនោះវាស្រវាតរកតែយក
ចុះឆ្នាំងចាននៅពេញវាលវាចុះរត់ទៅអស់ទៅនាំគ្នាស៊ីបាយស៊ីបាយហើយបានវាប្រាប់ស៊ីបាយហើ
យបានវាប្រាប់ យើងនៅធ្វើការយើងអត់ទាន់ប្រាប់ទេ។

ក:វាប្រមូលគ្នាយ៉ាងម៉េចទៅអ៊ំបានគេហៅមកប្រាប់ហ្នឹង?

ខ:វាប្រាប់តែម្នាក់ទេ?

ក:ហើយក៏ប្រាប់តគ្នា?

ខ:ពួកហ្នឹងរត់អស់ហើយ ចុះយើងប្រាប់តគ្នាទៅ!តោះយើងទៅផ្ទះគេអោយទៅផ្ទះហើយ
តោះតោះយើងទៅផ្ទះ។

ក:អ៊ំអើយ ពេលនឹងកំពុងធ្វើការ
អាហ្នឹងកំពុងនៅអារម្មណ៍ភ័យនៅឡើយប៉ុន្តែនៅពេលឮគេឲ្យទៅផ្ទះហ្នឹងសប្បាយ
ចាប់ផ្តើមហើយហេ?

ខ:សប្បាយនឹងណាស់!

ក:ប៉ុន្តែសប្បាយណាយភ័យអ៊ំហេ?

ខ:ថ៎!សប្បាយណាយភយ័បើវាឲ្យទៅផ្ទះហើយមិនភ័យ!

ក:ដឹងទេគេយកទៅសម្លាប់ចោលមិនដឹងមានរឿងអីមិនដឹងមានរឿងអីគេកើតឡើងអ៊ំហេ?

ខ:ថ៎មិនដឹងមានរឿងអីកើតឡើងមិនដឹងគេយកទៅសម្លាប់ចោលមិនដឹងអី
ប៉ុន្តែអរផងភ័យផងអរផងភ័យផង

និយាយពីចេញដើរមកមីអូនណាស់ទម្រាំមកដល់ផ្ទះឈប់មិនបានប៉ុន្មានដង

ចុះយើងតាំងតែពីគិតមើលទៅតាំងពីរ

នេះមកតាំងពីខាងក្រោយវត្តកកោះហ្នឹងមក។

ក:ចា៎!ហើយអ៊ំពេលនឹងបាយឆ្អែតហើយអស់ហើយនឹងមែនទេ?

ខ:ហើយអស់ហើយ យើងធ្វើការព្រឹកយើងធ្វើការព្រឹកចឹងម៉ោង 11

ស៊ីបាយមកស៊ីបាយបានវាប្រាប់ ខ្ញុំមកតែមួយ

នាក់ទេមកប្រាប់ថាផ្ទះបងប្អូននៅឯណាទៅឯហ្នឹងរាល់ខ្លួន អញ្ចឹងគេទៅបាត់ហើយ

គេអត់នៅជាមួយយើងទេបើគេ

ដឹងជើងការអស់ហើយ!

ក:ចា៎!គេដឹង!

ខ:គេអ្នកធំធំគេដឹងអស់ហើយ!

ក:វាដឹងតែរកព្រះរឃូសណាស់!

ខ:វាដឹងតែរកព្រះរឃូសរបស់វាហើយវារត់ចូលព្រៃអស់ហើយ។

ក:ហ្នឹងហើយបើអ្នកខ្លះក៏នេះដែរអ៊ំហេ

អ្នកណាបាញ់តបតអ្នកខ្លះវិញរត់ធ្វើធម្មតាថាអត់ដែលសម្លាប់គេ!

ខ:ចា៎ វាធ្វើធម្មតារបស់វាវាធ្វើដូចជាប្រជាជនឯងចឹង។

ក:តែបើសិនជាមានអ្នកណាគេស្គាល់មុខឥវ៉ាន់ហ្នឹងក៏ចប់ដែរ។

ខ:កាំភ្លើងឥវ៉ាន់វាលាក់វាឡោញអស់ហើយអត់មានទុកនូវស្លាយ បើវាដឹងហើយ

អ្នកធំតែវាដឹងវាប្រាប់គ្នាវាហើយ

ដល់អញ្ចឹងបានវាមកប្រាប់កូនចៅថាឥឡូវផ្ទះម្នាក់ឯងនៅឯណាទៅទីនឹងរាល់ខ្លួន។

ក:អ៊ំពេលហ្នឹងនៅកន្លែងអ៊ុំធ្វើការហ្នឹងពួកឈ្លបពុកអីហ្នឹងច្រើនទេ?

ខ:នៅណែន ពួកនារី 77

នៅដោយខ្លួនពួកនារីធំធំនៅដោយខ្លួនពួកយុវជនធំនៅដោយខ្លួនប៉ុន្តែនៅទីហ្នឹងទាំងអស់។

ក:ពួកឈ្លបហេ?

ខ:អត់ទេ!

ក:ពួកយើងធម្មតា?

ខ:ពួកយើងធម្មតា។

ក:ប៉ុន្តែដល់ពេលពួកអាខូចខូចសម្លាប់មនុស្សនោះមានច្រើនដែរឬក៏អត់អ៊ុំ?

ខ:អាហ្នឹង ហ្ន៎នៅពេញវត្តកកោះវានៅពេញវត្តកកោះ។

ក:ដូចវានៅចាំតែសម្លាប់ហើយអ៊ុំ!

ខ:វាមានវាមានមកនៅញែមញ៉ុមធ្វើការដូចយើងឯណាវាចាំតែសម្លាប់តែម្តង។

ក:ប៉ុន្តែដល់ពេលអ្នកដើរមើលដើរមើលអ៊ុំដែលមើលអីមានផ្សេងទៅ?

ខ:ផ្សេង មានផ្សេងអាហ្នឹងដូចថាពួកឈ្លបអីដូចយើងធម្មតា
អាហ្នឹងអត់មានពួកសម្លាប់ទេគ្រាន់តែពួកឈ្លបដើរមើល
ធម្មតា ដើរមើលយើងធ្វើការធ្វើអីអញ្ចឹងទៅណាស់។

ក:ចា៎ ហើយអាណាធ្វើមិនធ្វើ!

ខ:អាណាធ្វើមិនធ្វើ អាណា ខ្ជិលអាណាអីអញ្ចឹងវាចាំរាយការណ៍ អាហ្នឹងអញ្ចឹង។

ក:អើយសាហាវណាស់ពួកអារអស់នេះ
ហើយដល់ពេលថ្ងៃដែលវាដឹងខ្លួននាំគ្នារត់ប្រផាសប្រភិងនាំគ្នារត់ទៅដល់
ណាណាក្នុងព្រៃ។

ខ:ពួកវារត់បាត់ វារត់មុនយើងអ្នកប្រជាជនទៅទៀត!ចាំតែមាននូវតើ។

ក:អ៊ំបែកសង្គ្រាមក
ដល់ពេលអាតេវៀតណាមចូលមកស្រុកទេសយើងពេញនោះថាមកជួយចាំមកជួយរំដោះចេញ
ពីជំនាន់ប៉ុលពតណាស់ អ៊ំនឹងផ្ទះហ្នឹងទេ?

ខ:ខ្ញុំនៅផ្ទះ។

ក:ហើយឃើញទាហានពេញអីឬក៏អត់អ៊ុំ?

ខ:ហ៊ីនិយាយពីពួកទាហានវៀតណាមចូលឡើងប្រក ឡើងណែនផ្លូវតែម្តងមីអូនណាស់
ឡើងណែនផ្លូវមើលទៅអា
យខៀវរំពឹកតែម្តងណាស់។

ក:ហ៊ឹៗ! សុទ្ធតែពួកវៀតណាមចូលមកបាញ់តែម្តងអ៊ំ?

ខ:ចូលមកបាញ់រះតែម្តង ចុះបើមិនបាញ់រះបើវាខ្លាចពួកប៉ុលពត បាញ់ពួកប៉ុលពត។

ក:ចា៎! ហើយវាមានប្រកាសប្រកាសប្រាប់ប្រជាជនឲ្យនៅឲ្យស្ងៀមអីឬក៏អត់អ៊ំ?

ខ:ប្រកាសតើប្រកាសប្រាប់តើ!

ក:ប្រកាសប្រាប់ថាម៉េចទេ?

ខ:វាថាមិនបាច់ទៅឯណាទេនៅតែផ្ទះទៅនៅអោយតែស្ងៀមទៅ!យើងមានចុះយើងនាំគ្នាមានរត់ទៅឯណាដែល
គ្រាប់ដូចបាអង្កាមអញ្ចឹងមីអូនណាស់ ថាអង្កាមយ៉ាងម៉េចគឺអញ្ចឹង និយាយពីថាព្រាវៗៗ ផាវៗៗៗ ផាវៗគប់ និយាយ
ពីចេញចេញអត់បានទេ។

ក:តែចេញត្រូវ?

ខ:ចា៎!ចេញត្រូវរបស់វានេះឥឡូវបើវៀតណាមបាញ់រះ!បាញ់ការពារ!

ក:ចា៎ហើយពេលហ្នឹងពួកអាទាហានប៉ុលពតមានបាញ់តអីឬក៏អត់អ៊ំ?

ខ:អត់ទេ!បើវារត់អស់ហើយបានបាញ់អីតរ។

ក:ហើយចឹងវាចាំបាច់បាញ់អីតរ?

ខ:បើមិនបាញ់គេខ្លាចពួកអាហ្នឹងវាលាក់ខ្លួនលាក់អី។

ក:ប៉ុន្តែពួកប៉ុលពតអត់មានអ្នកតាមផ្ទះប្រជាជនអីទេ?

ខ:អត់ទេអត់ទេវារត់ផាស់ជើងផាស់ដៃទៅបាត់អស់ហើយហ្នឹងវារត់ចូលព្រៃ
ចូលផ្សែងទៅណាទៅណីអស់ហើយ។

ក:អាខ្ញុះក្តាយខ្លួនធ្វើជាប្រជាជនធម្មតា!

ខ:ធ្វើធម្មតាអញ្ចឹងទេ!

ក:តែអត់ហ៊ានចូលស្រុកទេអាពួកហ្នឹងហ្ន៎?

ខ:អត់ហ៊ានទេ។

ក:ទៅកន្លែងណាដែលវាស្ងាត់!

ខ:ចា៎!

ក:អ៊ំដល់ពេលហើយដល់ពេលប៉ុន្មានថ្ងៃទៅបានវាស្ងាត់ដៀតណាមអីវ៉ាន់ហ្នឹងទៅ?

ខ:ដៀតណាមចូលបានប្រហែល!បានប្រហែលមួយអាទិត្យហេ!មួយអាទិត្យ។

ក:បានស្ងាត់ទៅវិញហី?

ខ:ចា៎!ចូលទៅដល់ព្រៃស្វាព្រៃអីអញ្ចឹងទៅណាស់
ថាចុងបំផុតហ្នឹងតែម្តងវាបាញ់រះរហូតខ្លាចពពកមានលាក់ខ្លួនអ
ញ្ចឹងទៅណាស់អញ្ចឹងវាបាញ់រះរហូតថាជាងអង្កាមទៅទៀត។

ក:អូយអ៊ំទិដ្ឋភាពពេលហ្នឹងណាស់!

ខ:អេវៗៗៗ!

ក:អញ្ចេកគិតមើលពីស្រុកខ្មែរមិនដឹងទាហានដៀតណាមប៉ុន្មានលាននាក់អ៊ំហេ??

ខ:មកមិនដឹងប៉ុន្មានណានទេមកមកមិនមែនចូលតែពត់សរហ្នឹងអី

មករះមកអញ្ចេះមកព្រៃលើមកពេញតែទាំងអស់

ហ្នឹងចូលគ្រប់កន្លែងហ្នឹងណាស់!រាប់រយរាប់ម៉ឺនរាប់សែនមនុស្សនឹងណាស់វាមករំដោះនិងណាស់

។

ក:ហើយពេលមកហ្នឹងវាមានយកអាហារយប់អីអោយប្រជាជនដែរឬក៏អត់អ៊ំ?

ខ:អត់ទេ!

ក:គ្រាន់តែមកបាញ់តែមួយមុខទេ?

ខ:ចាំម្លូបអាហារអីវាធ្វើតែគ្នាពីហូបហ្នឹង!វាយកមកឱ្យយើងទៅវិញ!បានគេរំដោះនិងបានអរចង់

ងាប់។

ក:ហើយពេលហ្នឹងបានអីហូបទៅនៅក្នុងផ្ទះសុទ្ធហ្នឹង?

ខ:ក្នុងផ្ទះយើងមានទិញប្រដាប់ប្រដាទុកហូប!

ក:ហ្អ៊ាមានទិញកើតទៀត?

ខ:ហ៊ីដូចមាន់មោញ្ឆរបស់យើងយើងមិនចេះធ្វើស៊ីទេហេ!

ក:ហ្អ៊ុ!

ខ:មាន់ចិញ្ចឹមបានចង់ងាប់ហ្នឹង!បងខ្ញុំតែនេះហើយមាន់ពីរមាន់បីទុកគ្រាន់ហូប។

ក:សាគួរទៅ!

ខ:សាគួរទៅគ្រាន់ហូប!អាលីងអញ្ចឹងទុកទៅ ក្រឡាក់អីអញ្ចឹងទៅយើងអាលីអីទុកទៅ ។

ក:ហើយអ៊ំពេលនៅផ្ទះនៅជំនាន់ដើមផ្ទះក្បឿងផ្ទះអីអញ្ចឹងដែរឬក៏យ៉ាងម៉េច?

ខ:អត់ទេអូនផ្ទះខ្ចមតើអូន។

ក:ហើយនៅតែក្នុងផ្ទះហ្នឹង?

ខ:ផ្ទះស្លឹកតើ!

ក:ហ៊ីត្រូវមួយគ្រាប់មកអត់រស់ទេ!

ខ:អត់ទេចូលត្រង់សេ វៀតណាមចូលហ្នឹងចូលនៅក្នុងត្រង់សេ បងខ្ញុំចូលក្នុងត្រង់សេហ្នឹងដែរ
តែបងប្រុសខ្ញុំដែល

គាត់អើតករមើលអញ្ចេះគេចាក់បណ្តោយគេថាយើងប៉ុលពត!

ក:ហ៊ីស្រីសោះហ្នឹង?

ខ:បងថ្លៃខ្ញុំ!

ក:បងថ្លៃ?

ខ:បងថ្លៃ ប្តីបងរបស់ខ្ញុំនៅខ្វាន់មាសហ្នឹង!

ក:អញ្ចឹងបានយកទៅរៀនស្អីគេ?

ខ:ថ៎!នៅរោងចក្រកែវ!

ក:រោងចក្រកែវហ្នឹងទៅ!ហើយបានប៉ុន្មានខែបានគេលែងមកវិញ?

ខ:3 ខែបង!មានបានចិញ្ចឹមប្រពន្ធកូនឯណា!គេអោយនៅ
3ខែនៅឯហ្នឹង!ខ្ញុំទៅច្រូតស្រូវច្រូតស្រូវនៅរោង

ចក្រកែវនិងណាស់ច្រូតស្រូវហើយបុកអង្ករមួកអាមួកដែកហ្នឹង បុកអង្ករមួកដែកនិហ្នឹងដាំបាយស៊ី។

ក:បានអាមួកបានអីហ្នឹងបានសល់ពីជំនាន់សង្គ្រាមអីទេអ៊ំហេ?

ខ:ថ៎!

ក:ធីសមកអញ្ចឹង!

ខ:ធីសមកអញ្ចឹងបានបុកទៅនៅនឹងផ្ទះជិតនេះនឹងផ្ទះអោងចក្រកែវហ្នឹងដែរហ្នឹងនៅមុខអោងចក្រកែវខ្ញុំបើយកនៅឯ
នឹងក៏បានដែរមីអូនប៉ុន្តែបងខ្ញុំឪខ្ញុំអីថាអញ្ចេកម៉ែខ្ញុំអីបានថាយើងទៅផ្ទះវិញទៅ
ស្អាត់ហើយទៅផ្ទះយើងវិញបើខ្ញុំនៅ
ហ្នឹងខ្ញុំក៏បានដែរផ្ទះហ្នឹងផ្ទះប៉ុនណាណី!

ក:ពេលនឹងគិតគូរអីនោះ!

ខ:អត់មានគិតគូរចង់បានអីរលីងបើខ្ញុំនៅហ្នឹងណាស់ត្រូវបានដីហ្នឹងបានផ្ទះហ្នឹងផ្ទះ 2!

ក:នៅទល់ឥឡូវ។

ខ:ផ្ទះនៅទន្ទឹមគ្នាពី។

ក:អ៊ំដល់ពេល ជំនាន់សង្គ្រាមដូចរបៀបថាអញ្ចេកអោយតែបានជីវិតរស់អត់ខ្វល់អី!

ខ:ចា៎មិនខ្វល់អីអត់មានខ្វល់អីទាំងអស់!

ក:ឃឿងទ្រព្យសម្បត្តិរកបានទៀត!

ខ:អត់ចង់បាន!ចា៎អត់ចង់បាន។

ក:ចង់បានតែម្តង!ខ:ចា៎!ក:ដោយសារគិតមួយថាមកជួបជុំបងប្អូននៅស្រុកកំណើតខ្លួនឯងវិញ
!

ខ:ចា៎នៅស្រុកកំណើតខ្លួនឯងវិញ ងាប់និងជានៅផ្ទះនៅស្រុកយើង។

ក:ហ្នឹងហើយភាគច្រើនខ្សែរយើង
ច្រើនតែច្រើនជាងធម្មតាដូចថាក្តីស្រលាញ់អីទ្រព្យសម្បត្តិអីដឹងហើយថាទោះ
យ៉ាងម៉េចក៏រកបានវិញទៀតដែរអញ្ចឹងអ៊ំណាស់!

ខ:រកបានវិញទៀតអត់ចង់បានអីទាំងអស់ ឲ្យតែរួចជីវិត។

ក:ហ្នឹងហើយ។

ខ:ហើយបើងាប់ ងាប់ក្នុងស្រុក។

ក:ហ្នឹងហើយ!

ខ:កុំអោយងាប់ស្រុកគេ។

ក:អោយអស់ចិត្តបិទភ្នែកជិតទៅ!

ខ:ថ៎!

ក:ថ៎អញ្ចឹងអ៊ំពេលបែកសង្គ្រាមពេលវៀតណាមចូលមមកអញ្ចឹងទៅអ៊ំរៀបការនៅក្នុងជំនាន់ណា
ទៅវិញស្វាមីរបស់
អំពី 1ហ្គ៎?

ខ:ខ្ញុំប្តីខ្ញុំមុនហ្នឹងហេ?ក:ថ៎!ខ:ខ្ញុំធ្វើស្រូវបានពីរឆ្នាំបានពីរឆ្នាំបានគេមកស្តីទៅអីហ្នឹងអញ្ចឹងបាន
ការ ខ្ញុំអាយុ
18 ឆ្នាំ !18 កាលពេលហ្នឹងណាស់ !

ក:ហ្នឹងហើយ!

ខ:18 ឆ្នាំ។

ក:ហើយប្តីទី 1 គាត់ឈ្មោះអីគេទៅវិញគាត់អ៊ំ?

ខ:ឈ្មោះប្រែម។

ក:អីគេប្រែម?

ខ:ណាវប្រែម។

ក:ណាវប្រែម!ខ:ចា៎!ក:ឥឡូវគាត់នៅរស់ដែរឬក៏អត់អ៊ំ?

ខ:គាត់ស្លាប់ហ្នឹងហើយ!គាត់ស្លាប់បានខ្ទុំយកឪវាទៀតហ្នឹង!

ក:ហ្អ៊ុ!អញ្ចឹងដោយសារប្តីរបស់គាត់ស្លាប់ទេអញ្ចឹង?

ខ:ចា៎!

ក:គាត់ស្លាប់ថីអ៊ំ?

ខ:គាត់ឈឺ។

ក:ហើយបានតែបងភាពតើអ៊ំ?

ខ:ថ៎!បានតែអាភាពមួយ។

ក:ឥឡូវបងភាពដូចជាជ្រូក!

ខ:ដូចជ្រូក!

ក:ឡើងកាម៉ាប់ម៉ាប់!ធឹកពេកអ៊ំបានជាធាត់ម្ល៉ឹងម្ល៉ឹង?

ខ:ហ៊ីអាហ្នឹងធឹកតែរហូតហ្នឹង!ប្រាប់ថាកូនឯងតមខ្លះទៅបើពោះរបស់ឯងម្ល៉ឹង
តមធឹងតមស៊ីខ្លះទៅកូនណាស់!

ក:មិនមែនកើតអីឯណាអ៊ំហេ?

ខ:អត់ទេប៉ុន្តែវាអញ្ចេះវាដួលម៉ូតូ វាដួល ម៉ូតូបាក់ជើង បាក់កន្លែងនេះបាក់អស់ 2
កំណាត់កជើងនេះហ្នឹងត្រឹមនេះ

ត្រឹមនេះណាស់!

ក:ថ៎!

ខ:ដល់អញ្ចឹងទៅទៅទៅគ្រូខ្មែរគេថាទៅគ្រូខ្មែរគ្រូខ្មែរអត់មានទៅពេទ្យទៅរកគ្រូខ្មែរកគ្រូខ្មែរហ្នឹង
យកមកអបចឹងទៅ
វាដូចថាឆ្អឹងនិងវាចង់ជ្រុះណាស់វាយំឈឺអញ្ចឹងទៅបានទៅមើលយាយសេកនៅឯលិចឯណោះមើ
លយាយសេក
យាយសេកថាអត់អីទេមកជួបយាយអត់អីទេអត់អីឯណាអាភាពគិតតែពីកាច់ករកាច់ស្រង់ចូលណា
ស់ដល់អញ្ចឹងទៅ
រកគេមើលទៀតទៅគេថាអត់កើតទេទាល់តែសែនព្រេនឱ្យវាបន្តិចទៅសែនព្រេងហើយអីហើយបា
នយកទៅពេទ្យ
ហ្នឹងទៅពេទ្យនិងវះយើងទៅបានដាក់ដែកហ្នឹង!

ក:ឥឡូវនៅដែកនៅនឹងជើង?

ខ:ដែកនៅនឹងជើងហ្នឹង ហើយដល់អញ្ចឹងទៅវាត្រូវថ្នាំដូចថាថ្នាំផ្សះថ្នាំអីអញ្ចឹងវាធាត់រហូតមក។

ក:ហ្អ៎អញ្ចឹងផងហើយសុំតែធឹក

អ៊ំអើយហាមទៅដោយសារកំពុងតែឈឺផងហើយធឹកម្ដឹងម្ដឹងទៀតតែខ្យល់ហើយ

អ៊ំ!

ខ: វាធឹកទៀតវាធាត់បណ្ដោយវាត្រូវថ្នាំណាស់!

ក:ថា៎!ត្រូវថ្នាំមីថាសេរ៉ូមអីថ្នាំផ្សះថ្នាំអីអញ្ចឹងទៅវាខ្វាក់និងបណ្ដោយកាលពេលមុនអត់សូវធាត់ទេ

!

ក:អ៊ំប្ដីទីមួយរបស់អ៊ំហ្នឹងគាត់ស្លាប់នៅអាយុប៉ុន្មានទៅវិញ?

ខ:គាត់ឆ្នាំខាលដែរហ្នឹង!

ក:ដំណាលគ្នា?

ខ:ដំណាលគ្នា!

ក:នៅដល់រាល់ថ្ងៃហ្នឹង៥៦ហើយអ៊ំណោះ?

ខ:៥៦!

ក:ដូចគ្នា!ហើយស្លាប់នៅប៉ុន្មានឆ្នាំ 1981 ឬក៏១៩៨២អ៊ំ?

ខ:ហ៎ ការពេលហ្នឹងដូចជាយូរដែរហើយនេះស្លាប់ហ្នឹង!

ក:មើលកាលពេលអ៊ំចេញពីប៉ុលពតប៉ុន្មានឆ្នាំការជាមួយគាត់?

ខ:បានធ្វើស្រូវបាន 2 ឆ្នាំ!

ក:1982។

ខ:ម៉ែខ្ញុំស្លាប់បានមុនណាស់!បានខ្ញុំការខ្ញុំធ្វើស្រូវបាន 1
ឆ្នាំម៉ែខ្ញុំគាត់ស្លាប់ហើយខ្ញុំម៉ែខ្ញុំស្លាប់បានមួយឆ្នាំហើយ
បានខ្ញុំការ!ញឹងការបានន 2 ឆ្នាំម៉ែខ្ញុំស្លាប់បាន 2 ឆ្នាំ។

ក:អញ្ចឹងឆ្នាំ 1983 បានអ៊ំការ?

ខ:ចា៎!

ក:ហើយដល់ពេលការបានហើយប៉ុន្មានឆ្នាំបានជាអ៊ុំប្រុសស្លាប់ចោល?

ខ:មើលខ្ញុំមកនៅថ្នល់ដាច់ចូលប្រហែលបាន 3 ឆ្នាំ!ឃើ3ឆ្នាំ 4ឆ្នាំប្រាំឆ្នាំហើយ!

ក:អញ្ចឹង 1987!ខ:ថ៎!ក:អញ្ចឹងបងភាពបានប៉ុន្មានឆ្នាំហើយអ៊ំ?

ខ:អាយុបាន 2 ខួប។

ក:ហ្ន៎បានពីខួបបានជាអ៊ំប្រុសស្លាប់ចោលហេ?

ខ:ថ៎!

ក:ok

អញ្ចឹងមើលនៅក្នុងសំបុត្រកំណើតរបស់បងភាពអញ្ចឹងអ៊ំពេលស្វាមីអ៊ំពេលមុនគាត់ឈ្មោះដូចជាអ៊ំបាន

និយាយប្រាប់ពេលមុនចឹង!

ខ:ប្រែម។

ក:ប្រែម!ហើយដល់ពេលហើយ!អ្នកនៅទីនេះអត់មានឈ្មោះរបស់បងភាពផងហ្នឹង!

ខ:គ្មានទេព្រោះវា

កាលពេលមុនមានប៉ុន្តែដល់ពេលវាបែកទៅវាមានប្រពន្ធទៅវាធ្វើសំបុត្រវាឯណោះទៅវិញណាស់។

ក:មួយវិញទៀតអញ្ចឹងទៅ!

ខ:ចា៎!

ក:ចា៎អញ្ចឹងចាំមើលពេលក្រោយសម្ភាសន៍បងទៀតបានដឹង!ហើយដល់ពេលអ៊ំស្វាមីស្លាប់ចោលចឹងទៅបាន

ប៉ុន្មានឆ្នាំបានរៀបការជាមួយនឹងអ៊ំអន?

ខ:បានរយៈប្រហែល 2 ឆ្នាំ 2

ឆ្នាំហោបានគាត់នេះស្លាប់ប្រពន្ធដែរបានទៅសួរខ្ញុំហ្នឹងណាស់!ក:ចា៎!ខ:មិនមែនទេទៅអញ្ចេក គាត់ទៅជាមួយពូសួនទៅជាមួយធំវ៉ាន ពុកអញ្ចឹងទៅណាស់

ទៅគាត់ទៅបុណ្យ បុណ្យនៅទាំងឬ

ស្បី ហើយទុកគោទុកអីនៅឯណាទៅហើយក៏ដើរទៅដើរទៅភូមិចាស់ហ្នឹងណាស់ទាំងឬស្បីហ្នឹងដល់អញ្ចឹងគាត់មក

គាត់ថាអត់ទឹកអត់អីអញ្ចឹង!ចុះពេលចំបក់និងអត់ទឹកយើងក្រទឹកណាស់

មកងូតទឹកងូតអីចាន់ថនហ្នឹង សួរខ្ញុំថា

មីងបើខ្ញុំស្រលាញ់មីងឯងព្រមឬក៏អត់?ខ្ញុំខ្ញុំអត់អីទេខ្ញុំប៉ុន្តែគ្រាន់ថាកុំកាន់ជើងកូនខ្ញុំនិយាយតែត្រង់ត្រង់ទេកុំកាន់ជើង

កូនធ្វើយ៉ាងម៉េចតែមានខុសមានស្គងខ្ញុំផ្ដាំបន្តិចបន្តួចកុំមិនថាអីថាវ៉ាន់អញ្ចឹងណាស់

ខ្ញុំនិយាយនិយាយត្រង់ត្រង់តែម្តង

ដល់ចឹងគាត់ថាអត់អីទេបើមីងឯងមានលុយអោយវាទៅបើអត់មិនដឹងធ្វើយ៉ាងម៉េចទេអាហ្នឹងអញ្ចឹងណាស់ ខ្ញុំថាខ្ញុំ

មានលុយអោយហើយបើខ្ញុំអត់មិនដឹងធ្វើយ៉ាងម៉េចទេ

បានតែមួយហួបបាយហួបពេលណាបើវាទៅរៀនទៅអីអញ្ចឹង

ចេះតែបិចបោចអោយវាចាយចឹងទៅណាស់ !ចុះមានអីចាន់ថន

ចាន់ធឿនវាដឹងចិត្តរបស់ខ្ញុំដែរហ្នឹង! មាន

ហើយអញ្ចឹងទៅបើអត់ក៏ហីទៅ!

ក:ហ្នឹងហើយអញ្ចឹងដល់ពេលអ៊ំឯណោះមានកូន 1អ៊ំធនមានកូនពីរ។

ខ:កូនពីរ!

ក:អញ្ចឹងក៏រៀបការជាមួយគ្នា!រៀបឬក៏ការរឺក៏អីដែរអ៊ំ?

ខ:រៀប!

ក:រៀបហេ?

ខ:ចា៎!

ក:គ្រាន់តែសែនព្រេនអញ្ចឹងទៅ?

ខ:ចា៎សែនព្រេនកាច់ខ្មោចអញ្ចឹងទៅណាស់!

ក:ចា៎!ហ្នឹងហើយហើយចាស់ទុំតាយាយមកដឹងឮអញ្ចឹងទៅ។

ខ:មកទាំងអស់!

ក:ហើយកាលពេលរៀបអ៊ំហ្នឹងរៀបនៅឯណា?

ខ:យាយសាន់យាយអីក៏ទៅនៅថ្ពល់ដាច់!

ក:នៅស្រុកកំណើតនៅផ្ទះហ្នឹង!

ខ:ចា៎!នៅផ្ទះខ្លួនឯង។

ក:ហើយអ៊ំពេលរៀបការមកជាមួយអ៊ំឆនមកយ៉ាងម៉េចដែលការរស់នៅជាមួយអ៊ុំសុខសប្បាយទេ

តើអ៊ុំហេ?

ខ:អត់អីទេកូនចៅអីដូចថាយើងដឹងចិត្តគ្នាយើងនេះអញ្ចឹងទៅធម្មតាមានឈ្លោះទាស់ទែងគ្នាបន្តិច

បន្តួចដែរអញ្ចឹងវា

ធម្មតាហើយអាហ្នឹង!

ក:ធម្មតា!អញ្ចឹងពេលអ៊ុំរៀបការហើយកូនប៉ុន្មានទៅវិញអ៊ំ?

ខ:កូនក្រោយហ្នឹងហេ?

ក:កូនក្រោយបានប៉ុន្មាននាក់?

ខ:កូនក្រោយបាន 4 នាក់ហ្នឹង។

ក:ថ៎កូនមុន!

ខ:កូនមីឆម មីសរ វណ្ណារ៉ា វណ្ណារី មីសរគេឈ្មោះវណ្ណារី

វណ្ណារ៉ាមីក្រញាញ់បានមកចាន់នីនឹងពៅគេ 4នាក់!

ក:ថ៎!ហាអ៊ំដល់ពេលបងភាពដាក់ត្រកូលតាប៊ិចដែរហេ?ខ:ហ៊ី!ក:ប៊ិច សុភាព។

ខ:ប្រាក់ថាដាក់ណារភាព

តែទៅដាក់ហ្នឹង!ឥឡូវថាភាពយកទៅធ្វើសំបុត្រនេះហ្នឹងមិនដឹងដាក់អីវាទៅវិញ!

ក:ថ៎!ប៉ុន្តែនៅក្នុងនេះដាក់ឈ្មោះប៊ិចភាពកើតនៅថ្ងៃទី 8 ខែ 1 ឆ្នាំ1980 !ហេហ៊ី!

ខ:អាយុ 30 ឆ្នាំជាងហើយ!38 39!

ក:ថ៎ហ្ន៎អ៊ំបែកពីជំនាន់ប៉ុលពតមកប្តីស្លាប់ចោលលឿនហ្នឹងអញ្ចឹងហេ??

ខ:ថ៎!

ក:អញ្ចឹងគាត់ស្លាប់82(1982)មិនមែន87 88នេះទេ។

ខ:ទាល់តែអាភាពបាន 2 ខួប ។

ក:ហ្នឹងហើយគាត់ស្លាប់ឆ្នាំ 1982ប្តីរបស់អ៊ំមុននោះ!

ខ:ហ្នឹង!

ក:ហើយដល់ពេលមើលខ្ញុំអាននៅក្នុងសំបុត្រកំណើតរបស់គ្រួសាររបស់អ៊ំពីកូនរបស់ទាំងប៉ុន្មាន
ទាំងនោះអញ្ចឹងអ៊ុំ
នៅក្នុងសៀវភៅគ្រួសារនិងបទឈ្មោះតែបងចាន់ធឿនមួយទេតែបងចាន់ថនបងភាពឥ៉ាន់មាននៅ
ក្នុងនេះទាំងអស់
ឈ្មោះស្វាមីរបស់ក្រោយឈ្មោះញ៉ែមឆនកើតថ្ងៃទី 10 ខែ 7 ឆ្នាំ 1952
នៅភូមិទន្លេបាទីឃុំក្រាំងធ្នង់ស្រុកបាទី
ខេត្តតាកែវហើយដល់ពេលកូនបងចាន់ថនក៏ឈ្មោះបុិច ចាន់ថនកើតថ្ងៃទី 10 ខែ 11 ឆ្នាំ
1981 នៅភូមិទន្លេបាទី
ឃុំក្រាំងធ្នង់ស្រុកបាទីខេត្តតាកែវដែរដល់ពេលនឹងហើយកូនប្រពន្ធមុនរបស់អ៊ំឆន
ដល់ពេលកូនរបស់អ៊ំទូចឈ្មោះ
បុិចសុភាពដាក់ត្រកូលរបស់តាដែរកើតនៅក្នុងថ្ងៃ8 ខែ 1 ឆ្នាំ 1980
នៅភូមិទន្លេបាទីឃុំក្រាំងធ្នង់ស្រុកបាទីខេត្ត
តាកែវដែរដល់ពេលមួយទៀតកូនរបស់អ៊ំជាមួយនឹងអ៊ំឆនវិញឈ្មោះបុិច ចម កើតថ្ងៃ 26 ខែ 3
ឆ្នាំ 1986 នៅ
ភូមិទន្លេបាទីឃុំក្រាំងធ្នង់ស្រុកបាទីខេត្តតាកែវបន្ទាប់មកទៀតឈ្មោះបុិច វណ្ណារីកើតនៅថ្ងៃទី12ខែ
8 ឆ្នាំ 1988
នៅភូមិទន្លេបាទីឃុំក្រាំងធ្នង់ស្រុកបាទីខេត្តតាកែវមួយទៀតឈ្មោះបុិច វណ្ណារ៉ាកើតនៅថ្ងៃទី 9 ខែ
7 ឆ្នាំ 1993 នៅភូមិទន្លេបាទីដែរហើយមួយទៀតឈ្មោះបុិចចន្ធីទី 25ខែ3 ឆ្នាំ 1997
នៅភូមិទន្លេបាទីដែរ។ចាំហ្នឹងហើយគឺជា
ឈ្មោះកូនរបស់អ៊ំទាំងអស់ហ្នឹង។អ៊ំឥឡូវបងចមទៅឯណាបាត់ហើយ?

ខ:ចមនៅទីហ្នឹងទេតើ!

ក:នៅផ្ទះនេះទេ?ខ:ថ៎!ក:ប៉ុន្តែខ្ញុំអត់ដែលឃើញផង។

ខ:អត់ឃើញមកពីវាមិនទាន់មកពីធ្វើការផងធ្វើការចេញម៉ោង 6!ក:ហ្ន៎!ខ:ចេញមក ម៉ោង6 ។

ក:ខ្ញុំខានឃើញយូរណាស់ហើយអ៊ំ!

ខ:នោះមិនកូនវាកូនប្រុសហ្នឹង!

ក: ថ៎!តែមួយហ្នឹងតើហេ!?

ខ: នឹងតែមួយហ្នឹង ឥឡូវពោះធំទៀតហើយ!

ក: អ៎! តែផ្ទះនៅជាមួយអ៊ុំទេ!?

ខ:នៅជាមួយតើនៅជាមួយ!វាធ្វើនោះទិញដីជិតផ្ទះចាន់ធឿនធ្វើរបងធ្វើអីហើយហើយឥឡូវកំពុងធ្វើបង្គន់បម្រុង

ថានឹងធ្វើផ្ទះខ្ទមមួយតូចនៅទៅណាពីរនាក់ប្តីប្រពន្ធរបស់វាហើយកូននៅវានឹងប៉ុន្តែឥឡូវវាអត់លុយ

បម្រុងថាធ្វើរបង

ធ្វើអីហើយអស់លុយទៅឥឡូវអស់លុយ

បម្រុងថាអាប្តីរកខ្ចីលុយម៉ែវាលុយបងថ្លៃវាខ្លះយកមកផ្ទះណាស់!បន្តិចទៀតវាបែកហើយតែគ្រាន់

តែថាគ្នាអត់មានអីធ្វើ ធ្វើស័ង្កសីធម្មតាតូចនេះឈើឪវាកាត់អោយហើយនេះហ្នឹងហើយគរ

នៅខាងក្រោយផ្ទះហ្នឹងហិ!ចេះតែធ្វើនៅសិនទៅ សិនអីនៅរហូតហ្នឹងទម្រាំយើងរកបានធ្វើផ្ទះធំ។

ក:ថ៎អ៊ំដល់ពេលប្តីចមឈ្មោះអីគេទៅវិញ?

ខ:ឈ្មោះថនឈ្មោះដូចថាន់ថន!

ក:ឥឡូវអាយុប៉ុន្មានហើយ?

ខ:ឆ្នាំថោះ!

ក:ឆ្នាំថោះ។

ខ:ឆ្នាំថោះអាយុដំណាលគ្នាពីរនាក់ហ្នឹង។

ក:អាយុ 30 ឆ្នាំហើយហ្ន៎!

ខ:32ហើយ។

ក:ដល់ពេលមកប្តីរបស់វណ្ណារីក្រញាញ់ក្រញាញ់អត់ទាន់មានប្តីទេមែនទេ?

ខ:ថ៎!

ក:ត្រងោល!

ខ:ត្រងោលមីសរ!

ក:ហើយហើយដល់ពេលឥឡូវបានប្តីអាយុប៉ុន្មានហើយ?

ខ:មីសរហេ?

ក:ថ៎ដីនៅឯណា?

ខ:មីសរ៣០ប៉ុន្មានទេនេះមីសរមិនដឹង 30 ប៉ុន្មានទេ!វាខ្ទង់បន្តិចបន្តួចបន្តិចបន្តួច។

ក:អញ្ចឹងដកតាមហ្នឹងទៅហ្ន៎!

ខ:ដកតាមហ្នឹងទៅ!

ក:ហើយចុះដល់ពេលប្តីត្រងោលអ៊ំហេ?

ខ:ហៅមីស្រីសរ!

ក:ស្រីសរ!ហើយដល់ពេលក្រញាញ់ ក្រញាញ់!ហ្នឹងហើយហ្នឹងហើយ

ងារបងភាពជាអ្នកដាក់ឲ្យ!ពីរនាក់និង

អ្នកណាគេអត់ទាន់មានប្តី?

ខ:វណ្ណាវ៉ាហ្នឹងអត់ទាន់មាន។

ក:វណ្ណាវ៉ា។ វណ្ណារីបាន់មានប្តី។

ខ:មានប្តី!

ក:ប្តីឥលូវអាយុប៉ុន្មានហើយប្តី?

ខ:ប្តីវាបងវាប៉ុន្មានបងវាបីឆ្នាំបួនឆ្នាំឯណោះកូនខ្ញុ!ឈ្មោះខ្ញុ!

ក:ឈ្មោះខ្ញុ?ខ:ថ៎!ក:ត្រកូលអីគេអ៊ំចាំទេ?

ខ:ត្រកូលវាតាអី!យាយអ៊ូច ស្គាល់តែឈ្មោះយាយ តាដូចជាភ្លេចតាតារបស់វាឈ្មោះតាអីទេ តាភឹមហីអី!

ក:អត់អីទេអ៊ំបើសិនជាអត់ចាំ!

ខ:នែតាកូនខ្ញុវឈ្មោះអី?(សួរទៅកាន់ប្តីរបស់គាត់)។

ស្វាមីរបស់គាត់:តាភឹម។

ខ:តាភឹម។

ក:តាភឹម។

ខ:ភឹម ខ្ញុ។

ក:ហ្អ៊ ឥឡូវធ្វើការដែរតើអ៊ុំណោះ?

ខ:ធ្វើការធ្វើការរោងចក្រធ្វើជាមួយកូនថនហ្នឹងប្តីមីចមហ្នឹង ធ្វើនៅរង្វង់មូលឯណោះ រង្វង់មូលក្បាលថ្នល់នេះ!

ក:តើនៅឯណាឯណីឯណោះ?

ខ:អើរ!

ក: ឆ្ងាយ?

ខ:អានៅកន្លែងដំបូលខៀវនោះ ដំបូលខៀវខាងលិចហ្នឹង!

ក:ហ៊ឺ"! ហ៊ូឆ្ងាយណាស់អ៊ំជិះទៅវិញទៅមក។

ខ:ទៅវិញទៅមក។

ក:ដល់ពេលពៅគេចាន់នីចាន់នីឥឡូវប្តីនៅឯណា?

ខ:ប្តីនិងនៅកណ្តឹងប៉ុន្តែប្តីហ្នឹងខឹងចាន់នីឈ្លោះជាមួយចាន់នីរត់ទៅ 3ឃប់4 ហើយ
៥ឃប់ហើយ!

ក:ប៉ុន្តែមិនមែននេះឯណាមូលគ្នា?

ខ:ជិះកង់ទៅយកកង់ឯងទៅឥឡូវរត់បាត់ទៅចន្ទីអត់អោយម៉ូតូទៅចន្ទីថាបើយកម៉ូតូទៅអញបានអី
ជិះទៅធ្វើការ

ហើយវាអត់ធ្វើការអញ្ចឹងវាជាដើរលេង!មុនវាធ្វើការប៉ុន្តែដល់ឥឡូវហ្នឹងវាអត់មានការងារធ្វើ!អាងចក្រគេឬទាល់តែ

យើងចេះបើអត់ចេះទៀតអត់យកទេ។

ក:ចាំហើយអញ្ចឹងបានអីគេទៅ អ៊ំ?

ខ:ឥឡូវនៅតែផ្ទះនៅតែផ្ទះម៉ែវាហ្នឹងវាអត់ធ្វើអីឥឡូវវាទៅផ្ទះម៉ែវាទៅនៅកណ្តឹងជិតភ្នំតាម៉ៅឯណោះ!

ក:ឈ្មោះអីគេទៅវិញ?

ខ:ផ្លូវទៅភ្នំតាម៉ៅកណ្តឹង។

ក:លោកកូនអីគេទៅវិញអ៊ំ?

ខ:ឈ្មោះណាក់ ឈ្មោះញ៉ែមដែរហ៎! ញ៉ែ ណាក់ដែរហ៎?

ក:ត្រូវបងប្អូនដែរឬក៏អត់?

ខ:ជីតារបស់វាឈ្មោះញ៉ែម!ត្រកូលយាយនែនអីសុទ្ធញ៉ែមដែរតើ!

ក:ចប់ខ្សែខាងយើងដែរឬក៏អត់?ខ:អត់ទេអត់ជាប់ទេ។

ក:តែគ្រាន់តែឈ្នះដូចគ្នា!

ខ:គ្រាន់តែឈ្នះគ្នា។

ក:ហ្ន៎អញ្ចឹងញ៉ែមណាក់។

ខ:ញ៉ែម ណាក់។

ក:ហើយចុះដល់ពេលអត់ទាន់ពេលមកចូលស្តីដណ្តឹងមានការងារមានអីត្រឹមត្រូវទេ?

ខ:វាចូកខ្សាច់ចូកអីដាក់ឡានជាមួយប៉ាវាជាមួយឪវានឹងណាស់!វាចេះតែធ្វើនៅឯណោះអញ្ចឹងទៅ
ល្ងាចឡើងវាមកឯ
ណោះមក
មកដល់ឥឡូវនិងខ្សាច់គេលែងដូចថាយើងចូកដាក់ឡានវាយ៉ាប់ដែរហ្នឹងណាស់ដល់អញ្ចឹងគេលែង
ទិញ
លេងអីទៅដល់អញ្ចឹងគេដឹកអាឡានធំធំវិញវាអត់លែងបានធ្វើទៅ
អញ្ចឹងចាន់នីនឹងចេះតែនេះទៅវាធ្វើការនៅកន្លែង
តាសុខអានលិចនេះធ្វើបានប្រហែលបីទៅបួនប្រាំខែហ្នឹងហើយថាពិបាកឈប់ទៀតទៅចូលអាងច
ក្រទៀតអាងចក្រ
នៅឯជិតសំអាងយ៉ាងនេះអាងចក្រអា 3 ជាន់ខាងលិចនឹងណាស់ធ្វើទៅខាងផ្លែសន្ទូច
ធ្វើទៅគេដាច់ចង់អាណិត្តគេ

គេដកទៅភ្នំពេញវិញគេឈប់ធ្វើនៅទីនេះគឺដល់ទៅភ្នំពេញវិញណាស់ធ្វើនៅភ្នំពេញបានប្រហែលពីរអាទិត្យមកផ្ទះហ្ន៎

នឹកច័ន្ទណាតណាស់កូនគេឈ្មោះចាន់ណាត

គេមិនមែនឈ្មោះខ្ចៅទេឈ្មោះចាន់ណាត!នឹកច័ន្ទណាតណាស់អត់

ចង់ទៅទេក៏លែងទៅវិញទៀតទៅឥឡូវអត់ការងារធ្វើ។

ក:ឥឡូវទៅចោលកូន?

ខ:អើរឥឡូវទៅទៅរឹង!ទៅផ្ទះអត់មានឮកកូនទេ!

ក:តែដល់ពេលធ្វើការ!

ខ:ដល់ពេលធ្វើការនឹករាលល្បិច!

ក:ចង់យ៉ាងម៉េច មិនមែនឈ្លោះគ្នាដល់ថ្នាក់លែងឯណាគ្រាន់តែខាងគ្នាតើអ៊ំ?

ខ:អត់ទេគ្រាន់តែខាងគ្នាឈ្លោះគ្នាអត់អីទេតែរារកតែលែងគ្នាប៉ុន្តែខ្ញុំថាគិតឲ្យម៉ងបើថាគិតខ្លីកុំតែលែងគ្នាហើយផ្តិតមេ

ដៃហើយតែមួយគ្នាវិញណាស់ប្រយ័ត្នគិតឲ្យវែង!

ក:ប៉ុន្តែដោយសាររអ៊ូកអ៊ំលេងគ្នាធ្វើស្អីគេមានអ្នកណាគេស្តាប់មួយផងហ្នឹងហើយលែងធ្វើអីគេបើសិនជាទៅយក

ប្រពន្ធផ្សេងទៀតទៅយកប្តីទៀតនៅតែធ្វើការដើម្បីចិញ្ចឹមគ្នាទៅវិញទៅមកដដែលហ្នឹង!

ខ:ដដែលហ្នឹង!

ក:ចាំបាច់អោយកូន!

ខ:កំព្រីកំព្រា!

ក:ហ្នឹងហើយមានឪ1 ម៉ែមួយស្អីគេទៀតអញ្ចឹងចង់ថែមអីទៀត។

ខ:ទៅមានឪឯណាខុសពីហ្នឹងទៀត!

ក:ហ្នឹងហើយដោយសារត្រូវរកស៊ី។

ខ:ខ្ញុំមិនចង់អញ្ចឹងតើ
វាមិនចង់អញ្ចឹងបានខ្ញុំថាឥឡូវគិតឲ្យដែងឆ្ងាយកុំគិតខ្លីជាប្តីប្រពន្ធមិនរួចទេខ្ញុំថាឲ្យចឹងណាស់
ទាំងពីរនាក់និងណាស់ កុំគិតអីលែងគិតអីលែង
ម៉ែឯងម៉ែឯងជួយគិតទៅមើលម៉ែឯងមិនស្តាប់ពាក្យកូនរបស់ម៉ែឯង
មើលគេថាអញ្ចឹងណាស់!អញស្តាប់បានមិនមែនអញស្តាប់មិនបានទេ
ហើយកូនឯងដឹងស្រាប់ហើយចន្ទី ផាច់ៗៗ
ឆាវ់ៗៗហើយហីទៅ!វាមាត់ចឹងទៅហើយ ដល់តែប្រាប់អញ្ចឹងវាអត់មាត់!

ក:ហ្នឹងហើយ!

ខ:អត់មាត់មួយសន្ទុះវាលែងមាត់លែងកររអញ្ចឹងទៅស្រាប់ឯងអាឡែងតែចូរដាំបាយដាំអីហ្នឹង!

ក:ទាញ្ចកង់ទៅបាត់ទៅ?

ខ:ទាញ្ចកង់ទៅបាត់ទៅ!

ក:ហ្នឹងហើយអ៊ំឯងប្រាប់អញ្ចេកពេលក្រោយថាអញ្ចេកថាកូនឯងប្រឹងរកការងារធ្វើទៅដោយសារ!

ខ:ហ៊ីឪវាប្រាប់ខ្ញុំប្រាប់រហូត
មិនមែនថាមិននិយាយទេកូនឯងគិតមើលគេទៅស្ងាត់អស់ហើយផ្ទះអញ្ចឹងកូនឯងខំរកស៊ីទាន់ខ្លួន
នៅក្មេងណាស់តែយើងចាស់ទៅដូចជាខ្ញុំដូចចាស់ចឹងណាស់រកអីរំពឹងអីមើលតែចៅនេះ
ទៅណារួចគេ
មិនយកយើងយើងក្អែកងងឹតទៅហើយហ្នឹង។

ក:ហើយធ្វើការងារនៅកន្លែងដីសុខអានត្អួញពិបាកធ្វើអីគេទៅអ៊ំ?

ខ:អាហ្នឹងដូចថាយើងលាយដី ដាក់ដីតាមដួងណាស់!អាចម៍មាន់អាចម៍អីស្អុយងោងំហ្នឹងណាស់
ដាក់តាមដួងហ្នឹង
អោយគេអោយផ្តែណាស់!ក:ចា!ខ:ទៅមើលផ្តែ។

ក:ច្រើនតែម្តងអ៊ំហេ?

ខ:ផ្តែចង់បាក់ៗដើមឯណោះ!

ក:ប៉ុន្តែពាក់ម៉ាស់ពាក់អីអញ្ចឹងទៅវាអត់អីទេអ៊ំ!

ខ:វាពាក់ម៉ាក់ទេតើប៉ុន្តែគ្រាន់តែថា!ឃើអាមនុស្សខ្ជិលវាអាងតែទៅជួយតែម៉ែវាឯណោះ!

ក:ធ្វើអីគេទៅវិញ?

ខ:អោយតែនេះអីម៉ែវាតេហៅ!ធ្វើស្រែធ្វើអីហ្នឹងណាស់ចាំឌឹកចាំអីហ្នឹង!គ្រាន់តែចាំឌឹកក៏ហៅកូនឲ្យទៅចាំដែរ
ហើយកូនប្រសារនៅឯនិងមានមានដែរមិនប្រើមកប្រើតែអាណាក់!មកប្រើតែឌឹមីនេះ!

ក:តែបើសិនជាអោយទៅអញ្ចឹងទៅអោយលុយអោយអីទៅទុកចិញ្ចឹមចៅដូចជាមុខរបរឥវ៉ាន់ទៅវាមិនអីទេ!

ខ:វាមានអោយស្អីវាគ្រាន់តែឲ្យជួយហ្នឹង!

ក:ទទេគេត្រូវរកស៊ីចិញ្ចឹមកូនប្រពន្ធដែរ!

ខ:វាមិនសម!វាអត់សមទេ!អត់មានត្រូវការតេអោយកូនទៅជួយធ្វើអីឯណោះទេ!អោយវារកស៊ីចិញ្ចឹមប្តីប្រពន្ធវាឯ

ណារាល់ថ្ងៃហ្នឹងគឺខ្ញុំអត់ទាមទារអីទេ!ទាមទារថាឥឡូវនេះមើលចៅឥឡូវកូនម្នាក់អោយប៉ុន្មានអញ មើលកូនង៉ែង ង៉ែ

ងអោយប៉ុន្មានមើលកូនមីសរមើលកូនចាន់នីអោយប៉ុន្មានកូនចមអារ៉ប៉ុន្មានឲ្យមកម្តាយចាយទៅ។

ក:តិចៗម្នាក់អញ្ចឹងទៅ!

ខ:ហើយក៏ចិញ្ចឹមពួកអស់ហ្នឹងដែរ។ចិញ្ចឹមពួកវាដែរ ឲ្យមកហ្នឹងទិញម្ហូបអោយស៊ី ខ្លាចអត់ម្ហូប ផ្គត់ផ្គង់តែម្ហូបទេចំណី

ត្រីសាច់អីដូចថាបង្អែមបង្អោញអីទាល់តែថាកូនទិញមកឱ្យស៊ីបានបានពីរនាក់ឪវាហ្នឹង!មិនដែលថាឃើញកញ្ជើរបក់

ដៃហៅទិញស៊ីទេវាអត់មានលុយអញ្ចឹងកូនទិញយកពីរោងចក្រមកស៊ីទៅក៏ស៊ីទៅ!ផ្លែឈើអីស៊ីទៅ! មិនដែលថាហ្ន៎

កញ្ជើរអត់ហួសមួយអត់ទេ!ផ្គត់ផ្គង់តែម្ហូបទេមីអូនរាល់ថ្ងៃហ្នឹង!

ក:អញ្ចឹងអ៊ុំដល់ពេលស្វាមីមុនអ៊ំនៅផ្ទះឯណោះទេអញ្ចឹងហេ?

ខ:ណាខ្ញុំហេ?

ក:នៅផ្ទះចាស់ពីមុនហេ?ពេលការហើយនោះ?

ខ:កាលពេលរៀបជាមួយឪវាហើយហេ?

ក:មុននឹងមុននឹងប្តីមុននោះ?

ខ:ប្តីមុនហ៎?ក:ចា៎!ខ:នៅទាំងឬស្សីហ្នឹងតែម្តង។

ក:ចា៎!ហើយដល់ពេលយ៉ាងម៉េច អ៊ំបបួលយ៉ាងម៉េចបានមកនៅទន្លេបាទីឯណេះទៅវិញ?

ខ:ឪពុកក្មេកខ្ញុំស្លាប់ទៅនៅតែម្តាយក្មេកនៅតែ ម៉ែក្មេក
ម៉ែក្មេកហ្នឹងគាត់នៅជាមួយគាត់មិនសុខចឹងទៅណាស់ដល់
អញ្ចឹងទៅឪវា!អត់ទេគ្រាន់តែរៀបហើយមកតែម្តងខ្ញុំមកនៅនេះតែម្តងព្រោះខ្ញុំនៅជាមួយម្តាយក្មេក
យ៉ាងម៉េចនឹង
កើត!

ក:មកធ្វើផ្ទះនៅទីនេះតែម្តងអ៊ំហ៎?

ខ:អត់ទេ!

ក:នៅកន្លែងណាសិន?

ខ:ណោះផ្ទះដីតាចាស់ហ្នឹង ផ្ទះចាន់ថននៅហ្នឹង!

ក:ចា៎នៅឯផ្ទះចាស់មុនដែលមីងសយមីស៊ីមអត់បានរូសផងហ្នឹងហេ?

ខ:អើរ មិនទាន់រ៉ូសឯណាមីសយយកទៅធ្វើផ្ទះ វាហ្នឹង!

ក:ចាំហើយបានមកធ្វើផ្ទះនៅឯណេះមក!

ខ:បានទិញដីនេះធ្វើផ្ទះនៅឯណេះមក។

ក:ហ្នឹងហើយខ្ញុំដូចជានៅចាំដែរស្រពិចស្រពិលដែលថាពេលនៅក្មេងខ្ញុំមកនោះធ្លាប់មកដេកផ្ទះអ៊ំ
អាពេលថ្ងៃ 5 ថ្ងៃ
6
ណាស់អ៊ំមិនបាញ់គ្នានៅសល់សង្គ្រាមបន្តិចបន្តួចជាមួយប៉ុលពតទៀតហៅ!ខ:អើរ!ក:បាញ់!ខ្ញុំចាំខ្ញុំ
ដេកនៅ
កន្លែងនេះស្ងៀកសារ៉ុងកៅស៊ូទើបតែបានប៉ុន្មានឆ្នាំហ្នឹង!មកហ្នឹងរត់មកជិះរទេះពុកដឹកមកនិងម៉ូតូ
។

ខ:ដល់អង្ពែកចឹងមុនដំបូងអញ្ចេះទេមុនដំបូងពុកថាអង្ពែកហ្អែងរកដីរកអីធ្លីធ្វើនៅទៅអានេះអញ
ទុកឱ្យប្អូនដល់អញ្ចឹ
ងគាត់ហ្នឹងក៏ចេញអោយ 1តំឡឹង!មីស៊ីមនឹងណាស់មីស៊ីមវាយក។

ក:ដោយសារមីងស៊ីមពេលហ្នឹងក៏គ្រាន់បើដែរហៅ?

ខ:ហ៊ីកាលហ្នឹងវាមានហ្នឹង!អ្នកធីគ្រាន់បើនិងណាស់មានមានទាល់តែមែនទែនណាស់!
ក:ល្បីណាស់ពេលហ្នឹង!

ខ:អើរឥឡូវបើកស៊ីមយកអញអោយស៊ីមចេញបើមីសយយកអាហ្នឹងឲ្យមីសយចេញណាស់ ដល់អញ្ចឹងមីសយថា

ញ៉ុមអត់ទេញ៉ុមអត់មានអីផង អោយស៊ីមយកទៅ

ស៊ីមយកដីខ្ញុំយកផ្ទះ!ក:ថា!ខ:គេចែកគ្នាអញ្ចឹងណាស់ អញ្ចឹងក៏

មីស៊ីមគេចេញអោយមួយតំឡឹង

មួយតំឡឹងមកខ្ញុំក៏ចេញមកទិញដីហ្នឹងនេះគ្រាន់តែទិញហើយអីហើយប្រគល់លុយ

ប្រគល់កាក់ពុកអោយមកពុកគាត់ឲ្យមកហ្នឹងមួយតម្លឹងហ្នឹងទិញទិញដីហ្នឹងមួយតម្លឹងពីដីណាស់!ដល់អញ្ចឹងអោយ

ទៅគេទៅមកនៅតែម្តងមកនៅផ្ទះចាស់ហ្នឹងតែម្តងគ្រាន់តែទិញបានហើយមកនៅតែម្តងមកនៅផ្ទះចាស់ហ្នឹងមិនមែន

អានេះសុទ្ធតែអ៊ំធ្វើទេផ្ទះចាស់គាត់ហ្នឹងល្វែងវែងចេះនោះហើយដាក់ធាងស្មោតទេនៅ!អញ្ចឹងនៅដេកនៅធាងស្មោត

ធាងអីហ្នឹងអញ្ចឹងទៅធាងស្មោតឡើងរលោងអាស្មោតគេចាស់នោះហ្ន៎!ខ្ជីមនោះ!ចេះតែនៅអញ្ចឹងទៅយកគ្រែមក

ដាក់ដេកទៅនៅទៅ!ដល់ថារកធ្វើផ្ទះបានឪវាគាត់ក៏យ៉ាកពីមុខនឹងធ្វើខ្ទមនៅទៅប្រ៊ែកស័ង្កសីលិចៗហ្នឹងណាស់ដល់

តែភ្លៀងមកលិចទឹកចូលច្រមុះកូននាំគ្នាដល់ពេលភ្លៀងមកនាំគ្នាឱកូនមួយម្នាក់មួយម្នាក់អញ្ចឹងទៅកំសត់ណាស់មី

អូនណាស់នឹកឃើញថាទិញហើយយើងខ្ជិលមកនៅទីនេះតែម្តងទៅ។

ក:ចា៎! អញ្ចឹងក៏បានមកនៅណេះអីវ៉ាន់អញ្ចឹងទៅ!

ខ:មកន្លូវនេះទៅ!

ក:ហើយដល់ពេលស្រែអីវ៉ាន់បានពីក្រោយក្រោយឯណោះទិញខ្លួនឯងទៀតឬក៏តាចែកអីវ៉ាន់អោយដែលអ៊ុំ?

ខ:អត់ទេអាហ្នឹងរដ្ឋចែកទាំងអស់គ្នាតែម្តងចំណែកយើងរាល់ខ្លួនតែម្តង!

ក:អាហ្នឹងពេលការហើយ។

ខ:ពុកចំណែកជាមួយមីសយ

ហើយខ្ញុំចំណែកជាមួយឪវាឯណាកូនចៅអញ្ចឹងទៅ!រដ្ឋចែកតែម្តងណាស់មិនមានពុកចែកទេ!ដីឯលិចបានពុកចែកដីចំការ។

ក:ហ្ន៎អញ្ចឹងរាល់ថ្ងៃ មានដីកេរ្តិ៍តា?

ខ:កេរ្តិ៍តាតែលក់បាត់ហើយលក់ផ្ទះហ្នឹងណាស់ហ្នឹងហើយធ្វើផ្ទះហ្នឹង។

ក:ចា៎!បានមួយ!ហ្នឹងហើយអ៊ុំអញ្ចឹងអ៊ំមានអីចង់ប្រាប់ខ្ញុំទៀតទេដោយសារខ្ញុំអស់សំណួរសួរអ៊ុំហើយ។

ខ:អស់ហើយ?

ក:ចា៎!

ខ:អស់ហើយអ៊ំអស់ដែរ។

ក:ហ្នឹងហើយដោយសារ ហ្នឹងហើយក្តចបន្តិច
នៅបន្តិចទៀតទេដល់ពេលកូនកូនអ៊ំឲ្យគាត់បានទៅរៀនទៅអីដែរឬ
ក៏អត់អ៊ំ?

ខ:ហ៊ូមីសរថ្នាក់ទី 7មីចមបានរៀនថ្នាក់ទី 6
ទេគ្នារៀនអត់សូវចេះទេវារាងដូចថាអត់មានប្រាជ្ញា!អោយរៀនទាំង
អស់ !កូនអ៊ំអោយរៀនទាំងអស់
ចាន់នីហ្នឹងក៏អោយរៀនដែរ!រៀនទៅដូចថាវាអត់សូវចេះណាស់ដូចថាវាអត់ចូល
ណាស់អត់ចូលចឹងក៏អ៊ំនឹកឃើញថាហើយមីចមវានៅធ្វើការរោងចក្រនៅជិតផ្ទះមីស៊ីមងណោះអីរោ
ងចក្រកាណាឌី
យ៉ាណាស់នឹកឃើញចឹងកូនឯងដូចថាម្តាយវាមិនដឹងរកអីទេពីរនាក់ឪពុកណាស់!អញ្ចឹងកូនឯងទៅ
ធ្វើការជាមួយ
នេះទៅដល់កូនឯងរៀនអត់ចេះអញ្ចឹង!អញ្ចឹងជួយដូចថាជួយជីវភាពអញ្ចឹងទៅណាស់អញ្ចឹងអោយ
មីចមសំ ុគេទៅក៏យកប្អូនទៅនៅជាមួយទៅ!ចាន់នីនឹងធ្វើបានប្រហែលថា 1 ឆ្នាំចុះកុំថាដល់ 5
ខែ6ខែថាមួយឆ្នាំចុះ!ដល់តែនេះ
ទៅបាននាំគ្នាមកវិញមក!មីចាន់នីថាខ្ញុំលែងនៅហើយខ្ញុំមកវិញហើយម៉ែណាស់!
អើរមកវិញទៅមកទៅកូន ចាំ

មើលលោរគេមានការងារអីឯណោះធ្វើចាំធ្វើទៀតទៅអញ្ចឹងក៏ចន្ទីវាមកមុនមកនៅមីចម!នៅមីចម

មីចមធ្វើបាន

ប្រហែលមួយឆ្នាំទៀតបានគេមានប្តីមានអីហ្នឹងគេស្រលាញ់គ្នានៅឯណោះហើយហ្នឹងបានខ្ញុំទៅ

លេងទៅលេងវា

អាភាពខ្ញុំកូនខូវ4

នាក់ទៅលេងឃើញអាមួយហ្នឹងនៅទីហ្នឹងឃើញឪអានេះហ្នឹងឥឡូវហ្នឹងណាស់អាថនហ្នឹងណាស់

វានៅក្នុងបន្ទប់មីចមហ្នឹងជាមួយមីចមហ្នឹងតែមីចមវាយចេញទៅទិញអីហើយនៅតែវា!ដល់ឃើញវា

ឃើញវាក៏ខ្ញុំសួរ

ខ្ញុំសួរថាអាអូនខ្ញុំសួរអញ្ចឹងណាស់!អាអូនអើរអូនឯងស្រលាញ់កូនខ្ញុំនឹងមិនមែន?បាទ!ថាអញ្ចឹង

ណាស់!អញ្ចឹងបើ

អូនឯងស្រលាញ់កូនខ្ញុំ!តែមីចមទៅទិញអីបាត់ហើយនៅតែវានទេបើអូនឯងស្រលាញ់កូនអ៊ំអូនឯង

ទៅហៅម៉ែឪមក

ទៅផ្ទះអ៊ំទៅដល់ផ្ទះអ៊ំ!ថាអត់អីទេអ៊ំថាអញ្ចឹងណាស់អត់អីទេអ៊ំខ្ញុំអោយតែអ៊ំឯងថាចឹងខ្ញុំទៅម៉ែខ្ញុំប្រា

ប់ម៉ែខ្ញុំហើយតែ

ម៉ែខ្ញុំថាដល់មាដល់ម្តាយឯណោះអត់ដឹងអញ្ចអត់ហានទេបើឯងបើម៉ែក្អេកហ្អែងប្រាប់អញ្ចឹងហើយ

អញ្ចទៅអញ្ចឹងគេ

មកស្តីត្រឹមត្រូវណាស់!

ក:អញ្ចឹងក៏បានមកស្តីដណ្តឹងកូនការទៅ!

ខ:ចូលស្តីការទៅ!

ក:យូរឆ្នាំហើយអ៊ំហ៎?ការហ៎?

ខ:ការ ហ៊ឺ មីចមការយូរដែរហើយ អានេះចូលប៉ុន្មានហើយនេះអានេះ 4 ឆ្នាំ(កូនរបស់ចម)ចូល 4 ចូលក្បាល 5

ហើយអាយុ!

ក:ចា៎!ហើយចឹងដល់ពេលអញ្ចឹងអ៊ំដល់ពេល

កូនអីវ៉ាន់ទាំងអស់សុទ្ធតែលើឥវ៉ាន់ទាំងអស់គ្នាលើអ៊ុំទាំងអស់គ្នាផ្គត់

ផ្គង់អ៊ំ?

ខ:ចា៎!ផ្គត់ផ្គង់ដូចថាវាមកពីធ្វើការអ៊ីចឹង

ខ្ញុះទិញផ្លែឈើខ្ញុះទិញនេះទិញនោះអញ្ចឹងទៅណាស់បានហូបអញ្ចឹងទៅ

កូនយកមកឲ្យហូប។

ក:ចា៎ហើយដល់ពេល!តែអ៊ុំអត់បានកូនប្រុសអីមួយសោះជាមួយអ៊ុំអន?

ខ:អត់!

ក:បានតែបងភាពមុនមួយ?

ខ:បានតែភាពមុននឹង។

ក:អញ្ចឹងអ៊ំឆនអត់មានកូនប្រុសទាល់តែសោះ?

ខ:អត់!

ក:សុទ្ធតែកូនស្រីទាំងអស់?

ខ:សុទ្ធតែកូនស្រីទាំងអស់! 6 ហើយចាន់ថន ចាន់ធឿន 2 ហ្នឹងណោះ4 មិនឲហ្នឹង
អ៊ំនេះផងយកចេញមួយផង!
ស្រីទៀតហ្នឹងទៅយកនៅផ្ទះមីស៊ីមឯណោះ!

ក:យ៉ាងម៉េចអញ្ចឹងវិញ?ខ:អ៊ំនៅផ្ទះឯកើត ចាញ់ពេកខ្ញុំថា តែមួយខែកន្លះប៉ុន្តែពេទ្យគេថា 2
ខែ!កូនអ៊ំស្រីទៀត។

ក:ដឹងហើយ?ខ:ដឹងហើយថាស្រីទៀត!មីអូនអើយចាញ់ចំតិតចាញ់ចំតួងស៊ីស្អីក៏មិនកើត!សមអ្នក
ធីមកនោះគេ
មានគេធ្វើស្អីអាឯងនៅក្នុងផ្ទះនេះក្អួតចង់ដាច់ខ្យល់ងាប់ហើយក្អួតធំខ្ចីមអីអត់បានអីអត់បានដល់
នេះក៏ឌឺវាថាអញ្ចេក!
ស៊ីមហ៎អញមើលទៅបងឯងដូចជាពិបាកដល់ហើយចាញ់ម្តងម្តងដាច់ខ្យល់ងាប់ហើយ!នៅកន្លែង
ម្ដុំហ្នឹងមានអា
យ៉ាងម៉េចទេហ៎?សួរអញ្ចឹងណាស់!មានតើបង!ទៅទៅជាមួយខ្ញុំតែម្តងទៅការនិងគេមានឡាន
មីស៊ីមមានឡានពីរ

ឯណោះពេលជិះឡានទៅជាឡានទៅទៅដល់ព្រលឹមឡើង

ទៅដល់ទៅដេកផ្ទះវាមួយយប់ដេកមួយយប់ហើយ

ព្រលឹមឡើងបានទៅយក ទៅយកចេញទៅដូចគេ ដូចគេបេះបោះចោល។

ក:ហ៊ូអាណិតក្មេងជីវិតមួយដែរអ៊ំអើយ!

ខ:បើទុកស្រីទៀត។

ក:ប៉ុន្តែប្អូនចាន់នីទៀតមែនទេ?

ខ:ប្អូនចាន់នីនឹងណាស់!ហេបងចាន់នី បងចាន់នី!

ក:បងមុននឹងហេ!

ខ:បងចន្ថីហ្នឹងហើយបងចន្ថី។

ក:ខ្ញុំនៅទាន់អ៊ំពេលហ្នឹងដូចខ្ញុំទាន់ស្រពិចស្រពិលពេលអ៊ុំពោះធំណាស់!នៅក្មេងក្មេងតូចតូចណាស់ខ្ញុំមកស្រែ
ឃើញអ៊ំពោះធំ។

ខ:ហ្នឹងហើយកំណើតមីមួយស្លាប់ទៅទៀត មីមួយស្លាប់ទៅឆ្នាំខាលបានមកមីចមឆ្នាំថោះ។

ក:ហ៊ឺ!ហើយស្លាប់មូលហេតុអីគេអ៊ំនៅក្នុងពោះឬក៏យ៉ាងម៉េច?

ខ:ស្លាប់ក្នុងពោះអី!ក្មេងអាយុ 1 ខួបជាងហើយជិត 2 ខួបហើយ។

ក:ឈ្លោះអីគេទៅវិញ?

ខ:មមីហ្នឹងហៅតែខ្ចៀចៗ!យាយរិនហៅតែខ្ចៀចៗទេ?ស្គាល់យាយរិនអត់?

ក: ស្គាល់។

ខ:យាយរិនធំឃឺមណាស់!ក:ចា៎!ខ:ហៅតែខ្ចៀចៗទេនិយាយពីស្អាតមិនបាច់ថ្លាសឡើងបែកហើយ
ឡើងអោយរៀប
ថែងហើយអោមចិញ្ចើមឡើងផុតកន្ទុយភ្នែក!ស្អាតណាស់មីហ្នឹងណាស់បើនៅវិញលើមីចមប៉ុន្មានភា
គហ៊ុំលើមីចមលើ
មីអស់ហ្នឹងទៀតឯណោះ។

ក:ហើយពេលហ្នឹងថីបានស្លាប់អ៊ំ?

ខ:ខ្ចៅស្រស់!អញ្ចេកអាសេងហើយច្រឹបហ្នឹងអាសេងច្រឹបហ្នឹងស្គាល់!

ក:ស្គាល់ហើយស្គាល់ហើយ។

ខ:សេងច្រឹបហ្នឹងមានអាសិទ្ធ!ក:ថ៎!ខ:ហើយយើងមានដឹងឯណាចាស់ទុំ!មិនខាងតាឆនៗ

ក:កាច់ហ៎?ខ:ហ៊ឺ!

ក:តែអត់រៀបអោយត្រឹមត្រូវឥ៉ាន់មានទេហេ?

ខ:មានទាន់ដឹងទាន់រៀបអីឯណាវាមិនទាន់បានរៀបឯណាពោះធំហើយនិងពោះធំបានពីរខែមាន
បានរៀបមានអីឯ
ណាព្រោះយាយអីយាយអីម៉ែអាសេងឈ្មោះអី!យាយអីៗ

ក:អត់ស្គាល់ ភ្លេចឈ្មោះបាត់ហើយ!

ខ:យាយអីទេ!អត់អោយអាសេងអត់អោយអាសេងយកទេណាស់!

ក:នៅជិតនេះដែរអ៊ុំ អ៊ំហ៎?

ខ:បងអាសេង!ពួកហ្នឹងនៅទីហ្នឹងសុទ្ធតែខ្សែស្រឡាយយាយនេះហ្នឹង!

ខ:មិនមែនទេ។

ក:ជាប់ផ្ទះយាយឡូយហ្នឹងមិនមែន?ខ:ឈ្មោះយាយអីទេឪវាបានស្គាល់!ក:ថ៎!ខ:ខ្ញុំភ្លេចឈ្មោះដែរ
ហ្នឹងណាស់!

ភ្ជួចឈ្មោះកុងសឿនហ្នឹងឈ្មោះអីគេទេ។

ក:ចឹអញ្ចឹងបានតែជាកាច់យកក្មេង

អញ្ចេះទៅអ៊ំហេ??ខ:គ្រាន់តែប្រហែលព្រឹលៗប្រហែលថាយើងថាម៉ោង៥ ម៉ោង

៥ចុះ!ពុកគាត់ចុះមកដីគាត់សម្រានមានទាន់លក់អីពុកចុះមកគាត់ថាអញ្ចេកចុះកូនយំហើយឯងក៏

មិនយកកូនចុះ

មកអានន!ហើយខ្ញុំហ្នឹងអត់មាត់ទេចុះបើវាធ្វើទុក្ខមួយយប់ទៅហើយក្តៅអ៊ុនៗៗៗហ្នឹងចេះតែរកថ្នាំ

ច្រកវាទៅណាស់

អត់មានដឹងចឹងទេចេះតែរកថ្នាំច្រកវាចឹងទៅហើយពេលព្រលឹមឡើងហ្នឹងប្រហែលភ្លឺម៉ោង 5

ហ្នឹងគិតតែពីយំគិតតែ

ពីស្រែកយកស្រែកយគ្រាន់តែចុះពីកាំជណ្តើរមកមកដល់កាច់យកភ្លាម!គ្រូ 3 4

ហៅគ្រូមកតានៅផងតាសួនផង

ស្គាល់ថាសួនទេ?អត់ស្គាល់ទេមីអូនឯង!

ក:អត់ស្គាល់។

ខ:តាសួនបងរីយកគ្រូទៅ៣ ៤មានទាន់ណាកាច់យកមួយភ្លេតហ្នឹង!

ក:គិរទៅគ្រាន់តែជំនឿចឹងទៅវាសាហាវណាស់ហ៎!ខ:ចា៎!ក:ប៉ុន្តែពេលជំនាន់មុនខ្ញុជឿថាសាហាវ

មែនប៉ុន្តែឥឡូវ

អស់ហើយអស់រលីងហើយអ៊ំអើយ!

ខ:អត់ទេអត់សាបទេ!ប៉ុន្តែគ្រាន់តែថាអ្នកណាធ្វើមិនស្រួលមិនស្រួលដែរហ្នឹងណាស់!អត់ទេនៅតែ
អញ្ជឹងខ្មោច
ចង់កាច់!ជំនាន់ប៉ុលពតបានវាអត់តែម្តង។តែជំនាន់នេះមានម៉ង!ជំនាន់នេះអត់បានទេនៅតែខ្មោច
នៅតែដឹងអញ្ជឹ
ងខ្មោចនៅតែដឹងអញ្ជឹង។

ក:ខ្ញុំឆ្ងល់ហេតុអីបានជាជំនាន់ប៉ុលពតនបានជាចង្រៃយកខ្លាំងម្ល៉េះ!

ខ:វាខ្លាច វាខ្លាចប៉ុលពតដូចជាយើងដែរ។

ក:ចំឆ្ពួតទេហេ?ខ:វាខ្លាចប៉ុលពតចុះមើលមើលអាណាប្រធានភូមិណាវាលេងទៅលេងត្រូវត្រូវវា
លេងវាលេងលេង
ហើយហ៉ានតែប្រាប់គេវាសម្លាប់ចោល!ប្រធានភូមិណាស់។

ក:លេងយ៉ាងម៉េចទៅអ៊ំ?ខ:ចុះវាលេងវាលេងស្រីស្រីហ្នឹងណាស់!វាប្រធានភូមិ!

ក:ហ្នឹងហើយ។

ខ:ហើយដល់ស្រីស្រីនឹងវាញ៉ែញរញ៉ែញរ័ដាក់វាបងលិចបងកើតបងលិចបងកើតវាលេងអញ្ជឹងទៅ
ហើយហ៉ានតែងង
ហ៉ានប្រាប់គេវាសម្លាប់ចោល។

ក:ហ្ន៎ជំនាន់មុនអ៊ំហេ??អញ្ចឹងលែងមានខ្មោចកាច់ទៀតហើយ។

ខ:ជំនាន់ហ្នឹងអត់មានខ្មោចទេឃើញទេ!ខ្មោចអត់ហ៊ានទេខ្មោចខ្លាចអាពតដែរឥឡូវបច្ចុប្បន្នឥឡូវអត់ទេមីអូន។

ក:ហ្នឹងហើយ!

ខ:កុំចង់សាកអត់បានទេ។

ក:ខ្ញុំឆ្ងល់អញ្ចេកដោយសារ!

ខ:តែមើលទាន់មិនទាន់ងាប់ហើយមើលទាន់មិនទាន់ងាប់ហើយ។

ក:ហ្នឹងហើយ។

ខ:កាច់ផ្តែតៗភ្លាមភ្លាមមួយរំពេចមួយរំពេចហ្និង។

ក:ដោយសារអញ្ចេកធអ៊ំពេលជំនាន់អាពតខ្ញុំឮខ្មោចខ្ញុំឮសង្គមខ្មែរយើងខ្មោចលងកាត់អីវ៉ាន់!មន្តអាគមអូមអាមគ្រូ
អីវ៉ាន់ធ្វើឲ្យអ្នកនឹងឃើញអីវ៉ាន់មកផ្ទះអញ្ចឹងឃើញអីវ៉ាន់ចង់ធ្វើអោយងាប់ងាប់បានទៀតហើយចុះពេលជំនាន់អាពត
ហ្នឹងមិនព្រមកាច់!

ខ:កាច់ពួកអាចោរត្រូវគ្រាប់ទាំងអស់ហ្នឹងឲ្យងាប់ទៅ!

ក:ហ្នឹងហើយចា៎!

ខ:អត់ហ៊ានវាអត់ហ៊ានព្រោះតែអញ្ចឹងបានបានអ៊ំថាវាអត់ហ៊ានវាខ្លាចវាខ្លាចដូចជាយើងដែរណាស់
។

ក:ហ្នឹងហើយគ្រូខ្លាំងខ្លាំងណាស់!

ខ:អាគ្រូហ្នឹងវាខ្លាចដូចយើងដែរអាគ្រូក៏វាខ្លាចដែរ!អាគ្រូក៏វាខ្លាច។

ក:ហ្នឹងហើយឱ្យដឹងថាខ្មែរ!

ខ:អោយចេះដូចថាពិតណាស់!

ក:ហ្នឹងហើយ។

ខ:ហ្នឹងធ្វើអោយពិតមកធ្វើឲ្យអ្នកធំធំអោយងាប់ទៅ។

ក:ហើយមិនព្រមចាំ!

ខ:បើពូកែណាស់!

ក:ហ្នឹងហើយ!

ខ:ហើយដូចអញ្ចឹងវាថាវាខ្លាចដែរវាខ្លាចដូចជាយើងដែរ។

ក:ចាំនៅក្នុងស្រុកខ្មែរមិនល្បីថាពូកែធ្វើស្នេហ៍ឬក៏ធ្វើ!

ខ:ឱ្យងាប់!

ក:ហ្នឹងហើយ។

ខ:ធ្វើឱ្យហើមពោះ។

ក:ហ្នឹងហើយហើមពោះស្ទុលៗហើយពេលហ្នឹងខ្លួនឯងកំពុងតែឈឺទនាដែរមិនព្រមធ្វើឱ្យ!

ខ:ងាប់ទៅ!

ក:ជួយគេឥវ៉ាន់អញ្ចឹងទៅចាំបាច់ខ្លាច!ខ:ហ្នឹង!ក:អាគមអូមអាមផ្លូវងងឹតនេះក៏ម្ដេះៗ!មកធ្វើពេលអាសុខស្រុកសុខស្រួល។

ខ:ហ្នឹងខ្លាចគេដែរឥឡូវវាមានខ្លាចអី!ក:ចា៎!ខ:វាអត់ខ្លាចទេ។

ក:អ៊ំជីវិតអ៊ំពេលណាដែលពិបាកជាងគេបំផុតក្នុងជីវិត?

ខ:ហ៊ីពិបាកជាងគេពិបាកជាងគេអត់ពិបាកប្តីមុនពិបាកជាងគេតែដល់ឥឡូវអត់អីទេធម្មតា!

ក:ហ្នឹងហើយ។

ខ:ប្តីមុនដូចថាគ្នាវាដូចថានៅក្មេងដែលណាស់វាដូចថានឹកឃើញចង់ទៅធ្វើទាហានធ្វើទៅ!នឹកឃើញមកផ្ទះមក

មក!នឹកឃើញធ្វើទាហានទៅទៅ ។

ក:អញ្ចឹងប្តីពេលមុនធ្វើទាហានទេអញ្ចឹង?ខ:ប្តីពេលមុនធ្វើទាហានទេតើ!

ក:ហើយអញ្ចឹងបានចាញ់ស្តាប់អ៊ំហ៎?

ខ:ចា៎!

ក:ចា៎ហើយចុះដល់ពេលជីវិតអ៊ំ

ពេលពិបាកពិបាកអឿងប្តីដល់ពេលជំនាន់ប៉ុលពតវាពិបាកហួសពិបាកទៅហើយ!

ខ:ពិបាកហួសហួសពិបាកប៉ាន់ស្មានតែម្តង។

ក:ហើយចុះដល់ពេលសប្បាយជាងគេអ៊ំពេលណាវិញទៅអ៊ំ?

ខ:សប្បាយជាងគេយើងមានប្តីមានសីអីអញ្ចឹងទៅយើងដូចថារកស៊ីស្រួលអញ្ចឹងទៅមានដូចថាសប្បាយចិត្តលែងអី
ទៅ។

ក:ហើយសុខស្រួល!

ខ:សុខស្រួលលេងកាត់ទុកសុខស្រួលតាមនេះទៅតាមដំណើរអញ្ចឹងទៅ។
ក:ហ្នឹងហើយចឹងដឹងពីជីវិតអ៊ំ
អ៊ំដល់ពេលនៅពីក្មេងពីអីមកគ្រួសារឥ៉ាន់ធ្វើតែស្រែហើយមានធ្វើឆ្នោតធ្វើអីឬក៏អីដែរឬក៏អី?

ខ:អត់អត់។

ក:តែស្រែតែមួយមុខ។

ខ:ធ្វើតែស្រែតែមួយមុខធ្វើស្រែហើយនិងដាំដំណាំនិងបន្តិចបន្តួចយើងដូចថាលក់គ្រាន់បានទិញម្ហូបទិញម្ហាអីហូបអ
ញ្ចឹងទៅណាស់!យើងហូបបន្តែបន្តុករបស់យើងដាំអីញ្ចឹងទៅ!

ក:សុខភាពល្អមិនសូវឈឺប៉ុន្មានទេអ៊ំហ៊ៅពេលមុន?

ខ:អត់អត់ដែលឈឺអត់ដែលអីទើបតែមកឥឡូវស៊ីសុទ្ធតែខាងនេះ

ស៊ីសុទ្ធតែជាតិគីមីណាស់រាល់ថ្ងៃ។

ក:ហូបតែមិនស្រួលមិនស្រួលហ្នឹងហូបស្រួលមិនស្រួលហ្នឹងពិបាកឈឺគ្រប់គ្នាអញ្ចឹងអុំអរគុណច្រើនសម្រាប់ថ្ងៃនេះ

សម្រាប់ការដែលអោយខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់អ៊ំចចង់ចូលជិត 2ម៉ោង

!ខ:ចា៎!ក:ចា៎អ៊ីចឹងការសម្ភាសន៍មួយ

នេះពួកខ្ញុំនឹងដាក់ចូលទុកទៅក្នុងវេបសាយនៅក្នុងសាកលវិទ្យាល័យមួយដែលខ្ញុំបានធ្វើកិច្ចការងារឱ្យនឹងហើយថែ

រក្សាសំឡេងរបស់អ៊ុំទោះថារាប់រយឆ្នាំទៅខាងមុខក៏ពួកយើងនៅតែបានឮសំឡេងអ៊ំក៏ដូចជាកូនចៅក្រោយក្រោយ

ទៀតបានដឹងថានេះដូនតារបស់ខ្ញុំប៉ុន្មានជំនាន់ប៉ុន្មានជំនាន់គាត់សំឡេងបែបនេះគាត់មានរូបរាងមុខមាត់បែបនេះ

ដោយសារពួកយើងមានការថតរូបទុករក្សាចឹងអ៊ំណាស់អញ្ចឹងអត់មានអីក្រៅពីមួយនឹងទេគ្រាន់តែរក្សាប្រវត្តិប្រជាជនខ្មែរសម័យឥឡូវហ្នឹងទេចាចឹងអ៊ុំជាចុងក្រោយអ៊ំមានពាក្យពេចន៍អីចង់ផ្តែផ្តាំទៅកាន់កូនចៅខ្មែរក៏ដូចជាកូនក្មួយឥ៉ាន់

ទាំអស់ហ្នឹងហា៎ឱ្យគាត់ដើរលើផ្លូវយ៉ាងម៉េចដែរអ៊ុំ

ខ:អត់សូវចេះនិយាយទេ!

ក:មើលអោយគាត់ដើរផ្លូវយ៉ាងម៉េចដែរអញ្ចឹងណាស់អោយធ្វើជាមនុស្សយ៉ាងម៉េច!?

ខ:អត់សូវចេះនិយាយទេ!

ក:ប្រដៅឥឡូវប្រដៅដូចជាប្រដៅកូនៗចឹងណាស់ប្រដៅថាយ៉ាងម៉េចទៅ!?

ខ:អោយកូនខ្មែរដូចគ្នាអញ្ចឹងទៅអោយចេះរកស៊ីឲ្យចេះគិតគូរអញ្ចឹងយ៉ាងម៉េចនិយាយអញ្ចឹងឬក៏មិនមែន!?

ក:ចា៎!នឹងហើយហ្នឹងហើយអញ្ចឹងឲ្យជៀសផុតពីអីគេដែរអ៊ុំឲ្យពួកគាត់ហា៎!

ខ:ឲ្យជៀសផុតពីដូចថាយើងសុខសប្បាយ ដូចថាយើងឥឡូវនឹងរាល់ថ្ងៃហ្នឹវាសុខវាសប្បាយ
ដូចថាកូនចៅហ្នឹងវា
សប្បាយទៅមុខទៅណា៎!

ក:ចា៎!

ខ:វាអត់មានដូចថាថាសន្តិភាពយើងវារស់រវើកច្ចឹងណាស់

ក:ចា៎!អត់ដូចពីមុន

ខ:អត់ដូចពីមុនទេ

ក:ហ្នឹងហើយឲ្យផុតពីផ្លូវអាក្រក់ៗ

ខ:ហ្នឹងហើយគេចផុតពីផ្លូវអាក្រក់ហ្នឹងទៅកុំអោយមានសង្គ្រាមកុំអោយមានអីទៀត

ក:ហ្នឹងហើយ

ខ:ឲ្យសុខសាន្តរហូតតរៀងទៅណាមីអូនណា៎

ក:ចា៎!ហ្នឹងហើយអញ្ចឹងអរគុណច្រើនអ៊ុំសម្រាប់ថ្ងៃហ្នឹងណា៎! អញ្ចឹង

អរគុណ។